# ផ្ដើមសិក្សាអំពីកុលាលភាជន៍នៅអង្គរ*

Bernard-Philippe Groslier

ខ្មែរបុរាណផលិតកុលាលភាជន៍សម្រាប់ប្រើប្រាស់ជាធម្មតា។ ប៉ុន្តែលើសពីតួនាទីជាសម្ភារៈប្រើប្រាស់ទៅទៀត កុលាលភាជន៍នោះមានលក្ខណៈជាសិល្បៈពិត។ មកទល់បច្ចុប្បន្ន គេពុំសូវចាប់អារម្មណ៍លើវិស័យនេះប៉ុន្មានទេ ដោយសារបុព្វហេតុច្រើន។

បុរាណវិទ្យាខ្មែរនៅតែសង្កត់ខ្លាំងទៅលើប្រាសាទនិងរមណីយដ្ឋានធំៗ ត្បិតចំនួនក៏ច្រើន ហើយមានភាពស្មុគស្មាញ និងប្រកបដោយសោភណភាពទៀតផង។ ហេតុនេះអ្នកស្រាវជ្រាវ ជាបុគ្គលក្តី ជាស្ថាប័នក្តី តែងឲ្យអទិភាពទៅលើការរុករកនិងថែរក្សាវត្ថុទាំងនោះ ហើយគ្មានពេលអ្វីនឹងស្រាវជ្រាវពិចារណាលើវិស័យដទៃទៀតសោះ។ ជួនជាសង្គ្រាមលោកលើកទីពីរមកដល់ទៀតផង វិស័យស្រាវជ្រាវកុលាលភាជន៍ដែលនៅក្មេងខ្ចីនៅឡើយនេះ –ដោយទើបនឹងចាប់កំណើតនៅដើមស.វ.ទី២០– ក៏ត្រូវផ្អើបនៅគាំងរហូតមក។

ខ្មែរបុរាណពុំបានជម្រុញកម្រិតសិល្បៈខាងកុលាលភាជន៍នេះឲ្យបានខ្ពស់ស្មើនឹងវិស័យបដិមាថ្មឬសម្រិតទេ។ ក្នុងទស្សនៈនេះ គេអាចពោលថា ជំនាញនិងទឹកដៃនៅស្មើរនៅឡើយ។ មូលហេតុម្យ៉ាងគឺពេលដែលអារ្យធម៌ខ្មែរលេចមុខផ្លោះឡើង កុលាលភាជន៍ចិនរីកចម្រើនខ្លាំងណាស់ទៅហើយ ជាហេតុនាំឲ្យខ្មែរចាញ់ដំណើរចិនឆ្ងាយ ហើយងើបខ្ពស់ក្នុងវិស័យនេះពុំរួច ឬមួយងើបដោយលំបាក។ មិនតែប៉ុណ្ណោះ តាំងពីស.វ.ទី១០ម្ល៉េះ ខ្មែរនាំចូលមកពីស្រុកចិននូវចានក្បានដែលមានគុណភាពល្អ ចំនួនសន្ធឹកសន្ធាប់ បណ្ដាលឲ្យផលិតផលក្នុងស្រុកគ្មានលទ្ធភាពនឹងប្រកួតប្រជែងជាមួយបាន។ ដូច្នោះខ្មែរពុំឲ្យតម្លៃលើកុលាលភាជន៍ខ្លាំងក្លាប៉ុន្មានឡើយ ហើយបែរទៅនិយមវត្ថុផលិតអំពីលោហធាតុ –ជាពិសេសគ្រឿងជាងទង់– សម្រាប់ប្រើប្រាស់រាល់ថ្ងៃ។ ប្រសិនបើបុរាណវិទូរត្រូវវាយតម្លៃសិល្បៈខ្មែរទូទៅតាមរយៈកុលាលភាជន៍ ច្បាស់ជាគេពុំចាត់ថ្នាក់សិល្បៈនេះក្នុងជួរអ្នកនាំមុខនៃអាស៊ីភាគអាគ្នេយ៍ឡើយ។

ការដែលចម្លែកមួយ គឺអ្នកនាំអាទិ៍ចាប់អារម្មណ៍លើកុលាលភាជន៍ខ្មែរពុំមែនជាអ្នកស្រាវជ្រាវទេ តាមពិតគឺជាអ្នកដែលចូលចិត្តវត្ថុសិល្បៈ ហើយដែលស្វែងរកទិញសន្សំប្រមូលធ្វើសមុច្ច័យផ្ទាល់ខ្លួន។ រីឯប្រវត្តិវិទូរ ទៅជាដើរតាមក្រោយអ្នកអស់នោះទៅវិញ។ ពិព័រណ៍ដែលមាននៅទីនេះ

---

* ក្នុងអត្ថបទផ្ដើមសិក្សានេះ ខ្ញុំនឹងធ្វើការបញ្ជូនអ្នកអានឲ្យមើលរូបកុលាលភាជន៍ដែលនៅក្នុងកាតាឡុកពិព័រណ៍នេះ។ ចំពោះវត្ថុដទៃទៀត ខ្ញុំសូមឲ្យមើលរូបដែលមាននៅក្នុងសៀវភៅមួយចំនួន ដូចមានរាយចំណងជើងនៅខាងក្រោម ហើយដែលខ្ញុំឲ្យឈ្មោះកាត់ផង។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានឃើញរបស់តាំងពិព័រណ៍តែតាមរូបថតពណ៌ប៉ុណ្ណោះ ដែលមានភ្ជាប់ដោយអត្ថាធិប្បាយយ៉ាងក្បោះក្បាយពីគណៈកម្មការរៀបចំ។ ប៉ុន្តែគ្មានអ្វីអាចជំនួសការមើលនិងកាន់ស្ទាបផ្ទាល់បានឡើយ។ ដូច្នេះយោបល់ និងការអះអាងផ្សេងៗរបស់ខ្ញុំ មិនទាន់ជាច់ណាត់នៅឡើយទេ។

ពាក្យកាត់

*Celadons:* *Chinese Celadons and Other Related Wares in Southeast Asia,* Southeast Asian Ceramic Society, Singapore: Arts Orientalis, 1979.

*Ceramics:* R.M. Brown, *The Ceramics of South-East Asia,* Kuala Lumpur: O.U.P., 1977.

*Export:* W. Sorsby, ed., *South-East Asian and Early Chinese Export Ceramics,* London: Sorsby, 1974.

*Legend:* R.M. Brown et al., *Legend and Reality: Early Ceramics from South-East Asia.* Cologne: Catalogue, Museum für Ostasiatische Kunst, 1977.

*Southeast:* Dean Frasche, *South-East Asian Ceramics, Ninth through Seventeenth Centuries,* New York: The Asia Society, 1976.

*Trade:* J. Addis, et al., *South-East Asian & Chinese Trade Pottery.* Hong Kong: Oriental Ceramic Society of Hong Kong, 1979.

សឹងជាភស្តុតាងស្រាប់។ តែយ៉ាងណាក៏យើងត្រូវតែអរគុណយ៉ាងជ្រាលជ្រៅចំពោះ The Southeast Asian Ceramic Society ដែលបានរៀបចំពិពរ័ណ៍នេះ ទោះជាបុរាណវិទូអាចមានការសោកស្តាយដោយប្រការអ្វីផ្សេងៗក៏ដោយ។ ទស្សនៈនៃពិព័រណ៍ក៏អាចមានគុណវិបត្តិម្យ៉ាងដែរ ដោយសារម្ចាស់សមុច្ច័យដែលពោលមកខាងលើ តែងតែចាប់អារម្មណ៍ខ្លាំងទៅលើវត្ថុដែលប្លែក ហើយដើរទិញប្រមូលយកតែវត្ថុណាដែលមានគុណភាពល្អ គ្មានការខូចខាត ឬបាក់បែកតិច។ ដោយសារអ្នកនោះច្រើនជ្រើសរើសតែវត្ថុ "ពិសេស" ដូច្នោះ មនុស្សទូទៅឃើញបានតែទិដ្ឋភាពមួយផ្នែកប៉ុណ្ណោះនៃសិល្បៈកុលាលភាជន៍[៧]។ បើពិនិត្យត្រឹមតែទូដែលរចនាដោយ Oeben ឬ Riesener គេបានយល់ត្រឹមតែសិល្បៈសង្ហារឹមមួយដ៏វិចិត្របំផុតប៉ុណ្ណោះ ប៉ុន្តែពុំបានជ្រួតជ្រាបអំពីសង្ហារឹមដទៃទៀតដែលផលិតនៅតំបន់ឆ្ងាយឬជិតនៃប្រទេសបារាំង នាស.វ.ទី១៨ទេ។ ចានក្បាន់ដែលប្រើប្រាស់នៅវាំងស្តេចចិនក៏ដូចគ្នាដែរ ពោលគឺជាវត្ថុសិល្បៈដ៏ប្រណិតក៏ពិតមែន ប៉ុន្តែពុំបានបង្ហាញឱ្យយើងឃើញពីចានក្បានដែលកសិករចិនប្រើប្រាស់រាល់ថ្ងៃឡើយ។

លើសអំពីនោះទៅទៀត បុគ្គលជាម្ចាស់សមុច្ច័យ អ្នកដើរទិញរបស់ ពុំមែនជាអ្នកស្រាវជ្រាវសិក្សាទេ ដូច្នោះហើយច្រើនតែស្ថិតនៅក្រោមឥទ្ធិពលនៃការឃោសនារបស់អ្នកលក់ ជាពិសេសបើពោលពីប្រភពនៃវត្ថុនិមួយៗដែលខ្លួនទិញ។ យើងគ្មានបំណងបណ្តុះបង្អាប់កិត្តិយសនៃសាជីវកម្មជួញវត្ថុសិល្បៈទេ ប៉ុន្តែយើងត្រូវតែប្រុងប្រយ័ត្នចំពោះទិន្នន័យដែលគេផ្តល់មក ជាពិសេសត្រូវយល់ថា ជួនកាលអ្នកទាំងនោះគ្មានពត៌មានឬចំណេះអ្វីពិតប្រាកដផង។ ដោយហេតុថា ពុំទាន់មានការស្រាវជ្រាវជ្រៅជ្រះនៅឡើយក្នុងវិស័យនេះ គេច្រើនតែប្រាប់ប្រភពព្រមទាំងអាយុវត្ថុនោះដោយ "ជម្រុះ" លទ្ធភាពខ្លះចោល យោងទៅលើការប្រៀបធៀបតាម "អារម្មណ៍"។ ឧទាហរណ៍ បើភាជន៍មួយប្រភេទមើលទៅឃើញថាពុំមែនជាចិនឬសៀម ប៉ុន្តែមានទម្រង់លក្ខណៈបែបឥណ្ឌូចិនខាងត្បូង គេច្រើនអះអាងភ្លាមថាជាខ្មែរ ដោយផ្អែកលើឥទ្ធិពលនិងអនុភាពនៃអាណាចក្រអង្គរ។ រីឯកាលបរិច្ឆេទនៃការផលិតគេសន្មតតាមការមើលឃើញថាមានលក្ខណៈ "ប្រហាក់ប្រហែល" នឹងវត្ថុដែលធ្លាប់បានឃើញតាំងក្នុងទូកញ្ចក់នៃសារមន្ទីរខ្លះ (ដោយពុំទាំងគិតថា សូម្បីពត៌មានលើប្លាកក្នុងទូនោះ ក៏ពុំមែនសុទ្ធតែប្រាកដដែរ)។ ពុំនោះសោត ភាព "ប្រហាក់ប្រហែល" នោះ លើកឡើងដោយប្រៀបធៀបជាមួយរូបផ្សេងៗដែលមានបង្ហាញលក់ក្នុងកាតាឡុកជាដើម។ ថ្វីត្បិតតែការស្មានអាចមានមូលដ្ឋានរឹងមាំ ហើយជួនកាលប្រហែលត្រូវនឹងការពិតផង ក៏គេច្រើនតែពុំផ្អែកលើការពិចារណាល្អិតល្អន់ជ្រៅជ្រះដែរ។ ដូច្នេះការពិតនោះ ក៏ប៉ះដោយកម្រ។ ក្នុងរយៈពេលយ៉ាងយូរ គេនាំគ្នាជឿថា កុលាលភាជន៍ខ្លះដែលនាំចូលពីក្រៅមកក្នុងប្រទេសហ្វីលីពីន ឬទៅប្រទេសឥណ្ឌូណេស៊ី ជារបស់ខ្មែរ ដោយសារតែឃើញថាពុំមានលក្ខណៈចិន (ទាំងរូបរាង ទាំងសម័យកាល) ហើយម្យ៉ាងទៀតដោយសារចានក្បានទាំងនោះ ដុតឡើងមានស្រទាប់រលោងពណ៌ត្នោត (brown glaze) មើលទៅប្រហាក់ប្រហែលនឹងវត្ថុខ្លះដែលធ្លាប់ដឹងថាជាខ្មែរ។

យើងអាចសន្និដ្ឋានថាជា " ខ្មែរ " បាន ចំពោះតែកុលាលភាជន៍ណាដែលប្រទះឃើញនៅស្ថានីយ៍ខ្មែរពិតប្រាកដ ហើយដែលមើលទៅឃើញថាសមជាផលិតឡើងនៅទីនោះ សម្រាប់អ្នកស្រុកនោះប្រើប្រាស់មែន។ គេអាចចាត់វត្ថុទាំងនោះក្នុងក្រុមជាមួយគ្នា ដោយយោងទៅតាមលក្ខណៈពិសេសនៃក្រុមនោះ រួចហើយទើបអាចរៀបរៀងគ្រោងឆ្អឹងនៃកាលប្បវត្តិទូទៅ។ ឯធ្វើរបៀបនោះទៅបាន ក៏លុះត្រាតែវត្ថុចំនួនច្រើនគ្រប់គ្រាន់ដែលយកមកសិក្សា បានមកពីស្រទាប់ដីដែលគេស្គាល់សម័យកាលជាទូទៅ ហើយលុះត្រាតែស្រទាប់ខ្លះៗ មានកាលបរិច្ឆេទផ្ទាល់ខ្លួនឯង ដែលគេដឹងច្បាស់ (absolute dates)។ កុលាលភាជន៍ដែលបំពេញលក្ខ័ណទាំងនេះមានមែនពិត។ រចនាបថ, ការវិវត្តន៍ ព្រមទាំងកាលប្បវត្តិទូទៅពុំមែនស្រួលងាយយល់ដូចគេតែងស្មានឡើយ ត្បិតការស្រាវជ្រាវក្នុងវិស័យនេះទើបតែចាប់កំណើតឡើងប៉ុណ្ណោះ។

ខ្មែរហាក់ដូចជាមិននិយមប្រើប្រាស់កុលាលភាជន៍ណាស់ណាទេ។ នេះគឺមកពីធម្មជាតិដែលនៅជុំវិញខ្លួន ផ្តល់ឱ្យគេនូវវត្ថុធាតុច្រើនបែបយ៉ាងសម្រាប់ធ្វើឧបករណ៍។ តម្បាញឫស្សី, ត្រឡោកដូង, ផ្តៅ, រពាក់លាបម្រាក់ឬជ័រផ្សេងៗដើម្បីកុំឱ្យជ្រាបទឹក... នៅតែប្រើប្រាស់ទាល់សព្វថ្ងៃ តាមស្រុកស្រែចំការ។ វត្ថុទាំងនេះយកទៅប្រើប្រាស់តាមតម្រូវការផ្សេងៗពីគ្នា ហើយរកបានងាយ ដោយពុំចាំបាច់ជួញដូរអ្វីឡើយ ជាពិសេសចំពោះជនជាតិមួយដែលទទួលទានអាហារនឹងដៃ ដោយចាប់យកម្ហូបពីថាស (ត្បាញនឹងវល្លិ៍, ឫស្សី ឬសិតជាលោហធាតុ), ចាប់យកបាយពីស្នុកដែលមានគម្រប។ ចម្លាក់មួយកន្លែងនៅប្រាសាទបាយ័ន្ត (រវាងគ.ស.១២០០) បង្ហាញអំពីក្បួនត្រសោយក្រយា ព្រមទាំងការចំអិនព្រះស្ងោយនោះ (ចូរមើលរូបក១)។ គេចំអិនសាច់ក្នុងខ្ទះធំ ឯបាយក៏ក្នុងឆ្នាំងធំដែរ ហើយដាក់លើចង្ក្រានមុមបី រាងមូល ដូចចង្ក្រានដែលនៅប្រើសព្វថ្ងៃនេះដែរ។ គេដាក់ម្ហូបអាហារនៅលើស្លឹកធំៗសម្រាប់ចាប់យកមកទទួលទាន។ ឯបាយវិញក៏ដូចគ្នា គឺគេដាក់ក្នុងស្នុកដែលមានគម្រប។ មានតែម្ហូបទឹកទេ ដែលហាក់ដូចជា

[៧] ខ្ញុំបានពោលសង្កត់ធ្ងន់លើបញ្ហានេះ នៅក្នុងអត្ថបទមួយដែលខ្ញុំទើបនឹងសរសេរ៖ "La céramique chinoise en Asie du Sud-Est : quelques points de méthode" ហើយដែលនឹងត្រូវចុះផ្សាយក្នុង *Archipel*, Paris, 1981, n. 20។

ចំអិននៅក្នុងថ្នាំងដីតូចៗ។ ទិដ្ឋភាពរបៀបនេះ សព្វថ្ងៃគេអាចឃើញនៅវត្ត ក្នុងឱកាសបុណ្យផ្សេងៗ។ សម័យនេះក៏ដូចនៅសម័យដើមដែរ គេពុំប្រើប្រាស់ចានក្បានជាកុលាលភាជន៍ឡើយ។

យើងអាចសន្និដ្ឋានថា នៅស្រទាប់ជាន់ខ្ពស់នៃសង្គម គេច្រើនប្រើភាជន៍ទាំងឡាយណាដែលធ្វើអំពីលោហធាតុដូចជាស្ពាន់ បន្ទាប់មកប្រាក់។ ក្នុងករណីខ្លះធ្វើអំពីមាសផង។ លទ្ធផលនៃកំណាយផ្សេងៗព្រមទាំងចម្លាក់លើផ្ទាំងថ្មខ្លះធ្វើឲ្យយើងដឹងថាគេនិយមសិប្បកម្មលោហធាតុខ្លាំងណាស់។ សិលាចារិកក៏ឲ្យយើងដឹងដែរថា ក្នុងតង្វាយចំពោះប្រាសាទ តែងតែមានរបស់របរអំពីលោហធាតុដែរ។ នៅស.វ.ទី១៩សូម្បីតែនៅតាមផ្ទះសម្បែងអ្នកក្រ ក៏គេនៅប្រើប្រាស់ភាជន៍ដូចជាគោមឬចានសំប៉ែតស្ពាន់ដែរ បើមានប្រើភាជន៍ដុតរលោងជាសាច់ចាន គឺតែងតែជារបស់ផលិតដោយចិន។

នៅជំនាន់ដើម កុលាលភាជន៍ហាក់ដូចជាទុកសម្រាប់តែការប្រើប្រាស់ផ្សេងមួយបែបពីគេ ណាមួយតម្លៃក៏ថោកផង។ គេប្រើក្នុងការចំអិនផង រក្សាអាហារទុកផង។ ដើម្បីយល់ចំណុះនេះទាល់តែយើងក្រឡេកមើលបច្ចុប្បន្នបន្តិច។

## បច្ចុប្បន្នបង្ហាញអំពីអ្វីខ្លះ?

បើពោលពីកុលាលភាជន៍ធម្មតាប្រើប្រាស់រាល់ថ្ងៃ ខ្មែរសម័យអង្គរ បន្តទម្លាប់ដែលមានជាយូរអង្វែង តាំងពីបុរេប្រវត្តិរៀងមក។ ប្រពៃណីនោះពុំបានផ្លាស់ប្ដូរទេ ហើយខ្មែរនៅប្រកាន់យករហូតដល់សព្វថ្ងៃ[២]។ គេធ្វើថ្នាំងអំពីដីឥដ្ឋដោយគ្រាន់តែយករមូរដីមួយដុំមកវាយឲ្យចេញជារាង ដោយបន្ទះឈើមួយ។ ជួនកាលគេយកកូនទ្រនល់ឈើមកទល់ពីក្នុង ជួនកាលទៀតគ្រាន់តែយកដៃច្វេងមកទប់តែប៉ុណ្ណោះ។ គេពុំប្រើកង់សម្រាប់បង្វិលថ្នាំងទេ។ ស្ទួនគ្រាន់តែដាក់ដីថ្នាំងនៅលើបង្កោលមួយ ហើយដើរជុំវិញវាយដីនោះ។ គេប៉ិនប្រសប់ណាស់ក្នុងការបំបាំងថ្នាំងឲ្យមានរាងផ្សេងៗតាមចំណង់ចិត្តខ្លួន ហើយពីម្ខាងទៅម្ខាងមានទំហំស្មើគ្នា ស្មើរតែឥតខ្ចោះ។ ដើម្បីលំអក្អមថ្នាំងនោះ គេយកស្និតឬស្សីមក "សាក់" នៅលើក្អេង។ មួយបែបទៀត គឺគេយកឈើដែលមានចារក្បាច់ –ឬមួយឈើដែលរុំទៅដោយខ្សែវេញ– មកសង្កត់ផ្ដិតពីលើ។ បន្ទាប់មកទើបគេយកទៅដុតក្នុងគំនរភ្លើងដែលបើកចំហ ឬក្នុងរណ្ដៅរាក់មួយមានដីឥដ្ឋអមជុំវិញ នៅក្រោមគំនរភ្លើងឧស ដែលគេយកចំបើងមកគ្របពីលើ ដើម្បីឲ្យកំដៅជះសព្វជុំវិញបានស្មើល្អ។

របស់ដែលផលិតសព្វថ្ងៃ អាចចែកចេញជាបីក្រុមធំៗ។ ក្រុមទីមួយគឺ "ក្អម" សម្រាប់ដាក់ទឹក ដែលគេអាចដង, កណ្ដៀត ឬទូល ហើយដែលមានខ្លួនមូលប៉ោង, កវែងទៅលើ, រីកមាត់សាយចេញក្រៅ។ ក្រុមទីពីរគឺ "ថ្លាង" សម្រាប់ចំអិនអាហារជាទូទៅ។ ក្រុមទីបីគឺ "ខ្វាង" សម្រាប់ផ្ទុកទឹក, ធញ្ញជាតិ, គ្រឿងទេស... ក្នុងក្រុមធំនេះ មានពាងដែលនៅក្នុងកូនក្រុមភាជន៍ផ្ទុកវត្ថុរាវ។ ក្រៅអំពីនោះ រហូតដល់សព្វថ្ងៃគេនៅតែផលិត "ក្អមពួចជើង" ដែលជាកូនក្អមតូចមានជើង សម្រាប់អប់ទឹកប្រើប្រាស់ក្នុងពិធី, នៅតាមផ្ទះ, ឬនៅវត្ត។ ក្អមពួចនេះ ចុះតំណពូជពង្សពីអង្គរមកដែរ។

សព្វថ្ងៃ ក្រៅពីការចម្រាញ់និងលាយដី ស្ត្រីជាអ្នកធ្វើក្អមថ្នាំង ពោលគឺធ្វើឧបករណ៍ប្រើប្រាស់សម្រាប់សកម្មភាពអាហារជាទូទៅ ដែលជាវិស័យរបស់ខ្លួនក្នុងការចិញ្ចឹមជីវិតរាល់ថ្ងៃ។ បើវិភាគតាមទស្សនៈលោក Claude Lévy-Strauss ស្ត្រីជាអ្នកធ្វើឲ្យ "ឆៅ" ក្លាយមកជា "ឆ្អិន", ឲ្យព្រៃក្លាយមកជាស្រុក។ ពោលម្យ៉ាងទៀតថា ស្ត្រីជាអ្នក "ឲ្យកំណើត"។ ប៉ុន្តែប្រុសជាចុងភៅក្នុងពេលមានបុណ្យឬពិធីធំៗនៅតាមវត្ត។ ក្នុងសម័យកាលមុនៗមក ក៏ប្រហែលការចែកមុខងារនេះដូចគ្នានឹងបច្ចុប្បន្នដែរ។ តាមចម្លាក់ប្រាសាទនានានៅអង្គរ គេឃើញស្រីជាអ្នកដណ្ដាំស្លម្ហូបអាហារសម្រាប់គ្រួសារ ប៉ុន្តែចុងភៅសម្រាប់ព្រះក្រយាំវិញ គឺជាមនុស្សប្រុស។ ប្រសិនបើថ្ងៃណាមួយគេអាចបង្ហាញភស្តុតាងថាជំនាន់អង្គរ ស្រីជាអ្នកធ្វើថ្នាំងក្អមប្រើប្រាស់អំពីដីដុតធម្មតា ឯប្រុសជាអ្នកដុតកុលាលភាជន៍ចេញជាសាច់ចានភ្លឺរលោងសម្រាប់តម្រូវការនៅតាមប្រាសាទនានា និងនៅព្រះរាជវាំង ពេលនោះវិភាគតាមលំអានលោក Lévy-Strauss នឹងមានន័យពេញលេញប្រាកដ។

យ៉ាងណាក៏ដោយ គ្រឿងដីដុតដែលមិនទាន់ចេញជាសាច់ចាន (unglazed) ហើយដែលមានលក្ខណៈប្រហែលគ្នានឹងរបស់ជំនាន់បុរេប្រវត្តិឬរបស់ជំនាន់បច្ចុប្បន្ននេះ គេប្រទះឃើញនៅតាមស្ថានីយ៍ឬរមណីយដ្ឋានផ្សេងៗនៃសម័យអង្គរ។ វត្ថុដែលយកមកប្រើ របៀបដុត និងកំដៅភ្លើង

---

[២] លោក Roland Mourer –ដែលបានសរសេរអត្ថបទផ្សេងៗស្ដីពីក្អមថ្នាំងខ្មែរបច្ចុប្បន្ន– កំពុងសិក្សាបញ្ហាសំខាន់នេះ ក្នុងក្របខណ្ឌនៃនិក្ខេបបទមួយ។ សូមអាន R. Mourer: *Note sur des procédés traditionnels de fabrication de la poterie au Cambodge. Proc. VIIIth Int. Congress of Anthropological and Ethnological Sciences.* Tokyo-Kyoto, 1970, vol. III, pp. 5-10; J. Biagini et R. Mourer: La Poterie au Cambodge. *Objets et Mondes.* Paris, 1971, t. XI, fasc. 2, pp. 197-220។

ព្រមទាំងបច្ចេកទេសផលិត ដូចគ្នាខ្លាំងណាស់រវាងជំនាន់ផ្សេងៗនោះ។ បើកុំតែជំនាន់មុន ក្បូរក្បាច់លំអមានការផ្ចិតផ្ចង់ជាងសព្វថ្ងៃ ច្បាស់ជាគេច្រឡំអំបែងកុលាលភាជន៍ជំនាន់ផ្សេងៗនៃអតីតកាល និងអំបែងកុលាលភាជន៍ជំនាន់បច្ចុប្បន្ននេះជាពុំខាន។ វត្ថុមួយដែលយើងឃើញ មិនសំខាន់ប៉ុន្មានទេ បើយើងពិនិត្យតែចំពោះរាងរៅរបស់វា។ ប៉ុន្តែបើយើងពិនិត្យពិចារណាលើទេសកាល ព្រមទាំងរបៀបដែលគេយកវាមកប្រើ ពេលនោះទើបវត្ថុដដែលនោះមានសារៈសំខាន់ខ្លាំង។

ផ្ទះខ្មែរតែងទ្រដោយសសរផុតពីដី ក្រាលដោយរនាបឫស្សី ឬក្តារដែលមិនផ្គីបគ្នាជិតឈឹងទេ ហើយដែលទន់យោកចុះឡើងតិចៗផង។ ក្នុងនោះគ្មានសង្ហារឹមឡើយ។ អ្វីៗទាំងអស់ គេដាក់ផ្ទាល់លើក្តារ ឬរនាប។ ដូច្នោះហើយបានជាប្រភេទចានក្បានស្ទើរតែទាំងអស់តែងមានគូថមូល កាលណាក្តារឬរនាបមានចលនាកម្រើកខ្លះ ក៏មិនធ្វើឱ្យដួលដែរ។ មានតែពាងដាក់ស្រូវ ឬដាក់ស្រាទេ ដែលមានជើងឬគូថកាត់ស្មើ។ ប៉ុន្តែពីរមុខនេះ គេច្រើនតែទុកនៅក្រោមផ្ទះ ពោលគឺលើដី។ កាលពីសម័យបុរាណក៏ដូចគ្នាដែរ ពាងមានជើងគេប្រើសម្រាប់តម្រូវការតាមប្រាសាទនិងព្រះរាជវាំងដែលកម្រាលតែងតែមាំ។

ដោយសាររបស់របរដាក់ផ្ទាល់លើក្តារ គេតែងមើលឃើញវាពីលើទៅក្រោម បញ្ឆិតតាមមុមណាមួយ។ ក្នុងជំនាន់ណាក៏ដោយ កុលាលភាជន៍ខ្មែរមានលំអក្បូរក្បាច់នៅតែត្រង់កនិងក្អែងប៉ុណ្ណោះ –ព្រោះនេះជាកន្លែងដែលមើលឃើញភ្លាមៗ– មិនដែលមាននៅផ្នែកខ្លួនខាងក្រោមទេ។ នេះគឺខុសគ្នានឹងពែងនៃពួកសាសន៍ក្រិចបុរាណ ដែលមនុស្សប្រុសតែងកាន់ពេលទទួលទានភេសជ្ជៈ ក្នុងឥរិយាបថទម្រេតខ្លួនទៅក្រោយ ឬមួយដែលគេលើកឡើងខ្ពស់ដើម្បីច្រួចក្នុងកិច្ចបូជា។ ក្នុងឥរិយាបថទាំងនេះ គេអាចមើលឃើញផ្នែកខាងក្រោមនៃពែងច្បាស់។ សោភណភាពដែលទាក់ទងនឹងរបៀបរស់នៅនោះ លេចចេញផ្លោមកយ៉ាងច្បាស់ ក្នុងការរៀបចំតាំងវត្ថុ។ រៀបចំកុលាលភាជន៍ចិន ឬក្រិចនៅក្នុងទូកញ្ចក់មួយជាការងាយស្រួលណាស់ ព្រោះគេអាចដាក់វត្ថុនោះនៅកំពស់ណាក៏បាន ជាពិសេសកំពស់ភ្នែកមនុស្សឈរ។ ឯកុលាលភាជន៍ខ្មែរវិញ ពិបាករៀបចំតាំងជាទីបំផុត។ បាតថូ ឬបាតក្រឡផ្សេងៗច្រើនតែមិនជុតឱ្យមានស្រទាប់រលោងជាសាច់ចាន (glaze) ទេ ដូច្នោះអ្នកទស្សនាឃើញកន្លែងដែលមិនមែនធ្វើសម្រាប់ឱ្យមើលនេះ។ ដើម្បីឱ្យអ្នកមើល ឃើញចំកន្លែងក្បូរក្បាច់ល្អ លុះត្រាតែដាក់ក្នុងទូកញ្ចក់ទាប ជាពិសេសចំពោះកុលាលភាជន៍តូចៗមានក្បាច់រូបសត្វដែលច្រើនតែមានភ្នែក ចំពុះនិងកន្ទុយនៅចំពីលើក្អែង ហើយដែលហាក់ដូចជាធ្វើឡើងសម្រាប់មើលបញ្ឆិតពីលើទៅក្រោមវិញ។ ចំពោះប្រអប់តូចៗដែលប្រើសម្រាប់ដាក់បន្ថែមបញ្ហាក៏ដូចគ្នាដែរ។ ដូច្នេះ ចិនតែងកាន់ពែងតូចដែលគ្មានដៃ ដោយកៀបនឹងម្រាមពីរ ហើយសម្លឹងមើលទៅលំអបាតពែងដែលច្នះចាំងចេញពីក្រោមទឹកតែ ហើយទើបលើកពែងនោះមកដាក់មាត់ពេលទទួលទាន។ ឯសាសន៍អឺរ៉ុបវិញ កាន់ពែងត្រង់កន្លែងដៃ ពុំសម្លឹងមើលទៅក្នុងពែងទេ ព្រោះសុទ្ធតែកាហ្វេឬសូកូឡាខ្មៅៗ។ ប៉ុន្តែគេលើកពែងនោះដល់កំពស់ភ្នែក ហើយសម្លឹងមើលទៅលំអក្បាច់ដែលនៅក្រៅពែង។

វត្ថុទាំងអស់នេះ ទាល់តែយកមកប្រើប្រាស់តាមប្រពៃណីនិមួយៗនិងស្ទាបពិនិត្យ ទើបអាចយល់ពីតម្លៃសិល្បៈនិងបុគ្គលិកលក្ខណៈរៀងៗខ្លួន។

## ប្រភពនៃកុលាលភាជន៍អង្គរ
### ចានក្បានប្រើប្រាស់រាល់ថ្ងៃ

ការសិក្សាអំពីកុលាលភាជន៍បច្ចុប្បន្ននេះ ជួយយើងឱ្យយល់ខ្លះៗអំពីផលិតផលដែលកើតឡើងពីស.វ.ទី៦ដល់ទី១៤នៅតំបន់អង្គរ ហើយដែលប្រទះតាមស្រទាប់ដីផ្សេងៗ។ ដើម្បីងាយស្រួលយើងហៅវត្ថុទាំងនោះថា "ចានក្បានប្រើប្រាស់រាល់ថ្ងៃ" ឬ "ចានក្បានធ្វើពីដីដុត" ដោយរំលឹកម្តងទៀតថា វត្ថុទាំងនោះធ្វើដោយដៃ ដោយយកឈើមកឆ្កិតឬចូតជាលំអ។

ក្នុងក្រុមធំនេះយើងរាប់បញ្ចូលនូវរាល់វត្ថុសម្រាប់ដាំស្ល មានមាត់ធំ ហើយបត់រមូរចេញក្រៅជាគែម ព្រមទាំងមានគម្រប។ យើងបំបែកក្រុមនេះចេញជាពីរក្រុមតូចៗបន្ទាប់មកទៀត៖ ថូចំអិនអាហារដែលគ្មានក ដែលប្រហែលពីដើមគេប្រើជាឆ្នាំងដាំបាយ និងថូដែលមានកខ្លី រមូរមាត់ចេញក្រៅ ដែលប្រហែលជាស្រួលប្រើសម្រាប់ស្ល ឬដណ្តាំម្ហូបទឹកផ្សេងៗទៀត។ វត្ថុទាំងនេះមានលំអក្បូរក្បាច់ ដោយគេយកបន្ទះក្តារមានខ្សែវេញមកឆ្កិតពីលើ តែត្រង់កន្លែងក្អែងប៉ុណ្ណោះ ពុំដែលឃើញមាននៅផ្នែកក្រោមឡើយ។

ក្រុមធំទីពីរហាក់ដូចជាទាក់ទងនឹងកុលាលភាជន៍ដែលគេប្រើសម្រាប់ប្រមូលទុក និងថែរក្សាអាហារឲ្យបានយូរ។ គេតែងឃើញមានក្រឡរាងមូល មាត់តូចជាងពពួកទីមួយ ហើយតែងតែមានគម្របជានិច្ច។ ជាទូទៅ គម្របនោះរប៉ាង ហើយមានកំប៉ោយតូចមួយនៅកណ្ដាលសម្រាប់ចាប់ទៀតផង។ ក្រឡរបៀបនេះអាចបិទជិត ដោយយកក្រមួនឬដីឥដ្ឋមកភ្ជាប់នៅត្រង់តំណគម្រប។ ក្នុងក្រុមដដែល គេឃើញមានភាជន៍សម្រាប់ដងទឹក។ គេធ្វើកវាវែងដើម្បីងាយស្រួលកាន់ ឯមាត់វាញែកចេញសាយទៅក្រៅ ដើម្បីស្រួលចាក់វត្ថុរាវបញ្ចូល ឬចាក់ចេញទៅវិញ។ រីឯលំអ ក៏គេឃើញក្បាច់នៅត្រង់ក្អែងដូចមុនដែរ ប៉ុន្តែនៅគូថ ឃើញមានស្នាមខ្សែបណ្ដោយៗគ្នា ដែលប្រហែលគេធូតឡើងសម្រាប់ពេលកាន់ទៅនឹង ស្រួលកណ្ដៀត ហើយដាក់លើក្ដារមិនរអិល។ ក្នុងកូនក្រុមនេះ យើងរាប់បញ្ចូលភាជន៍ធំៗរបៀបជាខ្ទះ ឬថ្លាងដែលប្រហែលជាគេប្រើក្នុងការរៀបចំអាហារសម្រាប់មនុស្សច្រើន ឬមួយក៏សម្រាប់ប្រើការពិសេសដូចជាជ្រលក់ពណ៌, ស្ងោរសូត្រដង្កូវនាង។ល។ ក្រៅពីនេះ គេឃើញមានថ្លាងនិងកន្ត្រង ដែលប្រហែលជាប្រើក្នុងការកូរទឹកដោះសម្រាប់ពិធីព្រាហ្មណ៍។

គេពុំឃើញមានពាងធំសម្រាប់ដាក់ធញ្ញជាតិទេ ដោយសារបច្ចេកទេសដុតមិនអាចធានាឲ្យវត្ថុដែលមានទំហំធំមានភាពរឹងមាំបាន។ ខ្មែរនិយមទុកស្រូវនៅក្នុងជង្រុកដែលមានជញ្ជាំងក្រងដោយបន្ទះឬស្សី។ គេប្រើកញ្ជើ, ល្អី... សម្រាប់ដួសស្រូវពីជង្រុកឬដាក់ទៅក្នុងជង្រុក សូម្បីតែក្នុងការទទួលទានអាហារក៏គេប្រើឧបករណ៍ត្បាញដែរ។ ទម្លាប់នេះ មានចម្លាក់នៅតាមជញ្ជាំងជញ្ជាំងប្រាសាទជាតឹកតាងស្រាប់។

គេពុំអាចរៀបចំកាលប្បវត្តិលំអិតច្បាស់អំពីកុលាលភាជន៍ដែលពោលមកខាងលើនេះទេ។ គួរសង្កេតថាក្នុងជំនាន់ផ្សេងៗតរៀងមក រូបរាងនៅដដែល គ្មានប្រែប្រួលសោះ។ ទោះជាក្បាច់លំអមានខុសគ្នា ក៏ប្រហែលមកពីទំនៀមរចនាតាមតំបន់នានាដែលផលិតនោះខុសគ្នាតែប៉ុណ្ណោះ។ យើងមិនរៀបរាប់វែងឆ្ងាយទៅទៀតទេ អំពីប្រភេទកុលាលភាជន៍មួយបែបនេះ។ ប៉ុន្តែគួរបញ្ជាក់ថា ថ្វីត្បិតតែឈ្មួញនិងម្ចាស់សមុទ្ទ័យផ្សេងៗពុំស្គាល់ ឬពុំរវីរវល់យកចិត្តទុកដាក់ជាមួយ (ដោយសារគេមានហេតុផលរបស់គេ) ក៏យើងពុំត្រូវភ្លេចថារបស់ទាំងអស់នេះ ធ្វើឲ្យយើងដឹងអំពីបច្ចេកទេសផលិតព្រមទាំងរូបរាងមួយចំនួន ដែលជះឥទ្ធិពលទៅលើកុលាលភាជន៍ដែលមានស្រទាប់រលោង។

## កុលាលភាជន៍ផលិតដោយកង់វិល

នៅចុងស.វ.ទី៦ ពោលគឺនៅដើមប្រវត្តិសាស្ត្រកម្ពុជា គេចាប់ឃើញមានកុលាលភាជន៍ប្រកបដោយក្បូរក្បាច់ច្រើន ដែលផលិតជាមួយកង់វិល[៣]។ រីឯកុលាលភាជន៍ដីដុត ដែលស្មូនដើរវាយជុំវិញនោះក៏នៅតែបន្តធ្វើដដែល។ គេដឹងរឿងនេះដោយសារ ការធ្វើកំណាយនៅសម្បូណ៌ព្រៃគុក គេប្រទះឃើញរណ្ដៅផ្សេងៗដែលកប់ចានក្បានរាប់រយ។ ចានក្បានទាំងនោះ អាចពោលថាគេយកមកកប់ចោលដោយជំនឿ។ ក្រឡខ្លះ ដូនឃើញកាត់ក្បាលចេញហើយកប់ជិតគ្នានោះ មួយចំនួនច្រើនទៀត គេឃើញស្នាមបោះច្បាស់នៅគូថ។ គេអាចធ្វើសមត្ថិកម្មផ្សេងៗលើចំណុចនេះ។ ក្នុងចំណោមការស្មានទាំងអម្បាលមាណ គួរគិតថាកុលាលភាជន៍ទាំងនេះត្រូវបានគេប្រើប្រាស់ក្នុងពិធីសាសនា នៅតាមប្រាសាទជាដើម។ លុះដល់គេលែងប្រើដោយប្រការណាមួយហើយ (ក្រោយពីពិធីសំខាន់អ្វីមួយចប់ទៅ ឬដោយព្រឹត្តិការណ៍ពិសេសអ្វីមួយ) វត្ថុទាំងនេះនៅតែមានអនុភាពសក្ដិសិទ្ធិរហូត។ ដូច្នោះហើយបានជាគេយកមក "កប់"[៤]។

វត្ថុភាគច្រើនមានទំហំធំ ដូចជាភាជន៍ដាក់ទឹកដែលមានខ្លួនប៉ោងមូល, កវែង, មាត់រីកសាយផ្ដេកចេញក្រៅ ហើយលំអដោយក្បាច់បន្ទះបញ្ឈរដែលជារបស់ឥណ្ឌា ហៅថា ghata។ ខ្លះតូចជាងនោះ ខ្លួនរាងមូលដែរ ប៉ុន្តែកខ្លីហើយមានចំពួយ ដែលឥណ្ឌាហៅថា bhrngara។ ខ្លះតូចជាងនោះទៅទៀត មានចំពួយវែង ដែលហៅថាកុណ្ឌី[៥]។ ខ្លះគ្មានចំពួយទេ ប៉ុន្តែមាត់បែកសាយចេញក្រៅ ហៅថាក្លស់។ មានថូតូចៗប្រើក្នុងពិធីដែរ។ កវាវែងដើម្បីស្រួលកាន់ ព្រមទាំងធ្វើឲ្យអ្នកកាន់នោះងាយស្រួលលាងដៃខ្លួនឯងផង។ ភាជន៍នេះឥណ្ឌាហៅថា lota។

---

[៣] ភាគច្រើននៃកុលាលភាជន៍នេះ ទាក់ទងទៅនឹងក្រុមប្រាសាទសម្បូណ៌ព្រៃគុកខាងត្បូង ដែលសាងឡើងដោយព្រះបាទឦសានវរ្ម័នទី១ (៦១៦_៦២៧)។ ប៉ុន្តែគេអាចស្មានដែរថា វត្ថុទាំងនោះច្នះបញ្ចាំងនូវរចនាបថនាចុងស.វ.ទី៦។

[៤] កំពីក្ដីខ្លះ –ឧទាហរណ៍ "មហាវង្ស"– ចែងថាគេត្រូវប្រើភាជន៍ថ្មីថែសសម្រាប់ពិធីសំខាន់ៗ។

[៥] ខ្ញុំពុំប្រើពាក្យ kendi ដូចអ្នកខ្លះទេ ព្រោះពាក្យនេះប្រើតាមមាឡាយូ ក្លាយពីពាក្យដើមជាសំស្ក្រិតថា កុណ្ឌី។

រាជវាំងនោះមានដាច់រយៈនៅជំនាន់ខ្លះៗ។ ឧទាហរណ៍ នៅដើមស.វ.ទី១២ ព្រះរាជវាំងហាក់ដូចជាប្តូរទៅកន្លែងដទៃ។ កុលាលភាជន៍ចិនមានគុណភាពខ្ពស់ណាស់។ ក្នុងចំណោមវត្ថុដែលប្រទះឃើញ ខ្លះអាចស្មានបានថា ជាតង្វាយដែលគេថ្វាយមកព្រះរាជាខ្មែរ។ រីឯកុលាលភាជន៍ខ្មែរដែលមានស្រទាប់រលោងក៏មានគុណភាពខ្ពស់ដែរ។ ទាំងអស់នេះសុទ្ធសឹងជារបស់ប្រើប្រាស់ក្នុងវាំង ឯត្បូងទាក៏ឃើញថាខុសស្រឡះពីរបស់ចិន។ នៅបរិវេណខាងក្រោយដែលប្រជុំទៅដោយទីលំនៅនៃព្រះរាជវាំង គេប្រទះឃើញចានក្បានធម្មតា ពុំខុសអ្វីពីចានក្បានដែលអ្នកស្រុកប្រើប្រាស់រាល់ថ្ងៃឡើយ។

គេសង្កេតឃើញថាគុណភាពមានការចុះថយនៅតាមតំបន់ផ្សេងៗឆ្ងាយពីរាជធានី។ ជារឿយៗ ប្រាសាទខ្លះនៅតាមជនបទ តែងមានកុលាលភាជន៍ចិនប្រកបដោយគុណភាពមធ្យមតែប៉ុណ្ណោះ។ រីឯកុលាលភាជន៍ខ្មែរដែលមានស្រទាប់រលោងក៏ដូចគ្នាដែរ ពោលគឺពុំអាចយកទៅប្រៀបនឹងរបស់របរដែលប្រើប្រាស់នៅក្នុងវាំងបានទេ។ ដូច្នេះគេឃើញច្បាស់ថាក្នុងផលិតផលនៅសម័យអង្គរ ព្រះរាជាព្រមទាំងស្រទាប់សង្គមជាន់ខ្ពស់ប្រើប្រាស់របស់ដែលមានតម្លៃ រីឯរបស់ដែលអន់ជាងនោះទើបប្រើប្រាស់នៅតាមខេត្តឬតំបន់នានា។

កុលាលភាជន៍ដែលនៅមានរូបរាងពេញលេញច្រើនតែប្រទះឃើញនៅកន្លែងគេកប់ទុក ឬនៅក្នុងផ្នូរ។ ខ្មែរតែងបូជាសព ទើបយកធាតុមករក្សាទុកក្នុងថូ[៨] ហើយកប់ក្នុងដី។ ជុំវិញនោះ គេបញ្ចុះវត្ថុមានតម្លៃខ្លះ ដូចជាកុលាលភាជន៍ប្រណិតដែលច្រើនតែមកពីចិន, កញ្ចក់ច្លុះធ្វើពីសម្រិត, ទំពក់គ្រែស្នែង, កងសម្រិតជ្រលក់ទឹកមាសសម្រាប់លំអដងក្លស់ឬដងចាមរ។ យើងដឹងតាមរយៈសិលាចារិកថា គ្រែស្នែង, ចាមរនិងក្លស់ ជាគ្រឿងបញ្ជាក់ឥស្សរយសនៃមន្ត្រីឬអភិជនផ្សេងៗ។ ទីនេះគួរចាប់អារម្មណ៍លើចំណុចមួយ៖ វត្ថុចិនដែលប្រើរបៀបនេះ ឥតឃើញមានបាក់បែកអ្វីទេ ចំណែកឯវត្ថុខ្មែរវិញតែងតែត្រូវគេ "បង្ខូច"[៩] ដោយចេតនា (ដូចបានពោលពីមុនមក) ជានិច្ច។

បើវត្ថុបញ្ចុះឃើញនៅផ្នូរណាមួយដាច់តែឯងនោះ ជាការពិបាកកំណត់កាលបរិច្ឆេទខ្លាំងណាស់។ យើងបានប្រទះឃើញកន្លែងបញ្ចុះធាតុធំមួយនៅត្រើយខាងលិចនៃស្រះស្រង់ ដែលមានផ្ទុកកុលាលភាជន៍ពេញរូបរាងច្រើនរាប់រយ។ ទីបញ្ចុះធាតុនោះ មានដំណើរការនៅចុងស.វ.ទី១១ និងដើមបង្អស់នៃស.វ.ទី១២ រួចហើយទើបឃើញមានប្រើប្រាស់នៅចុងស.វ.ទី១២មួយរយៈទៀត។ កាលបរិច្ឆេទលំអិតពិតប្រាកដនៃសពផ្សេងៗ ពិបាកកំណត់ណាស់ ត្បិតវត្ថុដែលយកទៅកប់នោះ នៅស្រទាប់ដីធម្មជាតិ ហើយរបស់របរដែលទាក់ទងនឹងសពនិមួយៗនៅឃ្លាតពីគ្នា។

លើសអំពីនោះទៅទៀត វត្ថុបញ្ចុះមួយក្រុមសម្រាប់សពតែមួយ មិនទៀងថាមានអាយុស្មើគ្នាទេ។ កុលាលភាជន៍ចិនព្រមទាំងវត្ថុសម្រិតដែលធម្មតាងាយស្រួល កំណត់អាយុឲ្យ ហើយដែលបញ្ចុះសម្រាប់សពតែមួយនោះ ច្រើនតែផលិតឡើងពីសម័យកាលផ្សេងពីជំនាន់បញ្ចុះសព។ មើលទៅហាក់បីដូចជាគ្រួសានិមួយៗយកកេរ្តិ៍អាករជាតំណែលពីមុន មកបញ្ចុះជាមួយសពបុគ្គលសំខាន់។ ត្បិតវត្ថុបញ្ចុះទាំងនោះ ច្រើនតែកើតពីសម័យកាលមុនជំនាន់បូជានោះទៅទៀត។ ក្នុងកំណាយនៅស្ថានីយ៍ផ្នូរបុរាណផ្សេងៗលើលោកនេះ គេតែងប្រទះបញ្ហាលំបាកក្នុងការកំណត់កាលបរិច្ឆេទនៃរបស់របរដែលឧទ្ទិសបញ្ជូនទៅជាមួយសពដូច្នេះឯង។

ផ្ទុយពីកន្លែងផ្សេងៗដែលយើងច្រើនតែប្រទះឃើញបំណែក នៅស្រះស្រង់យើងបានកុលាលភាជន៍ពេញរូបរាងជាច្រើនសន្ធឹកសន្ធាប់ ប៉ុន្តែបញ្ហាកាលប្បវត្តិនៅតែមានការស្មុគស្មាញ។ ក្នុងន័យនេះ ភាពចម្លែកស្ថិតនៅត្រង់ថា គឺប្រភពដ៏សម្បូណ៌ទៅដោយកុលាលភាជន៍ជាងគេនេះហើយដែលចោទបញ្ហាច្រើនជាងគេ។

ក្នុងករណីយ៍ខ្លះទៀត យើងប្រទះឃើញក្រឡកំណប់ដែលផ្ទុកវត្ថុមានតម្លៃ ហើយដែលកប់ក្នុងដី។ កំណត់អាយុវត្ថុទាំងនោះ មិនងាយច្បាស់ប្រាកដបានឡើយ។ យើងតែងឮជារឿយៗថា ក្នុងការធ្វើស្រែចំការ មានជាអាទិ៍ពេលភ្ជួរឬសាបព្រួស កសិករប្រទះឃើញកំណប់របៀបនោះ។ កាលពីមុន មិនថានៅប្រទេសខ្មែរឬនៅប្រទេសសៀមទេ កាលណាប្រទះឃើញដូច្នេះ អ្នកស្រែតែងតែយកទៅប្រគល់ឲ្យវត្តនៃសហគមន៍ភូមិរបស់ខ្លួន។ ប៉ុន្តែចាប់ពីពេលថ្មីៗមក វត្ថុរបៀបនេះធ្លងទៅដល់ដៃរបស់អ្នកលក់បុរាណវត្ថុទៅវិញ។ រីឯបញ្ហារកប្រភពវត្ថុ ក៏កាន់តែស្មុគស្មាញខ្លាំងទៅទៀត។

ចំពោះឡសម្រាប់ដុតផលិតកុលាលភាជន៍ ក៏ការយល់ដឹងរបស់យើងមិនទាន់ជ្រៅជ្រះនៅឡើយ។ តាំងពីយូរមកហើយ យើងដឹងថាមានទួលធំៗនៅភ្នំគូលែន –ម្តុំអន្លង់ធំនិងថ្នល់ម្រេច– ដែលជាគំនរកុលាលភាជន៍ខូចនៃឡ។ របស់របរនៃគំនរនេះ ពុំទាន់បានសិក្សានៅឡើយទេ។ បំណែកដែលយកចេញពីផ្ទៃដីខាងលើ ភាគច្រើនមានស្រទាប់រលោង ពណ៌បៃតងខ្ចី, ពណ៌លឿងស្រគាលដូចចម្បើង ហើយយ៉ាងហោចណាស់ផលិតឡើងពី

[៨] លើចំណុចនេះ គម្ពីរក្ហ្ម –ជាអាទិ៍ Açvalâyana Grhasûtra– ក៏មានចែងដែរ ឧទាហរណ៍មានបញ្ញត្តិថា ចំពោះធាតុសពមនុស្សស្រី គេត្រូវប្រើភាជន៍ប្រភេទកំសៀវ។ រីឯសិលាចារិកភាសាខ្មែរវិញ ក៏មានរៀបរាប់តាំងពីស.វ.ទី៧ម៉្លេះ អំពីការកប់ក្រឡដាក់ធាតុនៅក្បែរ ឬនៅក្នុងប្រាសាទ។ តើកោដ្ឋនោះជាកុលាលភាជន៍ ឬលោហធាតុ ?

[៩] ចំពោះការកប់នេះ សូមមើលឧទាហរណ៍មួយនៅក្នុង B.P. Groslier, *Indochina: Archaeologia Mundi.* (Geneva & Paris, Nagel, 1966) p.143។

ពាក់កណ្ដាលស.វ.ទី១១ដល់ស.វ.ទី១៣។ ឡពុំមែនមាននៅតែភ្នំគូលែននេះទេ។ នៅសម្បូណ៌ព្រៃគុក ក្នុងស្រទាប់ដីជំនាន់ស.វ.ទី១០ ក៏គេឃើញចានក្បានដែលប្រើប្រាស់ជំនាន់គ្នាជាមួយអង្គរដែរ ប៉ុន្តែរូបរាងនិងស្រទាប់រលោងខុសគ្នា ជាហេតុឱ្យយើងស្មានបានថា ផលិតឡើងនៅឡផ្សេងៗក្នុងតំបន់នោះ។ កុលាលភាជន៍នៃប្រាសាទព្រះខ័ន –នៅកំពង់ស្វាយ– ដែលផលិតឡើងនៅស.វ.ទី១២ ក៏ស្ថិតនៅក្នុងករណីយ៍ដូចគ្នាដែរ។ លោក Jacques Dumarçay យល់ថាក្បឿងដែលដុតរលោងសម្រាប់ប្រើនៅរាំងឬតាមប្រាសាទ ប្រហែលដូចជាឥដ្ឋដែរ ពោលគឺផលិតនៅពុំឆ្ងាយពីទីសំណង់ទាំងនោះប៉ុន្មានឡើយ[១០]។

ចំពោះមធ្យោបាយនៃការដូរដោះ ឬពាណិជ្ជកម្មកម្រិតធំ (ប្រសិនបើពាណិជ្ជកម្មនោះមានមែន) ដែលទាក់ទងនឹងកុលាលភាជន៍ យើងពុំមានទិន្នន័យអ្វីសោះ។ នៅតំបន់ខ្លះដែលស្ថិតនៅឆ្ងាយពីធានីអង្គរ ខ្ញុំធ្លាប់ប្រទះឃើញនូវបំណែកព្រមទាំងចានក្បានដែលមានទ្រង់ទ្រាយ ឬលក្ខណៈ "អង្គរ"។ ចំណុចនេះអាចស្មានបានថា ប្រហែលមានការដឹកជញ្ជូនកុលាលភាជន៍ ឬក៏មានអ្នកធំណាមួយមកពីរាជធានី តាំងទីនៅកន្លែងនោះមួយរយៈ ឬមួយទៀតក៏វត្ថុដែលប្រទះឃើញ ជារបស់ដែលព្រះរាជាប្រទានឱ្យមន្ត្រីបម្រើរាជការនៅខេត្ត។ បើបញ្ច្រាសពីនោះមកវិញ នៅតំបន់អង្គរ គេពុំទាន់ដែលប្រទះឃើញកុលាលភាជន៍ណាមួយ មកពីភូមិភាគឦសាននៃប្រទេសសៀមសព្វថ្ងៃទេ។ ដូច្នេះបញ្ហាអស់ទាំងនេះនៅតែពុំទាន់មានចម្លើយ។

ការសិក្សាអំពីកុលាលភាជន៍ធ្វើឱ្យដឹងថា ការវិវត្តន៍នៃរូបរាងក្បាច់លំអ និងវត្ថុធាតុដែលយកមកប្រើ ឥតទាក់ទងគ្នាទេ។ ជួនកាលស្រាប់តែឃើញវត្ថុខ្លះលេចធ្លោឡើងភ្លែត ដូចជាថូដែលធ្វើជារូបសត្វ ផលិតនៅស.វ.ទី១១។ រឿងនេះឥតមានទាក់ទងនឹងបញ្ហាបច្ចេកទេសអ្វីទាំងអស់។ ផ្ទុយទៅវិញ ជួនកាលរចនាបថមួយដែលផ្លាស់ប្ដូរ មិនមែនប្រព្រឹត្តទៅតាមការវិវត្តន៍ធម្មតាឡើយ គឺមកពីនៅពេលដុត គេបានជួបដោយចៃដន្យនូវលទ្ធផលមួយថ្មី។

បញ្ហាក្នុងការស្រាវជ្រាវមានភាពស្មុគស្មាញជាងនេះទៅទៀត ដោយសារខ្មែរផលិតចានក្បានខ្លះ ដោយចម្លងតាមរបស់ចិនដែលនាំចូលមកជាច្រើនសតវត្សមកហើយ។ ជាទូទៅចានក្បានចិនដែលមានឥទ្ធិពលលើផលិតផលខ្មែរទាំងនេះ ជួយយើងក្នុងការកំណត់កាលបរិច្ឆេទ។ ប៉ុន្តែលំបាកត្រង់របស់របរនាំចូលអស់នោះ ផលិតនៅទីតំបន់ខុសៗគ្នា នៅប្រទេសចិន។ សូម្បីតែកំណត់កាលបរិច្ឆេទផ្ទៃក្នុងនៃប្រទេសចិនខ្លួនឯងក៏មានការលំបាកទៅហើយ។ នៅអង្គរ យើងប្រទះឃើញតែប្រភេទរបស់ចិនខ្លះៗប៉ុណ្ណោះ ដែលសូម្បីតែចិនខ្លួនឯងក៏ពុំស្គាល់ផង ដោយហេតុថារបស់នោះផលិតចេញពីមណ្ឌលផ្សេងៗ ដែលរកស៊ីនាំរបស់ចេញទៅក្រៅ ហើយដែលផលិតតាមចំណូលចិត្តនៃបរទេសអ្នកទិញនោះ។ រីឯរបស់ចិនមួយចំនួនដែលទើបចេញថ្មីចំពោះស្រុកអ្នកទិញ ក៏អាចដូរម៉ូតនៅប្រទេសចិនទៅហើយដែរ នៅពេលដែលមកដល់ប្រទេសនានានៅភូមិភាគខាងត្បូង។ នៅអង្គរ គេហាក់ដូចជាចូលចិត្ត តែរបស់របរណាដែលផលិតហើយផលិតទៀតនៅចិន ទោះបីជាតាមពិតទៅចិនគេលែងនិយមហើយក៏ដោយ។ នេះមកពីពាណិជ្ជករចិនយល់ពីចំណូលចិត្តអ្នកទិញ ក៏ចេះតែបញ្ជាសូមឱ្យគេផលិតរបស់ដដែលតទៅទៀត ដើម្បីនាំចូលមកស្រុកខ្មែរ។

ដូច្នេះយ៉ាងណាក៏ដោយ ក៏គេត្រូវមានការប្រុងប្រយ័ត្នជាទីបំផុត ក្នុងការកំណត់អាយុកុលាលភាជន៍ ដោយភ្ជាប់សមត្ថិកម្មពីមួយទៅមួយ។ តទៅនេះ ជាការឧបមាមួយៈ ក្នុងការធ្វើកំណាយនៅអង្គរ បុរាណវិទូម្នាក់ប្រទះឃើញក្នុងស្រទាប់ដីមួយ ដែលអាចកំណត់អាយុបាន នូវភាជន៍ខ្មែរមួយនិង "សេឡាដុន"**មួយ។ ដោយសារស្ថិតក្នុងស្រទាប់ដីជាមួយគ្នា បុរាណវិទូរនោះធ្វើការស្មានភ្លាមថាវត្ថុទាំងពីរផលិតនៅជំនាន់ជាមួយគ្នា។ នៅប្រទេសហ្វីលីពីន ចម្ងាយប្រមាណ ៣.០០០ គ.ម.ពីអង្គរ បុរាណវិទូម្នាក់ទៀតធ្វើកំណាយនៅផ្នូរបុរាណមួយ ហើយប្រទះនឹងសេឡាដុនដូចខាងលើដែរ ប៉ុន្តែស្រទាប់ដីនោះពុំអាចកំណត់អាយុបាន។ ដូច្នេះគាត់ក៏យកការកំណត់អាយុសេឡាដុននៅអង្គរមកអនុវត្តន៍លើការកំណត់អាយុផ្នូរនេះ។ ប៉ុន្មានឆ្នាំក្រោយមក បុរាណវិទូទីមួយឃើញគេចុះផ្សាយរូបសេឡាដុនដែលនៅផ្នូរប្រទេសហ្វីលីពីននោះ ប្រកបដោយ "កាលបរិច្ឆេទត្រឹមត្រូវ"។ មិនតែប៉ុណ្ណោះ អាយុកាលនោះគេយកទៅធ្វើជាទីសំអាង សំរាប់កំណត់កាលបរិច្ឆេទឱ្យផ្នូរនោះទៀតផង។ ដូច្នេះសមត្ថិកម្មរបស់គាត់ហាក់ដូចជាមានហេតុផល "ច្បាស់ប្រាកដ" ដោយសារនៅហ្វីលីពីនមានការអះអាងដូចគ្នា។ តាមពិត គោលប្រាកដគ្មានឡើយ ព្រោះនេះគ្រាន់តែជាកង់មូលមួយជុំដែលរកដើមនិងចុងមិនឃើញតែប៉ុណ្ណោះ ប្រៀបបីដូចជាកូនឆ្កែមួយដែលខាំអង្កៀមចុងកន្ទុយខ្លួនឯង ដោយស្មានថាកំពុងខាំទំពាសត្វអ្វីមួយជាចំណី។

ហេតុផលទាំងប៉ុន្មាននេះបង្ហាញថា យើងពុំទាន់អាចកំណត់កាលប្បវត្តិជាក់ច្បាស់នៅឡើយទេ។ ឯការចាត់ប្រភេទកុលាលភាជន៍ជាក្រុម

[១០] Jacques Dumarçay, *Charpentes et Tuiles khmères*. Paris, EFEO, 1973, p. 8។

* កុលាលភាជន៍ចិន ដែលមានពណ៌ផ្ទៃមេឃទាញទៅរកបៃតងខ្ចី (កំណត់អ្នកប្រែ)។

ផ្សេងៗ ក៏ពុំអាចទាន់លំអិតបានដែរ គ្រាន់តែអាចសម្គាល់កត់ត្រាការវិវត្តន៍ទូទៅតែប៉ុណ្ណោះ។ យោងទៅតាមគោលគំនិតទាំងប៉ុន្មានខាងលើ ការសិក្សាដែលខ្ញុំនឹងលាតត្រដាងបន្ទាប់ទៅនេះ នឹងមិនខុសទាំងស្រុងឡើយ។ វត្ថុខ្លះដែលតាំងក្នុងពិព័រណ៍នេះ ខ្ញុំយល់ថាប្រហែលមានចំណាស់ជាងកាលបរិច្ឆេទដែលគេសន្មត ដោយពិនិត្យលើលក្ខណៈពិសេសខ្លះនៃស្រទាប់រលោង ឬរូបរាង។ តាមធម្មតា រចនាបថមួយដែលទើបនឹងផុសចេញមក រមែងត្រូវការពេលមួយរយៈ មុននឹងផ្សព្វផ្សាយទៅទិសទីផ្សេងបាន។ ដើម្បីកំណត់អាយុកុលាលភាជន៍ ខ្ញុំមានទម្លាប់យកអាយុនៃប្រាសាទជាគោល កាលណាប្រាសាទនោះមានឲ្យកាលបរិច្ឆេទក្នុងសិលាចារិក ព្រោះនេះជាប្រភពដែលជឿបានទាំងស្រុង។ ស្រទាប់គ្រឹះនៃប្រាសាទទាំងនោះ ច្រើនតែសម្បូណ៌ទៅដោយបំណែកកុលាលភាជន៍។ ប៉ុន្តែ "រចនាបថ" នៃកុលាលភាជន៍ ក៏អាចមានចំណាស់ជាងរចនាបថនៃស្ថាបត្យកម្មដែរ។

យើងមិនត្រូវភ្លេចសោះឡើយនូវកត្តាស្មុគស្មាញទាំងអស់នេះ។ បើចងចាំបែបនេះបានខ្ជាប់ ទើបយល់ថាសេចក្ដីដែលខ្ញុំនឹងអធិប្បាយបន្ទាប់ទៅ គ្រាន់តែសន្មតបាននៅពេលនេះទេ លទ្ធផលនៃការស្រាវជ្រាវទៅអនាគតអាចនឹងឲ្យខ្ញុំខុសក្នុងអះអាងផ្សេងៗ។

## សិល្បៈមួយចាប់កំណើតឡើង

កុលាលភាជន៍ដែលមានស្រទាប់រលោង កើតឡើងនៅរាជ្យព្រះបាទឥន្ទ្រវរ្ម័ន (៨៧៧-៨៨៩)។ រីឯក្បឿងភ្លីរលោងក៏ដូចគ្នាដែរ (សូមមើលរូបលេខ១៤)។ តំបន់ដែលកើតនោះគឺរលួស ពោលគឺអតីត "ហរិហរាល័យ"។ ទីនេះជារាជធានី ហើយជា "បុរីបណ្ដាញទឹក" ទីមួយ [១១] ដែលមានទំហំធំ។

របស់របរទាំងនោះគឺគោមដែលឥតមានជើង, រាងមូល, ឬមួយរាងដូចសាជីកំបុតចុង ហើយត្រឡប់មាត់ទៅលើ។ ខ្លះជាកូនដបតូចៗ (កំពស់ ៨ស.ម.-១០ស.ម.) កត្រង់, ខ្លះឥតមានមាត់រីកសាយទេ ខ្លះទៀតមានក្បាច់ខ្សែបញ្ឈរជាតែម[១២]។ បើយោងតាមទំហំ វត្ថុទាំងនេះប្រើសម្រាប់ដាក់គ្រឿងក្រអូប ឬប្រេងអ្វីពិសេសជាដើម។

មានកូនភាជន៍ម៉្យាង (វិជ្ឈមាត្រ ៨ស.ម.-១២ ស.ម.) ដែលសម្បូណ៌ ហើយដែលមានបែបផែនផ្សេងពីគេ*។ រាងវាសំប៉ែតលើ សំប៉ែតក្រោម ខ្លួនមូល តែកាត់បញ្ឆិតពេលកាច់មកក្រោម។ គម្របក៏ដូចគ្នាដែរ។ មាត់នៃផ្នែកខ្លួនខាងក្រោមមានភាពស្ដើង ចូលទៅក្នុងស្រទាប់គ្របបាត់កាលណាគេបិទភាជន៍នោះ។ ប្រហែលជាគេប្រើសម្រាប់ដាក់គ្រឿងសំអាង ឬក៏ដាក់បង្អែមតូចៗផងក៏មិនដឹង។ ភាជន៍មានគម្របម៉្យាងទៀត (កំពស់ ១៥ស.ម.) រាងស្រដៀងប្រអប់ដែលនៅអឺរ៉ុបគេដាក់ថ្នាំខ្សៀរ។ តួវាកាត់ស្មើ ខ្លួនមានរាងដូចបំពង់ ជួនកាលប៉ោងឡើងលើបន្តិច។ តែមគម្របបញ្ឈរនៅត្រង់កន្លែងខាំញីឈ្មោល តែរាងប៉ោងបន្តិច។ នៅចំកណ្ដាលមានកំពោយកាន់ រាងដូចចុងផ្លែឈើ ហើយរុលមកក្នុងគម្របនោះវិញ (មើលរូបលេខ១១)។ មិនដឹងជាគេប្រើសម្រាប់ដាក់អ្វីទេ។ ឬមួយគេដាក់ម្លូ? បួនសតវត្សក្រោយនោះមកទៀត គេឃើញមានរូបភាជន៍នោះឆ្លាក់នៅផ្ទាំងចម្លាក់ប្រាសាទបាយ័ន្ត ហើយពិនិត្យមើលទៅសមជាគេដាក់ម្ហូបទឹក ឬសាច់ នៅពេលទទួលទានអាហារ (មើលរូប១)។ ប៉ុន្តែទាំងនេះគ្រាន់តែជាការស្មានប៉ុណ្ណោះ។ គេនិយមប្រើវត្ថុនេះច្រើនសតវត្សតគ្នា រហូតដល់សន្តតិវង្ស Yuan នៅប្រទេសចិន។ ចាប់អំពីនោះមក គេនាំចូលពីចិនមកវិញនូវភាជន៍ដែលមានរូបរាងដូចគ្នាដែរ។ មើលទៅប្រហែលភាជន៍ នេះហើយដែលខ្មែរយកធ្វើជាគម្រូ។ ហើយបើពោលជាទូទៅ ភាជន៍ប៉ុន្មានយ៉ាងដែលរៀបរាប់មក ប្រាកដជាធ្វើតាមគម្រូចិន។

បច្ចេកទេសផលិតនោះ គឺប្រើកង់វិល ដូចយើងឃើញតឹកតាងតាមរយៈស្នាមខ្លះ ជាពិសេសនៅគូថភាជន៍យើងឃើញស្នាមក្រយ៉ៅដែលជិតឡើង ដោយសារគេយកខ្សែលួសមកកាត់ឲ្យដាច់ចេញពីទម្រកង់វិល។ បច្ចេកទេសនេះគឺចិន។ ខ្ញុំសង្ស័យថាជួនកាលគេប្រើពុម្ពទៀតផង ដោយសង្កេត

---

[១១] តាមយោបល់ខ្ញុំ គឺហរិហរាល័យ ដែលជារាជធានី "អង្គរ" ដំបូងបង្អស់ ពុំមែនយសោធរទេ។ សូមអាន B.P. Groslier, "La Cité hydraulique angkorienne...", *op. cit.*

[១២] អ្នកស្រី R.M. Brown, *Ceramics*, p. 31, fig. 9, យល់ថាគម្រូនៃវត្ថុនេះអាចជា ghata ក្លីង្គ។ ប៉ុន្តែភាជន៍នេះ តែងតែខុសពី ghata និងធំជាងផង។ គេប្រទះឃើញច្រើននៅសម្បូណ៌ព្រៃគុក។ ទងឈូកដែលចេញពីមាត់ ជាភស្ដុតាងស្រាប់។ មិនតែប៉ុណ្ណោះ អ្នកស្រី Brown យករូបមួយនៅ Borobudur មកប្រៀបធៀប ប៉ុន្តែរបៀបនោះគ្មាននៅក្នុងសិល្បៈខ្មែរឡើយ។ តាមពិត គម្រូវត្ថុនេះគឺកូនភាជន៍ hu ដែលមានជាទូទៅតាំងពីសម័យ Han ជាពិសេសនៅវៀតណាមខាងជើង។ចំពោះគម្រូចិន សូមមើល *Celadons*, no. 4 (ប៉ុន្តែភាជន៍នោះមានកប៉ោង) ឬមួយមើល *Trade*, p. 65, no. 20។

* នៅទីនេះ ប្រហែលលោក Groslier ចង់និយាយពី តទ្លាប់ (កំណត់អ្នកប្រែ)។

ឃើញរាងស្មើគ្នាគ្រប់ជ្រុងជ្រោយ ហើយទំហំប៉ុនៗគ្នា ស្ទើរតែឥតឯាករេ យ៉ាងច្រើនខុសគ្នា១ ម.ម.។ ប៉ុន្តែវត្ថុដែលសង្ស័យនេះ ពុំសូវសម្បូណ៌ ដូច្នេះសន្មតច្បាស់មិនកើត។ គួរបញ្ជាក់ថាខ្មែរប៉ិនប្រសប់ខ្លាំងណាស់ក្នុងការប្រើពុម្ពផលិតរបស់របរមួយចំនួន មានក្បឿងជាដើម។ ក្រៅពីនោះ គេពូកែយកដីឥដ្ឋមកបោកសង្កត់លើពុម្ពឈើមួយ ដែលគេមានយកក្រណាត់មកទ្រាប់ ដើម្បីងាយស្រួលផ្តាច់វត្ថុផលិតនោះពីពុម្ពមកវិញ[១៣]។

ដីឥដ្ឋដែលប្រើ ច្រើនរឹង, ពណ៌សស្រអាប់ល្អក់, មានខ្យល់នៅក្នុងរន្ធតូចៗ (បើយកកែវពង្រីកមកឆ្លុះ នឹងឃើញរន្ធនោះច្បាស់)។ ដីនោះស្អាត គ្មានកំទេចអ្វីទេ ហើយពុំឃើញមានប្រើវត្ថុធាតុបន្ថែមសម្រាប់ពង្រឹងឡើយ។ ភាជន៍នេះតែងមានស្រទាប់រលោងនៅខាងក្រៅ។ ចំពោះគម្របវិញអាចមាននៅក្នុងផង។ ស្រទាប់នោះស្តើង, ជាប់ល្អជាមួយតួវត្ថុ ហើយពុំប្រេះស្រាំទេ។ ពណ៌វាមានតាំងពីពងមាន់ ទៅដល់លឿងដូចចម្បើង ជួនកាលទៅដល់បៃតងដូចទឹកតែចិន។ ពណ៌ទាំងនោះ ស្ថិតនៅក្រោមស្រទាប់រលោងស្រអាប់មួយ។ យើងមានលទ្ធផលនៃវិភាគគីមីតែចំពោះក្បឿងប៉ុណ្ណោះ។ ក្នុងវិភាគនេះ ឃើញមាន uranium oxide ហើយយើងមិនយល់ថាវត្ថុធាតុនេះមកពីណាផង គ្រាន់តែធ្វើឱ្យយើងគិតថាប្រហែលជាអុកស៊ីតស្ពាន់ (copper oxide)[១៤]។ ប៉ុន្តែទោះបីយ៉ាងណា ក៏យើងពុំដែលធ្វើវិភាគជ្រៅជ្រះអ្វីមួយសោះ សូម្បីតែអំពីកំដៅដុតក៏ទេដែរ។ ដូច្នេះខ្ញុំនឹងខំជៀសវាងធ្វើការអះអាងលើឈ្មោះឬចំនួនផ្សេងៗ ដរាបណាលទ្ធផលនៃការស្រាវជ្រាវបច្ចុប្បន្នមិនទាន់មានគ្រប់គ្រាន់។

ភាជន៍ប្រភេទខាងលើនេះ ខ្ញុំបានជួបពីរ នៅបក្សីចាំក្រុង និងមួយទៀតនៅធម្មនន្ទ។ ទាំងបីនោះ សុទ្ធតែគ្មានស្រទាប់រលោង។ ហើយដោយសាររូបរាងទាំងមូលនៅពេញលេញ យើងអាចសន្និដ្ឋានថា មិនមែនធ្លាប់មានស្រទាប់រលោង ហើយស្រទាប់នោះរបេះចេញក្រោយមកទេ។ ដូច្នោះប្រហែលជាអាចដុតពីរដងបើមានតម្រូវការ។ ដុតលើកទីពីរសម្រាប់ភ្ជាប់ស្រទាប់រលោង។ បើដូច្នេះមែន វត្ថុទាំងបីនេះប្រហែលគេយល់ថាមានតម្លៃ ឬល្អសមល្មមប្រើហើយ ពុំចាំបាច់មានស្រទាប់រលោងបន្ថែមក៏បានដែរ។

ទោះជាពីមុនមក កុលាលភាជន៍ប្រើប្រាស់រាល់ថ្ងៃមានស្រទាប់រលោង ដោយគេប្រើផេះក៏ដោយ (ព្រោះមានបំណែកខ្លះធ្វើឱ្យយើងយល់យ៉ាងនេះ ប៉ុន្តែស្រទាប់នោះអាចកើតឡើងដោយចៃដន្យក៏មិនដឹង) ក៏យើងជឿច្បាស់ថា បច្ចេកទេសនិងឧបករណ៍មានការផ្លាស់ប្តូរខុសស្រឡះអំពីមុន ទើបផលិតកុលាលភាជន៍មានស្រទាប់រលោងពិតប្រាកដយ៉ាងនេះបាន។ អំណើះតទៅ អ្វីក៏ចម្លងមកពីចិនដែរ៖ ប្រភេទដីឥដ្ឋ, របៀបដុត, ស្រទាប់រលោង, រូបរាងទូទៅ។ នេះឃើញច្បាស់ថាខ្មែរខំចម្លងតាមវត្ថុដែលផលិតនៅតាមឡល្បីៗនៅស្រុកចិនដូចជា Yue និង Ting ហើយបន្ទាប់មកសេឡាដន ក៏ចាប់ផ្តើមនាំពីស្រុកចិនចូលមកអង្គរ។ ក្បឿងក៏ស្ថិតនៅក្នុងករណីយ៍ដូចគ្នា គឺគេធ្វើពីរបែបថ្មី៖ ក្បឿងផ្កាប់និងផ្ងារ មានស្រទាប់រលោងពីក្រៅ។ គេលែងប្រើហើយក្បឿងប្រភេទចាស់ គឺក្បឿងសំប៉ែតមានទំពក់, ឥតមានស្រទាប់រលោង, ហើយដែលជាឥទ្ធិពលឥណ្ឌា។ លោក J. Dumarçay បានសិក្សាបញ្ហានេះយ៉ាងជ្រៅជ្រះ គប្បីយោងអ្វីៗតាមសំណេររបស់គាត់[១៥]។ ខ្ញុំយល់ដូចគាត់ដែរថា ឥទ្ធិពលចិននៅទីនេះជាក់ស្តែងណាស់ទោះបីជាការវិវត្តន៍ផ្ទៃក្នុងខ្មែរមានដែរក៏ដោយ ជាពិសេសបើនិយាយអំពីគ្រោងឈើទាំងមូលនៃដំបូលផ្ទះ។ ឥទ្ធិពលនេះមានដូចគ្នានៅប្រទេសចម្ប៉ាហើយប្រហែលជាចូលមកតាមតុងកឹង ដែលជាអាណាខេត្តមួយរបស់ចិន។

ខ្ញុំមិនជឿទេថា បច្ចេកទេសថ្មីស្រឡាងមួយ ព្រមទាំងមានកម្រិតខ្ពស់បែបនេះ ខ្មែរអាចបង្កើតដោយខ្លួនឯង ដោយគ្រាន់តែយកកុលាលភាជន៍នាំចូលពីស្រុកចិនមកពិនិត្យ។ គឺច្បាស់ជាមានស្មូនចិន ឬស្មូនដែលស្គាល់ប្រពៃណីឡចិនមកតាំងទី ធ្វើឡរកស៊ីទើបទៅរួច។ រីឯពាក្យថា "ចិន" ឃើញឡើងដំបូងបង្អស់នៅសិលាចារិកភាសាខ្មែរស.វ.ទី១០។ នេះពុំមែនជាការចៃដន្យឡើយ។ ក្នុងនោះមាននិយាយថាព្រះបាទឥន្ទ្រវរ្ម័ន –តមកព្រះបាទយសោវរ្ម័ន– វាតទឹកដីនៃអាណាចក្រទៅខាងជើង "ទល់នឹងប្រទេសចិន"។ សេចក្តីនោះពុំត្រូវប្រែតាមន័យចំៗទេ គឺគ្រាន់តែមានន័យថាប្រទេសជាមហារដ្ឋអំណាចទីមួយដែលនៅ "ខាងជើង" កម្ពុជានោះគឺចិន ពុំមានន័យថាជាប់ប្រទល់គ្នាទេ។ តាមពិតទៅគឺប្រាសាទខ្មែរក្នុងរចនាបថនោះ ដែលគួរកំណត់ព្រំប្រទល់ឱ្យប្រទេសនៅសម័យនោះតែម្តង។ ព្រំប្រទល់ពេលនោះមិនទាន់ឡើងហួសទៅខាងជើងស្ទឹងសេមូលឡើយ។ បើឡើងតាមទន្លេមេគុងវិញ ក៏ពុំទាន់ទៅហួសខាងជើងវត្តភូដែរ[១៦]។ យើងត្រូវចាំថា នៅរវាងគ.ស.៩០៦ ចិននៅតែជាអាណាព្យាបាលលើវៀតណាមខាងជើងនៅឡើយ ដែលស្ថិតនៅប្រមាណកំពស់តំបន់វេ។ បើនិយាយថាកុលាលភាជន៍ចិនចូលមកអង្គរតាមផ្លូវគោក –តាមរយៈចម្ប៉ា– ក៏ស៊ីងថាបាន ព្រោះប្រទេសនេះ

[១៣] J. Dumarçay, *Charpentes..., op. cit.*, p. 8។

[១៤] J. Dumarçay, *Charpentes..., op. cit.*, pp. 9-73។

[១៥] J. Dumarçay, *Charpentes..., op. cit.*។

[១៦] B.P. Groslier, "Prospection des sites khmers du Siam," in B.P. Groslier, ed., *Coûts et Profits en Archéologie*. C.R.A., Paris, CNRS, 1980, pp. 33-57។

និងអាណាចក្រអង្គរមានទំនាក់ទំនងគ្នារហូត។ *រវាងគ.ស.៩៥០* ព្រះបាទរាជេន្ទ្រវរ្ម័នបានលើកទ័ពទៅវាយរហូតដល់ញ៉ាត្រាំងទៀតផង។

ប៉ុន្តែផ្លូវនាំចូលសំខាន់ជាងគេគឺសមុទ្រ។ កុលាលភាជន៍ចិនដែលប្រទះឃើញនៅតាមច្នេរនៃរដ្ឋផ្សេងៗនៅអាស៊ីអាគ្នេយ៍ជាតឹកតាងស្រាប់។ នៅអង្គរ កុលាលភាជន៍ចិនជំនាន់ចាស់កម្រមានណាស់។ វត្ថុដែលប្រទះឃើញគឺ បំណែកខ្លះមកពីឡ Yue, មកពីឡ Ting មានប្រមាណជាង៥៧, បំណែកខ្លះដែលមានស្រទាប់រលោងពណ៌ដូចទឹកឃ្មុំខាប់ ហើយដែលលំអទៅដោយរូបបិទភ្ជាប់ផង។ ទាំងអស់នោះប្រហែលជាជំនាន់ចុងសន្តតិវង្ស Tang ហើយយ៉ាងណាក៏មានរបស់របរជំនាន់ 'សន្តតិវង្សទាំងប្រាំ' ដែរ។ ប៉ុន្តែយើងពុំទាន់បានធ្វើកំណាយរមណីយដ្ឋាននានានៅចន្លោះសម្បូណ៌ព្រៃគុកនិងរលួសនៅឡើយ។ បើពោលពីសេឡាដុនវិញ យើងប្រទះឃើញចំនួនរាប់រយ ដែលផលិតជំនាន់ដើមសន្តតិវង្ស Song ខាងជើង។ ភស្តុតាងទាំងអស់នេះធ្វើឲ្យងាយយល់ថា តាំងពីដំបូងឡើង ខ្មែរជាប់ចិត្តខ្លាំងណាស់នឹងកុលាលភាជន៍ចិន ដែលនាំចូលមកស្រុកខ្លួននេះ ហើយខំចម្លងធ្វើតាមទៀតផង។

យើងពុំដឹងទេថា ខ្មែរចាប់ផ្ដើមសាងឡនៅទីណាមុនដំបូងបង្អស់។ អ្នកស្រាវជ្រាវមានទម្លាប់ហៅរាល់ស្រទាប់រលោងពណ៌លឿងនិងពណ៌បៃតងខ្ចីថា 'គូលែន'។ ជាការពិតមែន ដែលឡនៅគូលែនផលិតកុលាលភាជន៍ប្រភេទនេះ ប៉ុន្តែយើងមិនដឹងថាចាប់ផលិតពីពេលណាមក។ រីឯនៅឧទ្យានអង្គរ យើងពុំដែលប្រទះឃើញស្ថានីយ៍ឡទេ។ តាមភូគព្ភសាស្ត្រខ្ពង់រាបភ្នំគូលែនមានកន្លែងច្រើនដែលមានដីឥដ្ឋម្យ៉ាង, ថ្មនិងខ្សាច់សម្រាប់ពង្រឹងដីនោះ, ដីឥដ្ឋដែលមានជាតិដែក, ប្រភពទឹកថ្លាស្អាតជាច្រើន ព្រមទាំងព្រៃឈើផង។ ដើម្បីកុំឲ្យសាំញ៉ាំច្រើន ខ្ញុំប្រើពាក្យ 'គូលែន' តាមគេដែរ សម្រាប់សំដៅលើស្រទាប់រលោងក្នុងប្រភេទបានពោលមកនេះ។ ប៉ុន្តែយើងត្រូវកុំភ្លេចថា នេះគ្រាន់តែជាការប្រើពាក្យសន្មតទូទៅប៉ុណ្ណោះ ពុំចាំបាច់ទាល់តែមានន័យថាផលិតនៅភ្នំគូលែនឡើយ។

ចាប់ពីជំនាន់នោះមក កុលាលភាជន៍ដែលមានស្រទាប់រលោងនេះ ច្រើនតែឃើញមានសញ្ញានៅគូថ ដែលគេគូសចូតមុននឹងយកទៅដុត។ ជាទូទៅ សញ្ញានោះជាឆ្នូតផ្សេងៗកាត់ខ្វែងគ្នា រីស័យដូចលេខរ៉ូម៉ាំង ឬមួយមានលំនាំគំនូរធរណីមាត្រក៏ថាបាន *(មើលរូបលេខ៣ និង១៥)*[១៣]។

សញ្ញាទាំងនេះ យូរៗឃើញមានម្ដងនៅលើក្បឿង ហើយក្រោយមកនៅលើចានក្បានដែលមានស្រទាប់រលោងពណ៌ត្នោត។ ថ្វីត្បិតតែយើងខំប្រមូលសញ្ញារបៀបនេះបានចំនួន៦៥ខុសៗគ្នាមកប្រៀបធៀបសិក្សា ក៏យើងនៅតែរកពុំទាន់ឃើញទំនាក់ទំនងជាមួយរូបរាងវត្ថុ, ស្រទាប់រលោង, ឬកាលបរិច្ឆេទនៃពេលផលិតនោះសោះ។ ដើម្បីរកទំនាក់ទំនងអ្វីមួយឃើញ លុះត្រាតែបានសិក្សាឡផលិតផ្ទាល់។

យោងទៅតាមផលិតផលខ្មែរ ដែលពុំទាន់មានលក្ខណៈឧស្សាហកម្មពេញលេញនៅឡើយ ហើយតាមសិលាចារិកដែលអាចឲ្យយើងធ្វើការស្មានបន្តិចបន្តួចផង មើលទៅហាក់ដូចជាមានភូមិខ្លះដែលទទួលងារធ្វើវត្ថុប្រភេទណាមួយ ហើយត្រូវប្រគល់ឲ្យអាជ្ញាធរ តាមវេនខ្លួន ក្នុងចំនួនណាមួយ ដើម្បីចែកចាយត។ គិតមើលទៅ ប្រហែលជាសញ្ញាអស់នោះ គេគូសចូតមុននឹងយកកុលាលភាជន៍ទៅបញ្ចូលក្នុងឡ ដើម្បីជាទីចំណាំរបស់ក្រុមស្មូន ឬភូមិស្មូន ប្រយោជន៍ឲ្យងាយរាប់គិតចំនួន ក្រោយពេលយកចេញពីឡមកវិញ។ ប្រសិនបើដូច្នោះមែន ក្រុមឡទាំងឡាយផលិតវត្ថុខុសៗគ្នា ហើយធ្វើការដាច់មុខងារពីគ្នា។

## វ័យកុមារនៃកុលាលភាជន៍មានស្រទាប់រលោង និងរលោងភ្លឺចាំង

ជំនាន់ព្រះបាទយសោវរ្ម័ន *(៨៨៩_រវាង៩១០)* ក៏ដូចជំនាន់ព្រះបាទឥន្ទ្រវរ្ម័នដែរ យើងឃើញកុលាលភាជន៍ប្រភេទដូចគ្នា (មើលរូបលេខ១៣)។ តាមពិតទៅ ទាល់តែដល់រាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន *(៩៤៤_៩៦៨)* ទើបវចនាបថដូរ ហើយពុំវិវឌ្ឍន៍ទៅណាទេ រហូតដល់ចុងរាជ្យព្រះបាទជ័យវរ្ម័នទី៥ *(៩៦៨_១០០១)*។ ការប្ដូររាជធានីទៅកោះកេរ្ដិ៍មួយភ្លែតនៅចន្លោះឆ្នាំ ៩២៨ និង ៩៤៤ ប្រហែលជាមូលហេតុនៃការទ្រឹងមួយស្របក់នោះ។

---

១៣ *Legend*, no. 59, បង្ហាញរូបមួយពីជំនាន់ពាក់កណ្ដាលស.វ.ទី១១ ដែលមាន 'ចារិកមើលមិនដាច់' នៅបាត។ តាមពិតទៅគ្មានចារិកអក្សរខ្មែរឬមនអ្វីទេ គឺគ្រាន់តែជាគំនូសខ្វែងគ្នាតែប៉ុណ្ណោះ។ នៅអង្គរ យើងបានប្រទះឃើញឧទាហរណ៍តែមួយគត់នៃអក្សរចារិកលើកុលាលភាជន៍។ ពាក្យនោះគឺ 'តេជសិ' –ដែលមានន័យថា 'មុត, ចិញ្ចាច' ពោលគឺ 'អនុភាពសក្ដិសិទ្ធិ'– ដែលចារលើខ្នងព្រះបដិមាមួយ ដុតមានស្រទាប់រលោង ជំនាន់ពាក់កណ្ដាលស.វ.ទី១១ *(ករណីយ៍នេះ កម្រមានណាស់)*។

យ៉ាងណាក៏ដោយ នៅពាក់កណ្ដាលទី២ នៃស.វ.ទី១០ មានរបស់របរចិនជំនាន់ Song ដែលផលិតនៅតំបន់ឡ Yue និង Ting –ហើយជាពិសេសសេឡាដុន– ហូរចូលមកអង្គរសន្ធឹកសន្ធាប់ណាស់។ ក្នុងនោះ ពពួក Ying-qing ចេញមុខជាងគេ។ គួរបញ្ជាក់ថា គេបានរកឃើញ បំណែកកុលាលភាជន៍មកពីតំបន់ឡ Jun និង Guan, បន្តិចបន្តួចមកពីក្រុមឡ Jizhou ឬ Jian-yao។ បើមកពី Cizhou គឺគ្មានទេ។ កុលាលភាជន៍លាបពណ៌ ឬគូរក្បាច់លំអពណ៌ ឬមួយទៀតដែលមានស្រទាប់រលោងស្រអាប់ដូចសំណរក៏គ្មានដែរ។

កុលាលភាជន៍ដែលនាំចូលមក មិនមានច្រើនប្រភេទណាស់ណាទេ។ ក្នុងនោះភាជន៍តូចៗនិងភាជន៍មានគម្របមានប្រមាណ ៣០%។ ឯ ៧០%ទៀត គឺចាន, ពែង, គោម, គោមមានគម្រប សារុបមកគឺចានក្បានម្ហូបអាហារ។ យូរៗម្ដង គេប្រទះឃើញក្រឡ mei ping ឬប្រភេទក្អមម្យ៉ាង។ នេះមិននិយាយអំពីក្អមក្រឡ ឬក្អមពាង –មានស្រទាប់រលោង ឬគ្មានក៏ដោយ– ដែលចិនផលិតសម្រាប់ផ្ទុកទំនិញផ្សេងៗនាំចូលមក។ នេះហើយដែលគេតែងស្គាល់ថាជាកុលាលភាជន៍ពណ៌ត្នោតនៃហ្វីលីពីន ហើយដែលគេតែងប្រទះនៅកន្លែងនានានៃអាស៊ីអាគ្នេយ៍។ ខ្មែរហាក់ដូចជាចូលចិត្តភាជន៍នេះណាស់។ គេទុកប្រើប្រាស់ ក្រោយពីប្រើទំនិញខាងក្នុងនោះអស់។ ចាប់ពីចុងស.វ.ទី១០មក គេក៏ចម្លងធ្វើតាម (ប៉ុន្តែមិនងាយដែលឃើញមានត្រចៀកនៅក្អេងទេ)។

ពិនិត្យយូរទៅ ឃើញច្បាស់ថា ចាប់តាំងពីខ្មែរនាំកុលាលភាជន៍ចិនជាច្រើនចូលមក –ដោយជ្រើសរើសរាងរៅតាមចំណូលចិត្តរបស់ខ្លួន– ផលិតផលក្នុងស្រុកក៏ចុះថយ រួមមកនៅតែប្រភេទមួយចំនួនតូចប៉ុណ្ណោះ។ យូរៗទៅ គេក៏ឈប់ផលិតក្អមភាជន៍មានគម្រប ត្បិតគេយកភាជន៍ Ying-qing ដែលមានរូបរាងប្រហាក់ប្រហែលគ្នាមកជំនួស ដោយសារគេនិយមជាង។ ខ្មែរលែងធ្វើគោម –ចំណុចនេះច្បាស់ណាស់នៅអង្គរ– ព្រមទាំងលែងព្យាយាមធ្វើចានឬពែងទៀត ព្រោះឃើញថាសេឡាដុននាំចូលមកស្រាប់ៗ ល្អជាងនោះឆ្ងាយ។

ប៉ុន្តែកត្តានោះក៏នាំឱ្យគេខំបង្កើតរូបរាងពិសេសរបស់ខ្លួនដែរ។ ដូច្នេះឥទ្ធិពលចិនមានទិដ្ឋភាពពីរ។ ម្យ៉ាងអវិជ្ជមាន គឺបញ្ឈប់ការផលិតក្នុងស្រុកខ្លះ។ ម្យ៉ាងទៀតវិជ្ជមាន ដោយសារនាំចូលមកនូវគម្រូល្អៗ ព្រមទាំងបច្ចេកទេសថ្មីផង។ ក្នុងន័យនេះ កុលាលភាជន៍អង្គរដែលប្រកបដោយស្រទាប់រលោង និងទំនិញនាំចូលមកពីចិន ជួយបង្គ្រប់គ្នាទៅវិញទៅមក។

បើយោងតាមចំនួនវត្ថុបានពីធ្វើកំណាយ ឃើញថាគេនិយមកុលាលភាជន៍ចិនជាពន់ពេក។ ចាប់តាំងពីពាក់កណ្ដាលស.វ.ទី១០មក នៅក្នុងព្រះរាជវាំងអង្គរធំ គេប្រើប្រាស់ចានក្បានចិនច្រើនជាងភាជន៍ប្រកបដោយស្រទាប់រលោង ដែលផលិតក្នុងស្រុក។ គួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ចំពោះរឿងនេះ ព្រោះសិលាចារិកក៏ស្រាប់តែផ្ដល់ពត៌មានត្រូវគ្នាដែរ។ សិលាចារិកនៅព្រះឥន្ទកោសីយ៍ ដែលជាប្រាសាទតូចមួយនៅអង្គរ (គ.ស. ៩៦៨_៩៨៤) និយាយថា នៅព្រះឃ្លាំង គេមានទុក "នោងចិនបី"[១៨]។ ពាក្យ "នោង" បាត់ពីភាសាខ្មែរហើយ ប៉ុន្តែគេឃើញនៅក្នុងភាសាមនថា "នុង" នៅក្នុងសិលាចារិក ស.វ.ទី១១ និង ទី១៣ ហើយសំដៅលើភាជន៍ដាក់វត្ថុរាវ ឬសម្រាប់ផឹក ឬម្យ៉ាងទៀតសំដៅពែងដែលមានជើងដែរ (ដែលអាចធ្វើពីលោហធាតុផង)[១៩]។ ចាប់អំពីនោះមក នៅអង្គរ ចានក្បានចិនដែលមានតម្លៃ គេទិញយកមកប្រើប្រាស់នៅតាមប្រាសាទនិងនៅវាំង។

ផលិតផលខ្មែររីកចម្រើនខ្លាំងណាស់នៅពាក់កណ្ដាលទី២ នៃស.វ.ទី១០ ដូចបានពោលពីលើមក។ ស្រទាប់រលោងពណ៌តែបៃតងដែលដំបូងឡើងចម្លងតាមផលិតផលឡ Yue កាន់តែស្ដើងទៅៗ, ចេញស្នាមស្រាំ, ហើយច្រើនតែប្រែពណ៌ទៅរកលឿងចម្បើង នៅលើដីឥដ្ឋពណ៌សដែលធ្លាប់ប្រើតាំងតែពីជំនាន់មុនៗមក។ គេចាប់ផ្ដើមប្រើដីឥដ្ឋប្រភេទថ្មីមួយ។ ដីនោះទន់ជ្រាយ តែហាប់ស្មើ ដូច្នេះគេសំអាតព្រមទាំងបោកប្រចាច់បានល្អធ្វើឱ្យមានភាពមាំ។ ឥតមានរន្ធតូចៗដូចពីមុនទៀតទេ។ ពេលដុតទៅ ដីនោះប្រែពណ៌ទៅជាប្រផេះ ឥតមានក្រមៅៗនៅផ្នែកខាងក្នុងឡើយ មើលទៅឃើញច្បាស់ថា គេចង់ចម្លងតាមសេឡាដុន។ ផែនទីភូគព្ភសាស្ត្រកម្ពុជា បង្ហាញថាមានដីឥដ្ឋប្រភេទ kaolin នៅតំបន់កំពង់ឆ្នាំង ប៉ុន្តែយើងមិនដឹងថានៅជំនាន់នោះគេស្គាល់ឬអត់។ យ៉ាងណាក៏មិនដែលឃើញខ្មែរព្យាយាមចម្លងវត្ថុមកពីក្រុមឡ Ting ឬព័រស៊ីឡែនសោះ។

---

[១៨] K.212, N, 15 និង K.263, D, 47: G. Cœdès: *Inscriptions du Cambodge,* vol. IV, p. 108. (Paris, EFEO, 1952)។

[១៩] H.L. Shorto, *A Dictionary of the Mon Inscription* (London: Oxford University Press, 1971) p. 215។ ឈ្មោះភាជន៍ដែលពោលខាងលើ អាចនឹងមាននៅក្នុងសិលាចារឹកភាសាសំស្ក្រិតនៃប្រទេសកម្ពុជា ជួនកាលមាននៅសិលាចារិកភាសាខ្មែរផង។ ប៉ុន្តែពាក្យសំស្ក្រិតដែលដើមឡើយ សំដៅវត្ថុមួយនៅឥណ្ឌា ពុំមែនមានន័យថានៅស្រុកខ្មែរ សំដៅលើវត្ថុដែលមានរូបរាង ឬរបៀបធ្វើដូចគ្នាឡើយ។ ម្យ៉ាងទៀត យើងមានប្រទះពាក្យខ្មែរបុរាណខ្លះ ពាក់ព័ន្ធនឹងកុលាលភាជន៍ដែរ តែពាក្យនោះបាត់ពីភាសាខ្មែរបច្ចុប្បន្នហើយ។ ប្រសិនបើមានការសិក្សាប្រៀបធៀបជិតដល់រវាងពាក្យមន, ពាក្យមន–ខ្មែរ, ពាក្យខ្មែរកណ្ដាល ប្រហែលអាចដេញរកន័យពាក្យទាំងនោះឃើញ។ តែទោះជាដូច្នោះក៏ដោយ ក៏យើងពុំអាចដាក់ថាពាក្យមួយសំដៅលើភាជន៍ខ្មែរណាមួយប្រាកដបានដែរ។ ណាមួយទៀត បើសិលាចារិកពុំបញ្ជាក់ទេ យើងពុំអាចដឹងបានថាភាជន៍នោះជាលោហធាតុ ឬធ្វើពីដីឥដ្ឋ ឬមួយក៏អាចសំដៅលើវត្ថុធាតុទាំងពីរបាន។

ដីឥដ្ឋប្រផេះនេះ ធ្វើឱ្យស្រទាប់រលោងឡើងក្រាសជាងមុន, រលីងជាងព្រមទាំងស្អិតល្អ។ ស្រទាប់នោះឡើងពណ៌កាគីបៃតង ឬពណ៌ផ្លែម្កុតតែស្រអាប់បន្តិច ពុំគួរឱ្យទាក់ភ្នែកប៉ុន្មានឡើយ។ ឯគ្រឿងក្នុងសម័យជាមួយគ្នានោះ ប្រើបច្ចេកទេសខ្ពស់ណាស់។ ស្រទាប់រលោងនៅតែរក្សាពណ៌ពងមាន់ ឬលឿងទឹកឃ្មុំ។ នេះមកពីដីឥដ្ឋដែលយកមកប្រើ ប្រកបដោយពណ៌ផ្កាឈូកព្រមទាំងមានភាពជ្រាយជាង។

ចាប់ពីចុងស.វ.ទី៩មក ក្នុងពពួកភាជន៍ដែលមានស្រទាប់រលោង "គូលែន" ហើយដែលដុតឡើងដោយប្រើដីឥដ្ឋពីរយ៉ាង –សនិងប្រផេះ– យើងឃើញមាន៖

តន្លាប់ និងភាជន៍មានគម្រប, ខួចដែលចម្លងតាមដប hu[២០], ដបខ្លះដែលមានជើងខ្លី, ខ្លួនរាងសាជីកាត់ចុង ព្រមទាំងចោំងត្រង់ក្អេងបន្តិច, ជួនកាលហាក់ដូចជារួញចុះក្រោមដោយសារទម្ងន់ (តាមពិត កនោះតូចចង្អៀត ហើយគ្មានរីកមាត់ចេញទេ)។ ជួនកាលលើខ្លួនមានឆ្នូតក្បាច់ត្របកឈូក (មើលរូបលេខ១៣)។ ដបខួចទាំងនេះ គេឃើញមានតាំងពីនៅសម្បូណ៌ព្រៃគុក ហើយតាំងពីជំនាន់នោះមកម្ល៉េះ ដែលមានក្អេង "រួញចុះក្រោម" ដូច្នោះ។ ឥទ្ធិពលចិន មើលឃើញច្បាស់នៅទីនេះ ជាពិសេសចំពោះក្បាច់នៅប៉ែកខ្លួនខាងក្រោម។ ក្នុងពពួកនេះ គេអាចរាប់បញ្ចូលនូវភាជន៍តូចរាងមូល, មានគម្រប (១០ស.ម.-១២ស.ម.), ជួនកាលមានឆ្នូតលំអនៅក្រោមស្រទាប់រលោង (មើលរូបលេខ១៥)។ នៅទីនេះក៏ឃើញឥទ្ធិពលចិនច្បាស់ដូចគ្នា។

ក្រៅអំពីនោះ គេមានផលិតភាជន៍ធំៗច្រើន។ ស្រទាប់រលោងមានភាពភ្លឺខ្លាំង ដែលជាលក្ខណៈសម្គាល់មួយនៃសម័យនោះ ព្រោះជាការបង្កើតថ្មី។ គួចវាជារមូដីឥដ្ឋមួយដុំ ឬមួយជាបំពង់ដីឥដ្ឋតាន់មួយកំណាត់ខ្លី។ តួខ្លួនធ្វើជាចង្វាយដីវាន់ត្រួតលើគ្នាសិន។ ជុំវិញខ្លួនខាងក្រៅ គេរំលីងស្មើល្អណាស់។ នៅខាងក្នុងគ្រាតគ្រើមជាងនោះ ហើយគេអាចឃើញស្នាមដូចខ្សែវាន់ ដោយសារប្រើបច្ចេកទេសថ្មីនេះ។ ភាពសំអិតសំអាងបង្អើយ, រូបរាងសមសួន, និងជាពិសេសស្នាមខ្សែលួសកាត់គូថឱ្យដាច់ចេញពីទម្រ... ទាំងអស់នេះធ្វើឱ្យដឹងថាគេប្រើកង់វិល។ ប៉ុន្តែពុំមែនជាកង់វិលដោយជើងធាក់ ឬដោយប្រើខ្សែដូចនៅស្រុកចិនទេ ប្រហែលគ្រាន់តែជាកង់បង្វិលដើម្បីឱ្យបន្ទះទ្រនោះវិល ងាយស្រួលស្មូនធ្វើការ។ រីឯវិធីដែលយករមូចង្វាយដីមករៀបជាការចម្លែក ត្បិតចានក្បានដីដុតធម្មតា គេតែងធ្វើដោយយកបន្ទះក្តារមកវាយដី ទោះជាភាជន៍ធំៗនៅជំនាន់នោះ ជាពិសេសជើងក៏ធ្វើដោយបច្ចេកទេសបន្ទះក្តារដែរ។ ហេតុនោះហើយបានជាគេឃើញដីមានរន្ធ ព្រមទាំងស្នាមប្រេះសំប៉ែតខ្លះដែលកើតឡើងដោយសារខ្យល់ចេញអស់នៅពេលដុត ព្រោះរន្ធនិងប្រឡោះខ្យល់ទាំងនោះ កើតឡើងដោយសារគេយកដីមកបិទលើគ្នា, ជាស្រទាប់ៗដើម្បីឱ្យបានកម្រាសក្រាស។

គេយកដីឥដ្ឋមកពង្រឹងជាមួយវត្ថុធាតុដូចជាខ្សាច់ថ្លាចាំង ប៉ុន្តែមិនសំអាតឱ្យបានហ្មត់ចត់ទេ ព្រោះជួនកាលឃើញមានដល់ទៅគ្រាប់គ្រួសតូចៗទៀតផង។ នៅពេលដុត ឧស្ម័នផ្តុំគ្នាដើម្បីរកកន្លែងចេញ ជួនកាលធ្វើឱ្យបែកចេញនៅផ្ទៃលើ។ ពណ៌ដីនោះប្រែពីប្រផេះទៅដល់ខ្មៅ ឯផ្នែកខាងក្នុងតែងតែក្រមៅជាងខាងក្រៅ។ កុលាលភាជន៍ក្រុមនេះស្ទើរតែទាំងអស់ មុននឹងដុតគេតែងតែលាបទឹកថ្នាំមួយស្រទាប់យ៉ាងស្តើង[២១] ស្ទើរតែមើលពុំឃើញ។ ក្នុងនោះប្រហែលមានជាតិដែកច្រេះខ្លះ ព្រមទាំងផេះឈើដែលធ្វើឱ្យមានភាពចាំង ក្រោយពីដុតរួច។ ក្រោយពេលដុត ពណ៌ប្រែទៅជាត្នោតស្រដៀងស្លាន់, ជួនទៅជាក្រហមដាំ, ជាពិសេសទៅជាពណ៌ម្យ៉ាងដូច lie-de-vin* (យ៉ាងហោចណាស់ ជនជាតិបារាំងមើលឃើញបែបនេះ)។ ខ្ញុំនឹងប្រើពាក្យឱ្យឈ្មោះនេះ អំណើះតទៅ។ កំដៅភ្លើងមានកំពស់លើសពីមុន ប៉ុន្តែស្មូនពុំទាន់ប៉ិនប្រសប់ខ្លាំងក្នុងការគ្រប់គ្រងកំដៅនោះទេ។ គេសង្កេតឃើញជារឿយៗថា ភ្លើងមិនស្មើ ត្បិតខ្លួនភាជន៍ម្ខាងច្រើនតែឆ្អិនលើសម្ខាងទៀត ជាហេតុធ្វើឱ្យយើងជឿថា គេដុតនៅក្នុងរណ្តៅ ពោលគឺមិនទាន់ប្រើឡនៅឡើយ។ បើទោះជាប្រើឡ ក៏ឡនោះមិនទាន់អាចផ្តល់ប្រសិទ្ធិភាពបានពេញលេញ។ ក្នុងសម័យជាមួយគ្នានោះ ចានក្បានដីដុតធម្មតា គេដុតបានល្អជាងមុន ដោយប្រើប្រភេទដីដូចគ្នានឹងសតវត្សមុនៗដែរ។ យើងដឹងថាគេប្រើកំដៅខ្លាំងជាងមុន ដោយឃើញថាពណ៌ប្រែទៅជាផ្កាឈូកឬលឿងមិនមែនទៅជាប្រផេះក្រមៅដូចពីដើមទៀតទេ។ មើលទៅប្រហែលជាគេប្រើអង្កាមសម្រាប់ពង្រឹងដែរ ត្បិតមានចំណុចខ្មៅៗតូចនៅក្នុងសាច់ដី។

ក្នុងពពួកវត្ថុដែលមានស្រទាប់ lie-de-vin គេឃើញមានក្រឡតូចៗនិងវត្ថុពីរថ្មីទៀត។ ទីមួយគឺភាជន៍ធំៗ (កំពស់ ៣០ស.ម.-

---

[២០] ចំពោះគម្រូចិន សូមមើល *Trade*, p. 65, n. 20។

[២១] ប្រហែលជាខ្ញុំធ្លាប់បរិយាយមិនច្បាស់លាស់ ហើយធ្វើឱ្យអ្នកស្រី R.M. Brown (*Ceramics*, p. 38) យល់ថាស្រទាប់រលោង lie-de-vin កើតឡើងដោយសារតែការដុតប៉ុណ្ណោះ។ តាមពិត យើងពិនិត្យឃើញស្ទើរតែរាល់ពេល ថាមានទឹកថ្នាំរាវដែលគេលាបឬជ្រលក់មុននឹងដុត។ បើទៅក្នុងអត្ថបទ "Khmer Ceramics", *Arts of Asia*, May-June, 1973 (Hong Kong), p. 33 នោះវិញ ទើបការសន្និដ្ឋានរបស់អ្នកស្រី Brown ត្រូវនឹងការពិតជាង។

* ពាក្យថា lie-de-vin គឺជាកំណកស្រាទំពាំងបាយជូរក្រហម ដែលជួនកាលមានរងនៅបាតដប។

*៥០ស.ម., ទទឹងវង្វះមាត់ ៦០ស.ម.-៨០ស.ម.)* លំនាំប្រហែលរណ្ដៅក្រិច ប៉ុន្តែយើងមិនដឹងថាគេប្រើធ្វើអ្វីទេ[៦៦]។ ភាជន៍ធំប្រភេទជើងនេះ មានធ្វើពីដីដុតធម្មតាតាំងពីស.វ.ទី៧ម្ល៉េះ។ យើងសង្កេតឃើញថា ក្រោយពីស.វ.ទី១០មក គេឈប់ផលិតទៀតហើយ ដោយគេប្រើជើងឬខ្ទះធ្វើអំពីស្ពាន់លឿងជំនួសវិញដែលត្រូវនឹងទំហំធំបែបនេះដាង។ យើងអាចមើលឃើញនៅផ្ទាំងចម្លាក់ប្រាសាទបាយ័ន្ត *(មើលរូបលេខក១និងក២)*។

ម្យ៉ាងទៀតយើងឃើញមានក្រឡពាងដែលមានគូថកាត់ស្មើ, ខ្លួនរាងដូចសាជីកាត់ចុង, ក្អេងរាងក្រឡុំ, កជំតែខ្លី, មាត់រីកសាយផ្ដេកស្មើទៅក្រៅ[៦៣]។ ប្រហែលជាគេប្រើសម្រាប់បិតស្រាព្រមទាំងដាក់ស្រាដែលគេបឺតទទួលទានតាមកូនបំពង់ពក។ ក្រៅពីនេះ គេឃើញមានដបដែលមានកតូច *(មាត់កំបុតមិនរីកសាយទេ)*, ចាន់ដែលមានចំពួយខ្លី, ព្រមទាំងភាជន៍តូចៗដាក់វត្ថុរាវ, ដែលមានខ្លួនរាងសាជីកាត់ដូចគ្នា *(កវាធំគ្រាន់បើ ឯមាត់រីកខ្លាំងទៅក្រៅ)*។

*របស់ទាំងប៉ុន្មាននេះគ្មានក្បាច់លំអអ្វីទាំងអស់ ក្រៅអំពីក្រឡស្រាដែលមានថ្នូតពីរបីព្រមទាំងក្បាច់ខ្សែវែងស្ដើងសើៗមួយបន្ទះ។* នៅកន្លែងតំណកាច់បត់និមួយៗ *(ពីកមកក្អេង, ពីក្អេងមកតួខ្លួន)* –លើកលែងតែតំណជើង– តែងមានកន្ទួលពកជាខ្សែមួយជុំអមទៅដោយខ្សែចង្អូរថ្មារពីរសង្ខាង។ លក្ខណៈពិសេសមួយនៃវត្ថុជំនាន់នេះ គឺមាត់រីកសាយនៃក្រឡស្រាធំៗឬមាត់ថូដាក់វត្ថុរាវដែលមានរាងជើងទៀន ច្រើនតែលំអទៅដោយល្បាក់បញ្ឈរមួយជុំ ហើយចុះមកវិញនៅជុំវិញចុងបបូរមានល្បាក់ផ្ដេកពីរខ្សែ ដែលមានចង្អូរនៅកណ្ដាល។

## វ៉ៃយជិទង់

*ពាក់កណ្ដាលទីមួយនៃស.វ.ទី១១ ដែលត្រូវនឹងរាជ្យយ៉ាងវែងនៃព្រះបាទសូរ្យវរ្ម័នទី១ (១០០២-១០៥០)* គឺជារយៈពេលដែលកុលាលភាជន៍ប្រកបដោយស្រទាប់រលោងក្លាយទៅជាសិល្បៈរបស់ខ្មែរផ្ទាល់។ ពិតមែនហើយ ឥទ្ធិពលចិននៅតែមានខ្លះ ដូចមានរបស់ចិននាំចូលព្រមទាំងរបស់ខ្មែរចម្លងតាមចិនជាតឹកតាងស្រាប់។ គេពុំដឹងថាមានស្មូនចិនប្រកបអាជីពទៀតឬអត់។ ប៉ុន្តែនៅពាក់កណ្ដាលទី២នៃសតវត្សដដែលនោះ ថ្វីត្បិតតែគេនៅតែនាំរបស់ចិនចូល *(ថែមទាំងច្រើនលើសមុនទៀតផង)* ក៏ឥទ្ធិពលចិនលើផលិតផលខ្មែរកាន់តែអន់ថយខ្លាំង ហើយទីបញ្ចប់ក៏បាត់សូន្យទៅ។

ចាប់ពីនោះមក កុលាលភាជន៍មានស្រទាប់រលោងប្រភេទ 'គូលែន' ស្ទើរតែទាំងអស់ ធ្វើពីដីឥដ្ឋពណ៌ប្រផេះ, សាច់ស្អាតម៉ត់ ហើយរឹងល្អ *(មើលរូបលេខ៥០គ)*។ របស់មានស្រទាប់រលោង lie-de-vin លែងឃើញមានទៀតហើយ។ យើងអាចជឿបានថា ស្រទាប់រលោងពណ៌ត្នោត ដែលវិវត្តន៍មកពី lie-de-vin នោះ ចាប់កំណើតឡើងនៅចុងស.វ.ទី១០ ប៉ុន្តែភស្តុតាងពុំទាន់មានគ្រប់គ្រាន់ទេ។ តែយ៉ាងណាក៏ស្រទាប់រលោងពណ៌ត្នោតនោះ កាន់តែរីកចម្រើនសម្បូណ៌រហូតដល់ក្លាយទៅជាផលិតផលដែលគេស្គាល់ជាងគេទាំងអស់នៅអង្គរ។ គ្មានអ្វីនឹងឱ្យសង្ស័យឡើយថា ស្រទាប់រលោងពណ៌ត្នោត (ដែលចេញពីជាតិច្រេះដែក)នេះ ជាលទ្ធផលនៃការខំចម្លងតាមក្រឡពាងដាក់ទំនិញនាំចូលមកពីស្រុកចិន ព្រមទាំងកុលាលភាជន៍ចិននៃចុងស.វ.ទី១០ *(ឧទាហរណ៍៖ កុលាលភាជន៍ប្រភេទ Ch'ang-sha)*។ លើកនេះ ដីឥដ្ឋសំអាតបានល្អជាងមុន, ឥតមានគ្រួសទេ, ព្រមទាំងពង្រឹងជាមួយខ្សាច់ចាំងផង។ ដូច្នោះដុតទៅមិនប្រេះឬបង្កើតស្នាមដោយសារខ្យល់ចេញទៀតទេ។ ដីនោះពណ៌ប្រផេះខ្ចី, សាច់ខាងក្នុងទើបក្រមៅបន្តិច, មានភាពរឹង គោះទៅឱ្យសូរច្បាស់មកវិញ។ ភាជន៍ធំៗតែងតែតម្លើងដោយរមូរដីវាន់រួចទើបគេលាបទឹកថ្នាំរលោង (ប្រហែលគេប្រើដក់អ្វីមួយសម្រាប់លាប)។ ដុតទៅឡើងពណ៌ដីច្រេះ។ ស្រទាប់រលោងនោះក្រាស មានស្នាមហូរចុះមកក្រោម បត់រមួលៗ។ ពេលដុត ពណ៌ដូរទៅជាត្នោតក្រមៅ រហូតដល់ពណ៌ត្នោតដាំជាងនោះទៅទៀត។ ក្រៅពីនោះ អាចទៅជាបៃតងដាំ *(មើលរូបលេខ១១កនិង៤៣)* ឬយូរៗម្ដងទៅជាពណ៌លឿងដាំដូចស្ពាន់ធ័រ។ ចំពោះភាជន៍តូចៗវិញ –ឧទាហរណ៍ កូនក្រឡសំប៉ែតដែលសម្បូណ៌នៅជំនាន់នោះ– ទឹកថ្នាំក្រាសជាង ហើយស្រទាប់រលោងដែលចេញមកដូចជាពុំជាប់ល្អទេ មើលទៅមានអារម្មណ៍ថាជា 'តំណក់ប្រេង' ហើយប្រែទៅរកពណ៌ឈាមស្ងួត *(មើលរូបលេខ៥៤)*។ ស្នាមភ្លើងដែលខ្លោចដោយអន្ទើ លែងឃើញមានទៀតហើយ ធ្វើឱ្យយើងសន្និដ្ឋានថា វត្ថុធំៗដុតនៅក្នុងឡ។ ប៉ុន្តែគប្បីបញ្ជាក់ដែរថា ស្មូនខ្មែរពេលនោះ ពុំទាន់គ្រប់

[៦៦] *Ceramics,* pl. 21, no. 70។

[៦៣] *Ceramics,* pl. J, no. 1។

គ្រង់បច្ចេកទេសឡូបានទាំងស្រុងទេ ដូចយើងអាចសង្កេតលើភាពខុសគ្នានៃស្រទាប់រលោងខាងលើវត្ថុតែមួយ ពោលគឺផ្នែកម្ខាងនៃភាជន៍ ច្រើនតែដុតក្តៅជាងម្ខាងទៀត។ ស្រទាប់រលោងបៃតងប្រភេទ "គូលែន" ច្រើនឃើញនៅលើភាជន៍តូចៗ។ គេនៅតែប្រើដីឥដ្ឋពណ៌ស ប៉ុន្តែគេសំអិតសំអាងរើសយកដីជ្រាយស្មើ ព្រមទាំងជាប់មាំ។ ដូច្នោះហើយបានជាលែងឃើញមានរន្ធខ្យល់តូចៗទៀត។ ប្រហែលជាគេបានរកឃើញរ៉ែដីឥដ្ឋប្រភេទ kaolin ឬមួយក៏គេលាយដីឥដ្ឋសជាមួយនិងសមាសធាតុដែលមាន felspath ផងក៏មិនដឹង។ កាលបើលាបលើដីនេះហើយ ស្រទាប់រលោងឡើងពណ៌បៃតងខ្ចីជាទូទៅច្រើនតែក្រាសបន្តិចព្រមទាំងរលោងស្រអាប់ (មើលរូបលេខ៧)។ ប៉ុន្តែមានមួយក្រុមនោះ មានស្រទាប់ដែលពុំសូវរលោងប៉ុន្មានទេ គឺសាច់ស្មើ, ស្រអាប់, ជួនកាលពណ៌កាគីបៃតងខ្ចី ដែលខ្ញុំយល់ថាជាការខំចម្លងតាមសេឡាដុន តែដែលពុំបានលទ្ធផលប្រសើរ។ ស្រទាប់នោះជាប់ស្អិតល្អណាស់ជាមួយតួវត្ថុ ហើយពុំដែលប្រេះស្រាំទេ ប៉ុន្តែចាប់ពីពាក់កណ្តាលសតវត្សនោះទៅ លែងឃើញមានទៀត។

រូបរាងភាជន៍កាន់តែមានច្រើនបែបយ៉ាង រីឯថូដែលមានរាងជើងទៀតក៏លេចចេញឡើងពេលនោះ។ ភាជន៍ខ្លះធំ, ជើងរាងដូចបំពង់, ខ្លួនប៉ោង, កវែង។ ជារឿយៗ តែងឃើញមាត់រីកសាយផ្តេកទៅក្រៅ (មើលរូបលេខ១៤៣)។ តាមពិតទៅវត្ថុនោះចុះតំណត្រង់មកតាំងពីស.វ.ទី៧ម្ល៉េះ ដោយទទួលការវិវត្តន៍ផ្សេងៗ។ ប៉ុន្តែមកដល់សម័យនោះ លែងវិវត្តន៍ទៅណាទៀតហើយ៖ គេសម្គាល់ថាមានលក្ខណៈខ្មែរសុទ្ធ។ មើលទៅ ច្បាស់ជាគេប្រើសម្រាប់ដាក់និងចាក់ទឹក។ ជួនកាលមានចំពួយខ្លីមួយផង តែពុំដែលមានដៃសម្រាប់កាន់ទេ។ បើថូស្រា គឺសម្បូណ៌ជាងនោះ។ ជួនកាលមានផ្ទាំងមួយខ្សែ ដែលមានក្បាច់ឆ្នូតខ្វែងគ្នា ឬមួយជាក្បាច់រលកនៅលើក្អេង (មើលរូបលេខ១៤៣)។ គេក៏ប្រទះឃើញដៃរនូវក្រឡធំៗសម្រាប់ដាក់ធញ្ញជាតិ។ ជួនកាលឃើញមានថូដែលមានខ្លួនប៉ោងគន្លាក់ៗ។ មាត់វារីកសាយ ហើយស្រទាប់លើពណ៌បៃតងមិនរលោងពេកទេ។ ពពួកនេះគេផលិតឡើងដោយចម្លងតាមចិន[២៤]។

ក្នុងពពួកភាជន៍ដែលមានស្រទាប់រលោង "គូលែន" ប្រអប់តូចៗមូលសំប៉ែត, មានគម្រប, លែងឃើញមានទៀតហើយ។ ឯចានគោមដែលមានរាងដូចសាជីកំបុត ឬមូលមួយកំណាត់, មានជើងសំប៉ែតមូលតូច, ស្រាប់តែឃើញសម្បូណ៌ឡើងវិញ។ ភាជន៍ប៉ោងមានគម្របក៏ឃើញមានច្រើនជាងមុនដែរ (មើលរូបលេខ១៥) ក្នុងនោះខ្លះមានឆ្នូតខ្សែបញ្ឈរឬមួយរាងត្រីកោណ ចុងចុះក្រោម។ ជាមួយគ្នានោះ យើងឃើញប្រអប់មូលរាងដូចផ្លែល្ពៅដែលគេចម្លងតាមគម្រូចិន[២៥] ហើយដែលយើងធ្លាប់ស្គាល់ច្បាស់។ រីឯខ្ទចតូចៗដាក់គ្រឿងក្រអូប ដែលមានរាងក្លាយពីខ្ទចចិន hu ក៏ឃើញញឹកញាប់ ប្រកបដោយឆ្នូតបញ្ឈរជាលំអផង[២៦]។ ជាទូទៅ ពពួកក្រុមនេះធ្វើពីដីឥដ្ឋពណ៌ស, រីឯ, ឯស្រទាប់រលោងមានតាំងពីពណ៌ចម្លើងលឿងខ្ចីប្រកបដោយស្នាមស្រាំច្រើន រហូតទៅដល់ពណ៌បៃតងខ្ចី។ គម្របថូច្រើនតែមានកំពោយកាន់ រាងដូចក្រពុំផ្កា ហើយហាក់ដូចជាវិវត្តន៍ទៅរករាងប៉ោង។ ខ្លះមានលំអក្បាច់ពករូបស្លឹកឈូក ជួនកាលរូបផ្លែឈូកដែលមានទងទៀតផង[២៧]។ កាលណាមានក្បាច់ដូច្នោះ ថូទាំងនោះតែងតែមានស្រទាប់រលោងពណ៌កាគីបៃតង, សាច់ស្រអាប់, ស្នាបទៅហាក់ដូចជាស្អិត។

ដូចនៅស.វ.ទី១០ដែរ ជាទូទៅក្បាច់លំអមិនច្រើនលើសអ្វីប៉ុន្មានពីក្បាច់ល្បាក់ខ្លះទេ។ ល្បាក់ទាំងនោះកាន់តែច្រើនទៅៗ ព្រមទាំងមានលំអានប្លែកៗ៖ ល្បាក់មូលពាក់កណ្តាល, ល្បាក់មូលមួយចែកជាបី (ស្រដៀងស្លឹកឈើខ្លះ) ដែលតែងតែមានចង្អូរអមសង្ខាង។ ល្បាក់ទាំងនោះតែងឃើញនៅមាត់ក្រឡធំៗ (មើលរូបលេខ១១ក)។ ជួនកាលទៀត នៅចុងក្អេង ត្រង់ចន្លោះឆ្នូតល្បាក់ថ្នារៗច្រើនខ្សែ ឃើញមានល្បាក់ធំមួយមានខ្សែបញ្ជិតៗកាត់ខ្វែងគ្នា, ឬមួយជារលកឆ្នូតវិស័យដូចសំបកខ្ចងសមុទ្រ (មើលរូបលេខ១៤៣)។ បើពុំដូច្នោះទេ អាចមានក្បាច់មូលដូចពងត្រីមួយជួររាយនៅឆ្នូតល្បាក់ថ្នារនោះ។

ប្រហែលនៅជំនាន់នោះហើយដែលចានក្បានមានលំអក្បាច់ពក ឬធ្វើជារូបសត្វ ចាប់កំណើតឡើង។ មុនដំបូង គឺជាភាជន៍មូលតូចដែលគេបន្ថែមក្បាច់មូលតូចៗពីរធ្វើជាភ្នែក, ក្បាច់ចេញស្រួចចុងធ្វើជាចំពុះ និងកន្ទុយ ដើម្បីបានជារូបសត្វស្លាប។ តើនេះជាសត្វមៀម ឬកូនមាន់? ក្នុងក្រុមដែលឃើញដំបូងនេះ យើងបានប្រទះដែរនូវភាជន៍ដែលមានរូបដំរី។ ដំរីនោះខ្លួនប៉ោង, ជើងបួនធំៗតែខ្លី, ក្បាលធ្វើជាចំជៀង (ប្រហែលជាចាក់ពុម្ពផង) រួចទើបយកមកតភ្ជាប់, កន្ទុយគឺគេលុញ, នៅលើខ្នង មានរង្វង់បើកតូចមួយ ប្រកបដោយគម្របរាងសាជី។ មួយចំនួនច្រើនមានសល់ស្នាម

[២៤] ឧទាហរណ៍ *Trade*, p. 217, no. 235។
[២៥] ឧទាហរណ៍ *Trade*, p. 217, no. 234។
[២៦] ឧទាហរណ៍ *Legend*, no. 65។
[២៧] ឧទាហរណ៍ *Southeast*, p. 33, no. 3។

កំបោរធ្វើឱ្យយើងដឹងថា ប្រើជាអកកំបោរសម្រាប់គ្រឿងស្លាម្លូ។ គេយកកំបោរចេញមកបៀកលើម្លូ ដោយប្រើចង្កឹះសំប៉ែតតូចមួយ។ ភាជន៍រូបសត្វស្ទើរតែទាំងអស់ ព្រមទាំងភាជន៍រូបដំរីដែលចាស់ជាងគេ តែងមានស្រទាប់បែតងពីលើ តែមិនរលោងភ្លឺទេ។

វត្ថុរូបរាងទាំងអស់នេះ ច្រើនតែឃើញនៅពាក់កណ្ដាលសតវត្សនោះ ដោយសារយើងស្គាល់ស្រទាប់ដីច្បាស់។ បើនៅចន្លោះឆ្នាំ ១០២៥ និងពាក់កណ្ដាលស.វ.ទី១១ យើងគ្មានទិន្នន័យច្បាស់លាស់ឡើយ។ ដូច្នេះខ្ញុំនឹងលើកយកតែពេលដែលវត្ថុទាំងនោះរីកចម្រើនខ្លាំងមកសិក្សា។

## រីកចម្រើន

ការខិតខំរិះរកបច្ចេកទេសនិងបង្កើតរាងថ្មីៗនេះ ចេញលទ្ធផលពេញបន្ទុកនៅវាងពាក់កណ្ដាលស.វ.ទី១១ បើពោលឱ្យច្បាស់ជាងនោះទៅទៀត គឺនៅរាជ្យព្រះបាទឧទ័យាទិត្យវរ្ម័នទី២ (គ.ស.១០៥០_១០៦៦)។ ពោលនេះគឺអះអាងទៅតាមស្រទាប់ដីដែលបានធ្វើកំណាយ។

ស្រទាប់រលោងពណ៌ត្នោត គេកាន់តែនិយម ឯទិដ្ឋភាពក៏មានច្រើនប្លែកៗគ្នា ទាំងពណ៌ផង ទាំងសាច់ស្រទាប់នោះផង។ ជាទូទៅ ដីឥដ្ឋសំអាតបានល្អជាងមុន ប្រកបដោយអង្កាមជាគ្រឿងពង្រឹង។ របស់ស្ទើរតែទាំងអស់ គេយកទៅជ្រលក់ក្នុងទឹកថ្នាំរាវ ដែលដុតទៅ ឡើងពណ៌ក្រហមស្រគាំ បែទៅរកពណ៌ត្នោត។ មានទឹកថ្នាំមួយបែបនោះ គេកាន់តែប្រើច្រើនឡើង។ ហើយប្រហែលជាមិនសូវមានផ្ទុកជាតិដែកច្រើនឡើយ។ ពេលដុតទៅ ប្រែពណ៌ទៅជាប្រផេះខ្ចី (មើលរូបលេខ២៤)។ ពណ៌ស្រទាប់រលោងមានពីត្នោតដាំ (មើលរូបលេខ២៤, ២៥ និង៤០ឃ) ដល់ត្នោតក្រមៅខ្លាំងអាស្រ័យទៅតាមកម្រាសរបស់ខ្លួន។ ស្រទាប់ម្យ៉ាងទៀតក្រាស ស្អាបទៅរអិលស្មើល្អណាស់ ប្រកបដោយពណ៌ត្នោតក្រមៅ ឬក៏ពណ៌ផ្លែម្កេញ គួរឱ្យគាប់ភ្នែក។ ស្នាមដាំតូចៗ ឬអាចម៍រុយពណ៌លឿងស្លាន់ធ័រ លែងឃើញមានទៀត។ ឯស្រទាប់រលោងដែលហូរចុះហើយផ្ដុំជា "តំណក់"ៗនោះ ក៏លែងមាននៅលើភាជន៍មូលសំប៉ែតទៀតដែរ។ ចំណែកស្រទាប់បែតង "គូលែន" វិញ តែងមានសោភណភាពណាស់៖ គឺជាស្រទាប់ក្រាស, ស្រអាប់ស្មើ, ពណ៌មានពីបៃតងខ្ចីទៅដល់ពងមាន់ (មើលរូបលេខ១៦) ហើយតែងមានស្នាមស្រាំសើៗ។

ក្នុងជំនាន់នេះហើយ ដែលចាប់ផ្ដើមមានចានក្បាន ប្រកបដោយ "ស្រទាប់រលោងពីរ" ឬយ៉ាងហោចណាស់ មានលំនាំពីរ៖ បៃតងខ្ចីនិងត្នោត។ ផ្នែកដែលពណ៌ខ្ចី ច្រើនតែជាបន្ទះឬផ្ទាំងខ្សែមួយពាត់ជុំវិញក្អេង ជាពិសេសនៅជុំវិញក (មើលរូបលេខ១១១, ១៧, ១៩ក និង១៩ខ)។

ពណ៌ទាំងពីរនោះ អាចជាស្រទាប់រលោងតែមួយទេ ដែលគេដុតតាមបច្ចេកទេស "បង្កើននិងបន្ថយអុកស៊ីហ្សែន"។ តាមការពិនិត្យលើភាជន៍ដែលគេចោលដោយដុតខូច គេដឹងថាវត្ថុដែលមាន "ស្រទាប់រលោងពីរ", ស្រទាប់គូលែន, និងស្រទាប់ពណ៌ត្នោត, គឺគេដុតនៅក្នុងឡជាមួយគ្នា។ បើពោលថាជាស្រទាប់រលោងពីរផ្សេងគ្នាក៏សឹងអាចថាបាន។ បំណែកខ្លះធ្វើឱ្យយើងដឹងថាស្រទាប់រលោងបៃតងចេញលើផ្ទៃដីឥដ្ឋសមួយបន្ទះដែលគេយកទៅបិទភ្ជាប់លើតួវត្ថុ។ ក្នុងករណីយ៍នេះ គែមលើក្រោមនៃបន្ទះដីឥដ្ឋដែលមានស្រទាប់រលោងពណ៌ខ្ចីនោះ មានទ្រនង់ពកមួយខ្សែអម។ ទោះបីជាមិនប្រើដីឥដ្ឋស ក៏គេនិយមធ្វើទ្រនង់ពីរខ្សែនោះដែរ។ តាមស្មាន ប្រហែលដើម្បីងាយស្រួលកំណត់ផ្ទៃសម្រាប់ស្រទាប់រលោងពណ៌បៃតងខ្ចីនោះ ព្រមទាំងការពារកុំឱ្យទឹកថ្នាំហូរដាមផង។ ប៉ុន្តែយើងមានឧទាហរណ៍ផ្សេងទៀតដែរ ដែលបង្ហាញថា គែមលើក្រោមនៃស្រទាប់រលោងបៃតងខ្ចីរលាយចូលទៅជាមួយព្រំនៃស្រទាប់រលោងពណ៌ត្នោត (មើលរូបលេខ១១១)។

ប្រព័ន្ធទាំងបីយ៉ាងនេះ ហាក់ដូចជាគេនិយមអនុវត្តន៍ដូចគ្នា។ ទាល់តែបានសិក្សានិងវិភាគឱ្យហ្មត់ចត់ជាងនេះ ទើបថ្ងៃក្រោយទៅយើងអាចយល់ច្បាស់បាន។ អ្នកស្រី Brown[២៨] យល់ថាបច្ចេកទេសនេះបែកចេញពីកុលាលភាជន៍ដែលមានដាំឬបញ្ចុះ ហើយដែលគេស្គាល់នៅវៀតណាម។ ប៉ុន្តែក្រៅអំពីបច្ចេកទេសដែលយកដីឥដ្ឋសមកបិទពីលើខ្លួនវត្ថុ (បច្ចេកទេសនោះពុំមែនមនុស្សជាតិទូទៅស្គាល់ទេ) ប្រព័ន្ធទាំងពីរហាក់ដូចគ្មានទាក់ទងនឹងគ្នាអ្វីទាំងអស់។ ទំនាក់ទំនងរវាងប្រទេសទាំងពីរប្រហែលជាមានតាំងពីពាក់កណ្ដាលស.វ.ទី១០មែន។ ប៉ុន្តែការដែលច្បាស់ គឺទាល់តែដល់ពាក់កណ្ដាលទី១ នៃស.វ.ទី១២ ទើបកុលាលភាជន៍យួនចាប់ផ្ដើមមាននៅអង្គរ។ ឯវត្ថុជាទីសំអាងក៏មានស្ដួចស្ដើងផង ពោលគឺមានតែបំណែកពីរនៃថូដែលមានបញ្ចុះ ព្រមទាំងវត្ថុចំនួនប្រមាណដប់ (ប្រអប់ដែលមានជ្រុងបន្ទះៗច្រើន និងពែងតូចៗមានជើង) ប្រកបដោយស្រទាប់រលោងពណ៌បៃតង

២៨ *Ceramics*, p. 39។

វិស័យដូចពណ៌ត្រប់ញូង, ចាំងបន្តិចដូចសំណ, ហើយដែលសាច់ដីទន់ពណ៌លឿងទាញទៅរកស្វាទុំ។ ប្រវត្តិសាស្ត្រអាចបញ្ជាក់រឿងនេះបានយ៉ាងងាយៈ ព្រះបាទសូរ្យវរ្ម័នទី២ ចាប់ផ្តើមវាយប្រទេសដៃវៀត ដោយឆ្លងកាត់តាមចម្ប៉ានៅរវាងគ.ស.១១២០។ ព្រះអង្គសាកល្បងជាលើកក្រោយម្តងទៀតនៅឆ្នាំ១១៥០ លើកនេះចូលតាមផ្លូវគោក។ ប្រហែលជាព្រះអង្គសុគតក្នុងសង្គ្រាមលើកក្រោយនេះ។ បន្ទាប់ពីនោះមក កុលាលភាជន៍យួនកម្រមាននាំចូលមកអង្គរទៀតណាស់។ យើងឃើញមានតែប្រអប់ដូចពោលខាងលើ ប្រមាណម្ភៃ–សាមសិបប៉ុណ្ណោះ នៅស.វ.ទី១៣។ លុះដល់ពាក់កណ្តាលទី២នៃស.វ.ទី១៤ យើងឃើញមានវត្ថុដែលមានពណ៌ខៀវនិងសលើផ្ទៃពណ៌ត្នោត។

ចំពោះខ្ញុំវិញ ខ្ញុំជឿទៅលើឥទ្ធិពលចិនជាង។ ឧទាហរណ៍ភាជន៍ Cizhou ដែលគេលាបទឹកថ្នាំពណ៌ខ្មៅ នៅក្រោមស្រទាប់រលោងថ្លាចាំង (ប្រភេទនេះ មិនដែលឃើញផលិតនៅអង្គរទេ) ឬមួយផលិតផលនៃឡនៅតំបន់ Hao-pi-chi និង Yu Xian ដែលគេធ្លាប់ឃើញបំណែកខ្លះនៅអង្គរ។

ជាធម្មតាយើងតែងឃើញស្រទាប់រលោងទាំងពីរនៅលើវត្ថុធំៗ ដូចជាថូរាងជើងទៀន និងពាងក្រឡ, ដប, ប៉ុន្តែជួនកាលមាននៅលើភាជន៍តូចៗដែរ (មើលរូបលេខ១៩ក និង១៩ខ)។ វត្ថុតូច ច្រើនតែមានស្រទាប់រលោងប្រភេទគូលែន ឯស្រទាប់រលោងវត្ថុធំច្រើនតែពណ៌ត្នោត។ ក្នុងសម័យនេះហើយដែលសោភណភាពនៃស្រទាប់រលោងឡើងដល់កម្រិតខ្ពស់បំផុត។ ទឹកដៃនៃស្មូនខ្មែរពេលនោះ ស្ទើរតែស្មើនិងចិនដែលជាគ្រូខ្លួន (មើលរូបលេខ៦, ៨ និង១៥)[២៩]។ ប៉ុន្តែចម្លែកនៅត្រង់គេមិនបង្កើតស្រទាប់រលោងអ្វីផ្សេងទៀត ក្រៅអំពីពណ៌ខ្ចី (លឿងនិងបៃតង) និងពណ៌ត្នោត ឬមួយក៏ពណ៌ទាំងពីរនេះនៅលើវត្ថុជាមួយគ្នា។ តាមពិតទៅ យើងពុំស្គាល់ពណ៌ទាំងអម្បាលមាណដែលខ្មែរបុរាណនិយមឬប្រើប្រាស់ទេ ក្រៅអំពីពណ៌ដែលបានឃើញលើកុលាលភាជន៍ ព្រមទាំងសម្រិតជ្រលក់មាស។ គ្មានសំណល់គំនូរតាមជញ្ជាំង ឬវត្ថុដែលមានលាបពណ៌អ្វីមួយ ដែលនៅគង់វង្សដល់យើងសោះ។ ប្រហែលជាចំនួនដ៏តិចនៃពណ៌កុលាលភាជន៍នេះ បណ្តាលមកពីបច្ចេកទេសផលិតនៅទាបនៅឡើយ។ ប៉ុន្តែខ្ញុំបានពោលមកថាស្រទាប់រលោងពណ៌ខ្ចីច្រើននៅលើវត្ថុដែលមានទំហំតូច ហើយវត្ថុតូចៗទាំងនោះច្រើនតែមានទំនាក់ទំនងជិតស្និតទៅនិងគ្រឿងប្រាក់។ អាស្រ័យហេតុនេះ ខ្ញុំនឹងហៅពពួកកុលាលភាជន៍នោះថាជា " គ្រឿងប្រាក់នៃអ្នកក្រ "។ ប្រហែលយើងអាចអះអាងថា ក្នុងការឲ្យពណ៌នោះ ស្មូនខ្មែរខំយកពណ៌ប្រាក់ជាតម្រាប់។ ម្យ៉ាងទៀតយើងដឹងថា ចំពោះរូបរាងវិញ ភាជន៍ធំៗធ្វើចម្លងតាមភាជន៍លោហធាតុ ដូចជាប្រាក់ និងមាស (ដែលខ្មែរនិយមហៅថាមាស អាចជាសម្រិតជ្រលក់ទឹកមាសតាមរយៈបារ៉ត និងស្ពាន់)។ សម្រិតនៅស្រុកខ្មែរ តាមពិតដូចនៅឥណ្ឌាដែរ ពោលគឺស្ទើរតែជាស្ពាន់សុទ្ធ។ កាលណាប្រើប្រាស់ជាប្រចាំ ស្ពាន់នោះក្លាយពូត។ មើលតាមទិន្នន័យទាំងអស់នេះទៅ យើងអាចធ្វើសមត្ថិកម្មថា ចំពោះភាជន៍ធំៗ ស្មូនខ្មែរព្យាយាមចម្លងពណ៌តាមវត្ថុធ្វើពីសម្រិតជ្រលក់ទឹកមាស។ ជាទូទៅ ពណ៌នោះគឺនៅជុំវិញពណ៌ត្នោត ទាញទៅរកទឹកមាស។

នៅទីនេះ គប្បីរាប់បន្ថែមនូវរូបរាងមួយចំនួនទៀត។ ថូរាងជើងទៀន មិនសូវមានលំអក្បាច់ពកលើខ្លួនច្រើនទេ ប៉ុន្តែមានបន្ទះក្បាច់រលកស្តើងៗជាជួរ (មើលរូបលេខ១០, ១៨ និង២៦)។ ជើងមានរាងមូលជាបំពង់ដដែល តែកាន់តែវែងទៅៗ ហើយច្រើនមានក្បាច់ទ្រនង់ល្បាក់ ជួនកាលថែមទាំងមានឆ្នូតរលកសើៗផង (មើលរូបលេខ១០ និង២៦)។ បើថូស្រាវិញ ឥតឃើញមានល្បាក់បញ្ឈរលើមាត់ទៀតទេ ឯរូបរាងសមសួនជាងមុន។ បើសម្បូណ៌ជាងនោះទៅទៀត គឺថូដែលមានរាងប៉ោងខាងលើ, ឥតមានក (មើលរូបលេខ១០) មាត់ជារមូមួយជុំ[៣០] ព្រមទាំងដបដែលមានរាងប៉ោងដែរ, កតូចចង្អៀត, មាត់មិនរីកសាយ ឬមួយមាត់រីកសាយធ្លាក់មកជារមូមួយជុំនៅគែម (មើលរូបលេខ១៩ក)[៣១]។ ដបធ្វើជារាងឃ្លោកក៏មានដែរ (មើលរូបលេខ១៩ខ)[៣២]។ ចំណែកឯភាជន៍ដែលមានរាងមូលសំប៉ែតក៏កាន់តែសម្បូណ៌ឡើង (មើលរូបលេខ៣៨) ប៉ុន្តែមានតែខ្សែឆ្នូតបញ្ឈរបន្តិចបន្តួចជាលំអប៉ុណ្ណោះ។

ចានក្បានរូបសត្វក៏ប្រើជាទូទៅដែរ។ គេច្រើនតែធ្វើជារូបមៀមឬកូនមាន់ ហើយមានក្បាច់ខ្សែឆ្នូតបញ្ជាក់ថាជាស្លាប (មើលរូបលេខ៨, ៩ និង៤០)។ ជាមួយគ្នានោះ ឃើញមានកូនក្រឡឬខ្ចូចតូចៗរាងមូល, ជួនកាលមានគ្របផង, ហើយដែលមានក្បាច់ខ្សែឆ្នូតសឹងតែទាំងអស់ (មើលរូប

---

២៩ ឧទាហរណ៍ច្បាស់ខ្លះទៀតនៅក្នុង *Southeast*, p. 33, no. 5; *Legend*, nos. 36, 39, 58។

៣០ សូមមើលវត្ថុដ៏ល្អៗនៅក្នុង *Legend*, nos. 88, 89។

៣១ សូមមើល *Legend*, no. 92 ផងដែរ។

៣២ សូមមើលបន្ថែមក្នុង *Ceramics*, pl. J, no. 4; *Export*, p. 112, no. 210។

លេខ២៤)។ បើភាជន៍ដែលមានរាងផ្លែល្ពៅ ទើបឃើញថាចម្លងតាមធម្មជាតិទាំងស្រុង។ គេធ្វើសណ្ឋានវាឲ្យលៀនចេញមកច្បាស់[៣៣]។ចំណែកឯប្រអប់មូល, មានគម្របមូលចោំង, ហើយកំពោយកាន់រាងសាជីក៏កាន់តែសម្បូណ៌ដែរ[៣៤]។ ជួនកាលឃើញមានស្រទាប់រលោងពីរ ប្រកបដោយក្បាច់ផ្ចិត។ ឱទាហរណ៍សំខាន់បំផុតនៃផលិតផលទាំងអស់នេះ គឺថូមានគម្របដែលមានស្រទាប់រលោង "គូលែន"។ ប៉ុន្តែជួនកាល ស្រទាប់រលោងនោះពណ៌ត្នោតដែរ *(មើលរូបលេខ១៤៥)*[៣៥]។

គឺនៅសម័យនេះហើយ ដែលគេប្រទះភាជន៍តូចៗមានគម្រប, ខ្លួនរាងដូចបំពង់ តែផតកណ្ដាលបន្តិច ស្រដៀងវែក *(មើលរូបលេខ២០)*។ ខ្មែរសព្វថ្ងៃមើលទៅស្គាល់ភ្លាមថាជាភាជន៍ដាក់ក្រមួនសំអាងកាយ ត្បិតអ្នកខ្លះនៅប្រើប្រាស់នៅឡើយ។ ប្រេងក្រមួននោះអប់ដោយផ្កា ហើយគេយកទៅលាបក្រោយស្លឹកត្រចៀក និងនៅកញ្ចឹងក។ វត្ថុដែលបង្កើតថ្មីមួយទៀត ជាភាជន៍មានជើង, ខ្លួនរីកសាយទៅលើដូចសាជីកំបុត, ក្អែងរាងសាជីដែរ ប៉ុន្តែសំប៉ែតផ្ដេកខ្លាំង។ គម្របប្រហោងក្នុង ហើយមានកំពោយចាប់ពីលើ ចំពោះភាជន៍មានទំហំតូច។ បើភាជន៍នោះធំ គឺគម្របមានរាងសាជីស្រួចរហូតដល់ចុងតែម្ដង។ ទំហំភាជន៍នេះខុសៗគ្នា អាចឡើងពីកំពស់ ១០ស.ម.រហូតដល់៤០ស.ម.។ នៅលើចម្លាក់តាមជញ្ជាំងប្រាសាទ យើងតែងឃើញរូបរាងភាជន៍នេះនៅជិតព្រះរាជាឬមន្ត្រីផ្សេងៗ។ ក្នុងនោះមានផ្លែឈើ *(?)* មូលៗ ទំហំប្រហែលគ្រាប់ពុទ្រា *(ឬមួយជានំបង្អែមទៅវិញ?)*។ ចម្លាក់នោះលំអិតល្អណាស់ ធ្វើឲ្យយើងឃើញច្បាស់ថាជាភាជន៍ដែលត្បាញដោយរុក្ខជាតិ។ ដូច្នេះកុលាលភាជន៍ដែលទើបនឹងពោលមក ច្បាស់ជាចម្លងតាមកុលាលភាជន៍រុក្ខជាតិនោះឯង។ មិនតែប៉ុណ្ណោះ នៅលើក្អែងច្រើនតែមានក្បាច់លំអស្អេកស្កះ៖ ខ្សែទ្រនង់ដ៏ច្រើន, ខ្សែបន្ទះតូចៗដែលមានក្បាច់គូសខ្វែងគ្នា ព្រមទាំងពងក្រីផង... ទាំងនេះធ្វើឲ្យយើងជឿថាជាការធ្វើត្រាប់តាមភាជន៍ត្បាញដោយរុក្ខជាតិ *(មើលរូបលេខ១៥ និង១៦)*[៣៦]។ ភាជន៍ដែលប្រើសម្រាប់ដាក់តង្វាយឬជំនូននោះ ជាដូនតានៃភាជន៍ដែលខ្មែរប្រើក្នុងមុខងារដដែលរហូតដល់បច្ចុប្បន្ននេះ។ កាលដើមឡើយ ស្រទាប់រលោងមានពណ៌បៃតងប្រភេទ "គូលែន" ប៉ុន្តែមិនយូរប៉ុន្មាន គេប្រើស្រទាប់រលោងពណ៌ត្នោតជំនួសវិញ។ ក្រោយមកទៀត ចានរាងសាជី ក៏កាន់តែផលិតច្រើនទៅៗ *(មើលរូបលេខ១២, ១៣ និង១៤)*[៣៧], ជួនរាងមូលក្រឡុំពាក់កណ្ដាល, ទ្រដោយជើង[៣៨], ជួនកាលខ្លួនបញ្ឈិតផ្ដេកជាងនោះ ប្រកបដោយបាតផ្ដេកស្មើ[៣៩]។ ម្ដងៗឃើញមានពែងដែលតួរាងបំពង់ខ្ពង់បន្តិច[៤០]។

បើនិយាយសង្ខេបកុលាលភាជន៍សម័យនោះមកនៅតែពីរបីមាត់ គឺគេសំអិតសំអាងស្រទាប់រលោងជាងពេលមុនៗ។ ចំពោះលំអវិញ ការនិយមក្បាច់ល្បាក់និងខ្សែព្រកត្រូវចុះថយ ហើយគេយកផ្ចិតប្រភេទធរណីមាត្រមកជំនួសវិញ។

## ប្រមូលផ្ដុំ

ការរីកចំរើនដែលបានពោលមកហើយនេះ ចាប់ផ្ដើមថយចុះទៅវិញរហូតដល់នៅទ្រឹងមួយកន្លែង រវាងពីរឬបីទសវត្សចុងក្រោយនៃស.វ.ទី១២។ យើងអះអាងយ៉ាងនេះបាន ដោយសារបានរបស់របរច្រើន *(ហើយជារបស់ពេញរូបរាងមិនមែនត្រឹមជាបំណែកប៉ុណ្ណោះទេ)* ពីការធ្វើកំណាយនៅទីបញ្ចុះធាតុ "ស្រះស្រង់"។ របស់ភាគច្រើន កើតពីជំនាន់នោះឯង គឺត្រូវនឹងរាជ្យព្រះបាទជ័យវរ្ម័នទី៦ *(១០៨០_១១០៧)*។

ភាជន៍ប្រកបដោយស្រទាប់រលោងពីរ មានតិចជាងពេលមុនៗ។ ស្រទាប់ពណ៌ខ្ចីច្រើនតែវាតទីទៅកនឹងក្អែងទាំងមូល។ លុះទីបញ្ចប់ ឃើញ

---

[៣៣] *Legend*, no. 59; *Trade*, p. 217, no. 234។
[៣៤] *Southeast*, p. 33, no. 2; *Legend*, no. 58។
[៣៥] *Legend*, no. 64; *Trade*, p. 217, no. 233។
[៣៦] មានឱទាហរណ៍ច្បាស់ខ្លះទៀតនៅ *Legend*, no. 84។
[៣៧] *Legend*, nos. 29, 31; *Southeast*, p. 34, no. 6។
[៣៨] *Legend*, nos. 32, 33។
[៣៩] *Legend*, no. 36; *Southeast*, p. 33, no. 5។
[៤០] *Legend*, no. 34។

មានភាជន៍មួយចំនួនតូចដែលមានស្រទាប់គូលែនស្ទើរតែពេញលើខ្លួន។ មានតែនៅផ្នែកខាងក្រោមជិតគូថប៉ុណ្ណោះ ទើបមានស្រទាប់ត្នោតក្រមៅកំពស់ ២ឬ៣ស.ម.។ លក្ខណៈគួរកត់សំគាល់នៃវត្ថុទាំងនេះ គឺស្រទាប់រលោងពណ៌បៃតងច្រើនតែឈប់នៅត្រង់ទ្រនង់ពកមួយជុំ ដែលលើនោះមានច្នូតខ្ចីៗបញ្ឈរជាក្បាច់។ របៀបនេះគេអាចឃើញដែរ នៅលើដើមកនៃថូឯទៀតក្នុងប្រភេទជាមួយគ្នា។

ភាគច្រើនគឺស្រទាប់ពណ៌ត្នោត ដែលគេនិយមសូម្បីតែលើភាជន៍តូចៗក៏ដូច្នោះដែរ។ ក្នុងការផលិត គេច្រើនតែយកវត្ថុទាំងនោះទៅជ្រលក់ក្នុងទឹកថ្នាំមួយដែលគ្របដណ្តប់ពាសពេញខ្លួន ពីលើដល់ក្រោម (មើលរូបលេខ១៥១ខ)។ ពេលដុតទៅ ប្រែពណ៌ទៅក្រហមខ្ចី, ស្ទើរតែដល់ស្វាទុំ, ជួនកាលភ្លឺចាំងផ្លេកចេញពណ៌ស្វាយផង។ ពីដំបូង ស្រទាប់រលោងមានគុណភាពល្អប្រសើរ ពោលគឺក្រាស, រលើបជាប់ស្អិតជាមួយតួវត្ថុ។ ស្រទាប់នោះមានរន្ធខ្យល់តូចៗច្មារ ព្រមទាំងស្នាមអុចច្មាររាយលើនោះដែរ មើលទៅហាក់បីដូចជាគេរាយអំបិលម្រេចលើផ្ទៃរលោងថ្លានោះ។ ជាទូទៅ ស្រទាប់រលោងមានពណ៌ត្នោតស្រគាំ (មើលរូបលេខ១៥១ក) ដែលអាចក្រមៅលើសនោះទៅទៀត (មើលរូបលេខ២២, ២៥ក, ៣១, ៣៧, ៥០ក, ៥០ខ និង៥០គ) ឬខ្មៅរលើបដូចកៅស៊ូក្រាលថ្នល់ផង (មើលរូបលេខ២៥ខ, ៣២ក, ៣៣ និង៤០ឃ)។ យើងមានអារម្មណ៍ថា គេចង់ចម្លងតាមពួក temmoku ព្រោះយើងបានប្រទះបំណែកពីរបីនៅព្រះរាជវាំងអង្គរធំ។ ស្រទាប់រលោងដូចកៅស៊ូថ្នល់នោះសម្បូណ៌ ជាពិសេសបើពោលពីវត្ថុផលិតនៅតាមឆ្ងាយៗពីរាជធានីអង្គរ។ នេះប្រហែលមកពីជ្រុលភ្លើង?

រវាងចុងសម័យនោះ ស្រទាប់រលោងស្តើងជាងមុនឆ្ងាយ ជាហេតុធ្វើឲ្យពេលដែលដុត ប្រែពណ៌ទៅជាត្នោតស្រគាល, ជួនកាលទៅជាពណ៌ទឹកឃ្មុំចាំង ឬក៏ពណ៌ស្លាន់ផង (មើលរូបលេខ១៤៨ និង៥១ក)។ ជាមួយគ្នានោះ ក៏អាចមានពន្លឺផ្លេកពណ៌បៃតងចាស់ផងដែរ។ ប៉ុន្តែនេះជាការកម្រ (មើលរូបលេខ២៨, ៣២ខ, ៥១ក និង៦៣)។ ចំណែកឯស្រទាប់គូលែនវិញ គេពុំសូវនិយមទៀតទេ។ ស្រទាប់នោះស្តើងណាស់ ជាហេតុនាំឲ្យងាយរបក។ ឯពណ៌ មានពីបៃតងដល់ពណ៌លឿងទឹកឃ្មុំ (មើលរូបលេខ១៩ និង១២)។

រូបរាងទាំងអម្បាលមាណ មិនខុសពីរូបរាងដែលធ្លាប់រៀបរាប់ពីលើមកហើយទេ៖ ភាជន៍ប្រភេទក្អម[៤១], ដប[៤២], ក្រឡ[៤៣], ក្រឡរាងជើងទៀន (មើលរូបលេខ១៥២)[៤៤], ភាជន៍ដាក់តង្វាយ, ឪទិនស្រា (ដែលស្រដៀងនឹងក្រឡរាងជើងទៀន)[៤៥]។ ជើងតូចៗក៏ធ្លាប់ប្រទះញយដែរ។ នៅប៉ែកខាងលើនៃខ្លួនភាជន៍ធំៗសម្រាប់ដាក់ធញ្ញជាតិ ចាប់ផ្តើមឃើញមានច្នូតលំអជារលកៗ (មើលរូបលេខ១៦៣)។ វត្ថុដែលជាលក្ខណៈសម្គាល់នៃសម័យនេះ គឺដបម៉្យាងដែលមានរាងមូលទ្រវែង, កវែង, មាត់រីកចេញក្រៅបន្តិចសិនទើបបត់មកឡើងលើដូចសាជីកាត់ចុងវិញ ពាត់ដោយក្បាច់ពងក្រពើកៗមួយជុំផង[៤៦]។ បើសម្បូណ៌ជាងនោះទៅទៀត គឺដបដែលមានរាងឃ្លោក, ខ្លួនប៉ោង, កវែង, មាត់រីកសាយ ជួនកាលប្រកបដោយស្រទាប់គូលែន, បើពុំដូច្នេះទេ មានកខ្លី, មាត់គ្រាន់តែជារមូមួយជុំ មិនសាយទៅក្រៅឡើយ ឯស្រទាប់រលោងច្រើនតែពណ៌ត្នោត។ បើភាជន៍មូលសំប៉ែតតូចៗវិញ គឺសម្បូណ៌ណាស់ ព្រមទាំងជាទីនិយមនៃឈ្មួញនិងម្ចាស់សមុច្ច័យក្រៃលែង ត្បិតវត្ថុទាំងនេះតូចមាំ ពុំសូវមានខូចខាត។ មុនដំបូង ក្បាច់លំអមានតែស្នាមចូតបញ្ឈរ និងក្បាច់ចង្អូរខ្លះៗនៅមាត់ក្អែងប៉ុណ្ណោះ (មើលរូបលេខ៣៧ និង៣៨)។

ចំពោះពពួកកូនភាជន៍តូចៗ ការផ្លាស់ប្តូរមានបន្តិចបន្តួច។ ចាប់ពីពេលនោះមក ភាជន៍មានគម្របតែងមានពណ៌ត្នោត។ កំពោយកណ្តាលគ្រប ចេញមកលើផុតបន្តិច ហាក់ដូចជានៅលើទងមួយ (មើលរូបលេខ២៣)។ ក្រឡប៉ោងតូចៗ (មើលរូបលេខ២៥ក និង២៥ខ) និងកូនដប តែងតែមានក្បាច់លំអនៅក្រោមស្រទាប់រលោង។ ប្រអប់ដាក់ក្រមួនសំអាងកាយក៏ដូចគ្នាដែរ។ យើងឃើញមានក្បាច់ខ្សែច្នូត បញ្ចិតរៀងគ្នា –ជួនកាលខ្សែនោះកើតឡើងដោយចំណុចតៗគ្នា– ហើយច្រើនតែចែកជាថ្នាក់ខុសៗគ្នាផង (មើលរូបលេខ១៥៨)។ គួរកត់សម្គាល់ប្រអប់ពិសេសម៉្យាង (មើលរូបលេខ១៤៨) ដែលមានក្បាច់ច្នូតព្រមទាំងចំណុចពក ហើយដែលចម្លងត្រង់តាមប្រអប់សម្រិតជំនាន់អង្គរដែរ។ រូបរាងប្រអប់នេះ ទាបចុប្បន្នគេផលិតជាគ្រឿងប្រាក់។ ចានក្បានដែលមានរូបរាងជាសត្វក៏ច្រើនតែលំអទៅដោយក្បាច់ច្នូតខូង (មើលរូបលេខ១៨, ៣២ក, ៣២ខ, ៣៣, ៤០ឃ និង៤៩)។ រី

---

[៤១] សូមមើល *Southeast,* p. 35, no. 7, and *Ceramics,* pl. J, no. 2។

[៤២] *Trade,* p. 223, no. 244។

[៤៣] *Ceramics,* pl. K, no. 2។

[៤៤] *Trade,* p. 223, no. 245។

[៤៥] *Ceramics,* pl. K, no. 1។

[៤៦] *Ceramics,* p. 41, fig. 13។

ឯចានក្រឡុមដែលមានជើងរាងសំប៉ែត ឃើញមានច្រើន។ ស្រទាប់រលោងរបស់វា រាងក្រមៅមើលទៅដូចជុតខ្លោច។ ភាជន៍មានជើងម្យ៉ាងទៀតមានទម្រង់រាងដូចក្រពុំផ្កាលៀនចេញពីបាតខាងក្នុងមកលើ។ យើងពុំស្គាល់មុខងាររបស់វាទេ (មើលរូបលេខ៧ និង៦១)[៤៧]។

ជាទូទៅយើងសង្កេតឃើញថា វត្ថុទាំងឡាយមានភាពសមរម្យ, នឹងន, បង្ហាញថាស្មូនច្បាស់ប្រាកដនឹងជំនាញព្រមទាំងទឹកដៃរបស់ខ្លួន។ ក្បាច់ល្បាក់ស្ទើរតែលែងឃើញមានទៀត ហើយគេព្យាយាមបង្កើនលំអក្បាច់ឆ្នូតវិញ។ មានតែក្បាច់ទ្រនង់តូចៗខ្លះទេ ដែលនៅសល់នៅឡើយ។ ក្បាច់ឆ្នូតកាន់តែកើនឡើងច្រើននៅលើក្អែង, នៅផ្នែកខាងលើនៃខ្លួនភាជន៍, ជួនកាលនៅជើងផង។ ក្បាច់នេះគ្មានបែបផែនច្រើនប៉ុន្មានទេ គឺមានតែក្បាច់ចង្អូរ, ក្បាច់ឆ្នូតផ្តេក ឬខ្សែបញ្ឆិត ព្រមទាំងក្បាច់រលកដូចខ្សែសមុទ្រ។ ស្មូនសំអិតសំអាងខ្លាំងទៅលើរាងទូទៅនៃភាជន៍ ព្រមទាំងលើការឱ្យពណ៌ផង។ ភាជន៍រាងជើងទៀន មានភាពសង្ហារគួរឱ្យចាប់ភ្នែក។ ជើងរបស់វាមានកស្តួច មើលទៅឃើញដូចជាកែវមានជើងដែលគេផ្កាប់។

## លំនឹង

ជំនាន់អង្គរវត្ត ជាសម័យកាលដែលកុលាលភាជន៍ខ្មែរឈានមកដល់គុណភាពពេញលេញ។ បើគិតជារាជ្យវិញ គឺត្រូវនឹងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ *(រវាង១១១៣_១១៥០)* ដែលជាអ្នកកសាងប្រាសាទអង្គរវត្ត ចូងចូលមករាជ្យខ្លីៗតមក រហូតដល់ពេលដែលចាមលុកលុយអង្គរនាឆ្នាំ១១៧៧។

គេនិយមពេញបន្ទុកនូវភាជន៍ដែលមានស្រទាប់រលោងពណ៌ត្នោត។ ភាជន៍ប្រកបដោយស្រទាប់គូលែនកម្រមានណាស់ ឃើញមានតែថូមានគម្របពីរបីប៉ុណ្ណោះ *(មើលរូបលេខ២៩)*។ តួខ្លួនវារាងស្រឡូនជាងមុន, គម្របក៏ចោំងជាងមុនដែរ, កំពោយរួញ ហើយនៅគល់កំពោយនោះច្រើនតែមានក្បាច់ស្លឹកពីរបីជុំ ឬមួយមានខ្សែឆ្នូតស្របៗគ្នា។ វត្ថុនោះអាចមានស្រទាប់រលោងពណ៌ត្នោតដែរ ប៉ុន្តែក្នុងករណីយ៏នេះ កំពោយតែងតែលេចចេញច្បាស់អំពីទងមួយ ដែលនៅគល់មានវង្វង់ក្បាច់ខ្លះជាលំអ។ តាមពិតទៅ យើងពិបាកចែកវត្ថុខាងក្រោយនេះឱ្យដាច់ច្បាស់ពីផលិតផលដែលមានមុនបន្ទាប់នោះខ្លាំងណាស់។ ប្រហែលមានតែស្រទាប់រលោងដែលស្តើងងាយរបកនោះប៉ុណ្ណោះ ដែលជាលក្ខណៈសំគាល់នៃវត្ថុសម័យថ្មីនេះ។

តាមខ្ញុំស្មាន ប្រហែលជានៅសម័យនេះហើយដែលគេផលិតវត្ថុដ៏ល្អពិសេសមួយ ដែលខ្ញុំមានឱកាសបានកាន់ស្ទាបនៅដៃ។ វត្ថុនោះជារូបដំរី, តាំងនៅសារមន្ទីរជាតិភ្នំពេញ, មានស្រទាប់រលោងពីរពណ៌។ ទាំងស្រទាប់រលោង ទាំងរូបរាងដំរីនោះ សឹងប្រកបដោយសោភណភាពពន់ពេក[៤៨]។

ស្រទាប់រលោងក្រាសហើយគ្រើម ដែលនៅពីលើទឹកថ្នាំផ្ទាល់មួយជាន់នោះ គេនៅផលិតមួយរយៈពេលតទៅទៀត។ ទឹកថ្នាំនោះជួនកាលប្រែទៅជាពណ៌ស្វាយ។ ប៉ុន្តែជាទូទៅ ស្រទាប់រលោងស្តើងជាងមុន ហើយថ្លា។ ពណ៌មានតាំងពីត្នោតស្រដៀងស្លាន់ ទៅដល់ពណ៌ក្រហមដាំ *(មើលរូបលេខ៣៩, ៤១, ៤២ និង៥៩)*។ ព្រមជាមួយនោះ គេលែងឃើញមានប្រើទឹកថ្នាំពណ៌ត្នោតទៀតហើយ, ជួនកាលគេជំនួសដោយទឹកថ្នាំមួយស្រទាប់ស្តើងខ្លាំង ដែលដុតទៅពណ៌ប្រែជាសល្អក់។ ប៉ុន្តែជាទូទៅ ច្រើនតែដីខ្លួនឯងតែម្តង *(ឥតទឹកថ្នាំ)* ដែលប្រែពណ៌ទៅជាប្រផេះល្អក់ឬក៏លឿងខ្ចី។

ភាពបរិសុទ្ធនិងភាពសង្ហារនៃរូបរាងភាជន៍ មានជាទូទៅ។ ចានក្បាននៅធ្វើដោយរមួដីឥដ្ឋនៅឡើយ ប៉ុន្តែខាងក្នុង គេរំលីងស្អាតមិនឱ្យ

---

[៤៧] មានឧិទាហរណ៍ខ្លះទៀតនៅក្នុង *Trade,* p. 223, no. 243; *Legend,* nos. 37, 38។ ភាជន៍របៀបនេះ គេច្រើនហៅថា 'ចង្កៀងខ្លាញ់' គឺប្រហែលជាគេប្រៀបទៅចង្កៀងខ្លាញ់ចិន។ ប៉ុន្តែធម្មតាចង្កៀងចិនតែងមានជើងទម្រ ឬបណ្តូលក្នុងវែងទៅលើ ហើយមានកូនចាននៅបន្តភ្ជាប់សម្រាប់ដាក់ប្រេះ។ ខ្ញុំពិបាកជឿណាស់ថាភាជន៍ខ្មែរនេះជាចង្កៀង ជាពិសេសយើងធ្លាប់ឃើញមានវត្ថុដែលប្រហែលជាចង្កៀងពិតប្រាកដទៅហើយ *(សូមមើលកំណត់លេខ ៦០)*។ បើពោលថាជាភាជន៍សម្រាប់ដុតគ្រឿងក្រអូប អាចសមបន្តិច ប៉ុន្តែទោះបីយ៉ាងនោះក៏យើងពុំឃើញមានស្នាមខ្មៅខ្លោចដែរ នៅលើបណ្តូល។ ម្យ៉ាងទៀត មានឧិទាហរណ៍វត្ថុនៅសម័យជាមួយគ្នា ដែលសមជាភាជន៍ដុតគ្រឿងក្រអូបជាងនេះផង។ សូមអាន W. Willetts, ed., *Ceramic Art of Southeast Asia* (Singapore: Southeast Asian Ceramic Society, 1971), p. 89, no. 8។ មើលទៅ វត្ថុនេះអាចជាភាជន៍សម្រាប់កំដៅគ្រឿងសំអាងកាយផ្សេងៗ ឱ្យរលាយចូលគ្នានៅក្នុងតទ្វាប់ ឬខ្ទចអ្វីមួយដែលគេដាក់បន្តុបនៅលើចុងបណ្តូលនោះ។ វិធីកំដៅនោះ គឺគេយកទឹកក្តៅមកចាក់ក្នុងគោមជុំវិញបណ្តូល ដែលបារាំងហៅថា "bain-marie"។ ប៉ុន្តែនេះក៏គ្រាន់តែជាការស្មានដែរ។

[៤៨] B.P. Groslier, *Indochina, op. cit.*, pl. 138។

ឃើញស្នាមវាន់គ្នាទៀតទេ។ កម្រាសខ្លួនវត្ថុ ស្តើងជាងមុន។ បើគេប្រៀបធៀបភាជន៍ពីរ មានប្រភេទដូចគ្នា តែមួយផលិតនៅស.វ.ទី១១ ឯមួយទៀតនៅស.វ.ទី១២ កម្រាសតួវត្ថុខាងក្រោយ មានយ៉ាងច្រើនពាក់កណ្តាលកម្រាសវត្ថុទីមួយ ឬអាចទៅដល់មួយភាគបីផង។

ល្បាក់និងទ្រនង់ កម្រមានជាងមុន ហើយបើមានក៏ពុំចេញពកខ្លាំងទេ។ គេយកក្បាច់ចង្អូរមកជំនួសបន្តិចម្តងៗក្នុងសតវត្សនោះ។ ក្បាច់ឆ្លាក់ក៏កាន់តែសម្បូណ៌នៅលើក្អេង ឬមួយជាក្បាច់ផ្តិត (ក្រឡាតូចៗ) ដោយកូនកង់ឫស្សីមួយដែលគេរុញបង្វិលឱ្យបត់ជុំវិញក្អេងនោះ។ បើពុំដូច្នោះ គេនិយមក្បាច់រលកវិស័យដូចខ្សែលើសំបកខ្យង (មើលរូបលេខ២៦, ៤៤, ៥២, ៥៣១ និង៥៧)។ ក្បាច់លំអទាំងនេះ កាន់តែវាតទីបន្តិចម្តងៗទៅលើតួខ្លួន រហូតដល់ជើង។ មើលទៅឃើញថា គេកាន់តែនិយមឡើងៗ ដោយសារស្រទាប់រលោងមានភាពស្តើងល្អ ធ្វើឱ្យក្បាច់លេចចេញឡើងច្បាស់ក្រោមពន្លឺថ្លានៃស្រទាប់នោះ។

រូបរាងភាជន៍ពុំសូវដូរបែបផែនអ្វីទៀតទេ (មើលរូបលេខ៣១, ៤៤ និង៥២)។ រីឯថូដែលមានចំពួយ ក៏ស្ទើរពុំប្រទះទៀតឡើយ។ បើក្រឡពាងធំៗទើបសម្បូណ៌។ ខ្លះមានក្បូរក្បាច់ប្រកបដោយលក្ខណៈប្លែក ធ្វើឱ្យយើងគិតថា ប្រហែលជាផលិតផលនៃឡតាមខេត្តផង។ ចានក្បានតូចតាចស្ទើរតែទាំងអស់មានស្រទាប់រលោងពណ៌ត្នោត ដូចជាកូនភាជន៍រាងមូល (មើលរូបលេខ២៧ និង៥១ក), ប្រអប់រាងមូលដែលមានគម្របស្រួចទៅលើ[៤៩], ប្រអប់ដាក់ក្រមួនសំអាងកាយ (មើលរូបលេខ២១)។ល។ កុណ្ឌីជារបស់ដែលកម្រមាន (មើលរូបលេខ៤៧)។ បន្ទាប់មកមានដបផ្សេងៗ, គោមដែលមានជើងរួញសំប៉ែត (មើលរូបលេខ៤៦) ហើយដែលច្រើនតែមានស្រទាប់រលោងស្តើងពណ៌ក្រមៅ។ ចានដែលមានទម្រនៅខាងក្នុងក៏សម្បូណ៌ដែរ។

យើងពិបាកចែកឱ្យដាច់ពីគ្នាច្បាស់ រវាងកុលាលភាជន៍ផលិតនៅពាក់កណ្តាលទីមួយនៃស.វ.ទី១២ និងផលិតផលតអំពីនោះមកម្ភៃឬសាមសិបឆ្នាំទៀត។ មិនដឹងជាពេលណាច្បាស់ទេ ដែលគុណភាពចាប់ផ្តើមចុះថយ។ យើងគ្រាន់តែអាចបញ្ជាក់ថា ការវិវត្តន៍ទូទៅ គឺទៅរកក្បាច់ឆ្លាក់ដែលមានចំនួនកាន់តែតិចទៅៗ ព្រមទាំងទៅរកស្រទាប់រលោងដែលមានភាពក្រមៅដូចកៅស៊ូក្រាលថ្នល់។ អាស្រ័យហេតុនេះ វត្ថុដែលមានរូបលេខ២៧, ៥៣ក, ៥៣១, ៥៥, ៥៦ក និង៦៨ អាចផលិតក្រោយសម័យនោះបន្តិចទៀត។ រីឯដីវលេខ៦៦, ៦៧ និង៦៩ ក៏ដូច្នោះដែរ។ មុនយល់ថារបស់ទាំងនេះផលិតជំនាន់ព្រះបាទជ័យវរ្ម័នទី៧។ ប៉ុន្តែនេះគ្រាន់តែជាការស្មានតាមអារម្មណ៍តែប៉ុណ្ណោះ។

មានភាជន៍ម៉្យាងដែលគេនិយមខ្លាំងនៅពេលនោះ គឺភាជន៍មូលសំប៉ែត, មានចំពួយខ្លី  ព្រមទាំងដៃកាន់កាច់ខ្វែងជាមួយមាត់ ហើយដែលតែងតែមានគម្រប។ គេច្រើនធ្វើភាជន៍នោះ ជារូបសត្វស្លាប ឬជួនកាលដៃកាន់ធ្វើជារូបសត្វប្រភេទជីងចក់ ឬពុំនោះសោតជាក្បាលនាគ (មើលរូបលេខ៣៩, ៤១ និង៤២)[៥០]។ ខ្មែរសព្វថ្ងៃនៅស្គាល់ថារបស់នេះសម្រាប់ដាក់ទឹកឃ្មុំ។

ខ្ញុំចាត់ជាបណ្តោះអាសន្ន នូវកូនក្រុមវត្ថុពិសេសមួយ ថានៅដើមសម័យខាងលើនេះ។ វត្ថុនោះជាដបរាងមូលមួយជាន់ ហើយមានថោងមួយគន្លាក់នៅផ្នែកលើទៀត ទើបមានកស្តួចវែងបន្តទៅ ប៉ុន្តែមាត់ឥតរីកខ្លាំងទេ។ កន្លែងថោងជិតកនោះ គេធ្វើជាមុខមនុស្ស មានដៃពីរផង។ កដបនោះជួនកាលមានស្រទាប់រលោងបៃតងប្រភេទតូលែន បើពុំនោះទេ ដបទាំងមូលមានស្រទាប់រលោងពណ៌ត្នោត (មើលរូបលេខ៣៥ និង៣៦)[៥១]។ មានប្រទះឃើញដបរបៀបនេះមួយនៅទីបញ្ចុះធាតុស្រះស្រង់ ដែលគេអារកផ្តាច់ពីខ្លួនយ៉ាងផ្ចិតផ្ចង់ នៅលើរូបក្បាល។ ដោយយោងទៅតាមស្រទាប់រលោងរបស់វា ខ្ញុំចាត់ទុកដបនេះថានៅក្នុងស.វ.ទី១២[៥២]។ មានដបរបៀបនេះមួយទៀត នៅសារមន្ទីរនគររាជ (ថៃឡង់ដ៍)។ ក្រៅពីនេះមានច្រើនទៀតដែលរាយប៉ាយនៅតាមសមុច្ច័យផ្សេងៗ ហើយដែលប្រហែលផលិតនៅតំបន់ ‘ភ្លៀសាន’ នៃប្រទេសសៀម។ យោងតាមគំនិតនេះ ដបដែលឃើញនៅស្រះស្រង់ អាចជារបស់សម្គាល់ទីបញ្ចុះធាតុនៃបុគ្គលណាម្នាក់ដែលមកពីភ្លៀសាននោះ ហើយដែលស្លាប់នៅអង្គរក៏មិនដឹង! នេះជាឧទាហរណ៍ ភាជន៍រូបមនុស្សតែមួយគត់ដែលខ្ញុំឃើញមានក្នុងកុលាលភាជន៍ខ្មែរ។ នៅស្រះស្រង់ឃើញច្បាស់ថា មានទំនាក់ទំនងជាមួយសព។ ប៉ុន្តែតើអាចមានតួនាទីអ្វីផ្សេងទៀត ឬអត់? ប្រសិនបើមាន ហេតុម្តេចបានជាគេអារកឱ្យដាច់ចេញ? សំនួរនេះពុំមានចម្លើយនៅឡើយទេ។

---

[៤៩] ឧទាហរណ៍៖ *Legend,* no. 62; *Ceramics,* pl. 23, no. 79; *Trade,* p. 219, no. 238។

[៥០] មានឧទាហរណ៍ច្បាស់ខ្លះទៀតនៅ *Southeast,* p. 37; *Ceramics,* pl. L, nos. 1, 4; *Legend,* nos. 81, 82, 83។

[៥១] ខ្លះទៀតនៅក្នុង *Ceramics,* pl. 22, no. 75; *Legend,* no. 69។

[៥២] B.P. Groslier, *Indochina, op. cit.,* pl. 144។

## សិល្បៈមួយដែលមកដល់អាយុកាល

ឆ្នាំ១១៧៧ មានសារៈសំខាន់ក្រៃលែង។ រាជធានីអង្គរត្រូវទទួលការវាយលុកដុតបំផ្លាញខ្ទិចខ្ទី។ មហន្តរាយនេះធ្វើឲ្យវិស័យសិល្បៈទូទៅដុនដាបខ្លាំង មានជាអាទិ៍សំណង់ប្រាសាទ, ចម្លាក់, ព្រមទាំងវត្ថុសម្រិត។ កុលាលភាជន៍ក៏ទទួលការប៉ះពាល់ដូចគ្នាដែរ ហើយស្ទើរតែផុតពូជនៅសម័យព្រះបាទជ័យវរ្ម័នទី៧ (១១៨៦_១២១៨) និងនៅក្រោមរាជ្យបន្តបន្ទាប់ភ្លាមនោះផង។

គួរឲ្យចម្លែកត្រង់ថា កុលាលភាជន៍ចិនមិនត្រឹមតែគេបន្តនាំចូលមកទៀតប៉ុណ្ណោះទេ គឺថែមទាំងចំនួនកើនឡើងជាងមុនៗទៅទៀត។ ជាការពិតហើយ គុណភាពចុះអន់ជាងមុន ដូច្នោះតម្លៃក៏ប្រហែលថោកជាងមុនដែរ។ តម្លៃថោកនេះអាចជាកត្តាមួយដែលនាំឲ្យគេលែងនិយមផលិតផលក្នុងស្រុក ហើយទីបំផុតទៅក៏ឈប់ផលិតតែម្ដង។ ទោះបីមូលហេតុជាអ្វីក៏ដោយ នៅព្រះរាជវាំងអង្គរធំ បើគេសន្មតថាបំណែកកុលាលភាជន៍ជំនាន់សន្តតិវង្ស Song ខាងជើង មានមួយនោះគឺបំណែក Song ខាងត្បូង មានពីរ, បំណែក Yuan មានបី ហើយបំណែកដើមជំនាន់ Ming មានបួន។ នៅព្រះរាជវាំងចំនួនកុលាលភាជន៍សន្តតិវង្សទាំងប៉ុន្មាននេះមាន ៥០%, បន្ទាប់មក ៣០%, រួចទើប ៨០% (ជំនាន់ Yuan និង Ming)។ នៅជំពូកខាងក្រោយទៀត យើងនឹងឃើញថាចម្លាក់នៅផ្ទាំងជញ្ជាំងប្រាសាទបាយ័ន្តបង្ហាញច្បាស់អំពីជំនួញកុលាលភាជន៍ (មើលរូបយ)។

ផលិតផលក្នុងស្រុក រួមមកនៅតែពីរបីក្រុមប៉ុណ្ណោះ។ ចំនួនដែលច្រើនជាងគេគឺ កោដ្ឋ (លើកនេះយើងអាចពោលថា "កោដ្ឋ" ច្បាស់ពោលគឺមិនត្រឹមតែជាភាជន៍មានគម្របប៉ុណ្ណោះឡើយ) ដែលគេរកឃើញនៅតំបន់ភ្នំគូលែន។ ស្រទាប់រលោងភាគច្រើនបំផុតពណ៌លឿងចម្បើង, មានស្នាមស្រាំ ព្រមទាំងងាយរបេះផង។ រូបរាងសំដៅទៅរកខ្នាតដូចគ្នា គឺពុំមានការបង្កើតថ្មីអ្វីឡើយ៖ ខ្លួនភាជន៍រាងកាន់តែស្រដៀងសាជីជាងពេលមុន, មានកងមួយជុំនៅជើង, គម្របរាងប៉ោង។ នៅគល់កំពោយលើគម្រប មានក្បាច់ស្លឹកឈើមួយជុំ បន្ទាប់មកមានក្បាច់ធ្នូតបញ្ឈរមួយឬពីរជួរ។ កំពោយសំប៉ែតបន្តិច ដែលគេបន្តុបទៅលើរមូជីវាន់លើគ្នាជាថ្នាក់ៗ (មើលរូបលេខ៣០)។ រហូតមកទល់ពេលថ្មីៗនៅឡើយ ខ្មែរប្រើប្រាស់កោដ្ឋរបៀបនេះដើម្បីដាក់ធាតុដែលបានមកពីបូជាសពហើយកប់ក្បែរប្រាសាទផ្សេងៗនៅអង្គរ ឬនៅតាមវត្ត។ យើងជឿច្បាស់ថាគេផលិតកោដ្ឋទាំងនោះក្នុងតួនាទីដូច្នេះឯង តាំងពីដើមរៀងមក។ តើនេះជាឥទ្ធិពលនៃព្រះពុទ្ធសាសនា ដែលចាប់ផ្ដើមផ្សព្វផ្សាយនៅរាជ្យព្រះបាទជ័យវរ្ម័នទី៧មក ឬយ៉ាងណា? ម្យ៉ាងទៀតគួរកត់សម្គាល់ថា កោដ្ឋទាំងនេះ គេពុំដែល "បង្ហូច" ពោលគឺអារផ្ដាច់កចេញ ឬបោះឲ្យមានប្រហោងឡើយ មិនដូចសម័យមុននោះ ដែលរាល់ភាជន៍បញ្ចុះនៅផ្នូរតែងតែត្រូវគេធ្វើដូច្នោះ។ នេះកាន់តែធ្វើឲ្យយើងជឿខ្លាំងឡើងថា "កោដ្ឋ" ដែលពោលមកនេះ គេធ្វើឡើងសម្រាប់កិច្ចសពនេះឯង។

ក្នុងស្រទាប់ដីជំនាន់នេះ គេពុំប្រទះឃើញរបស់ដែលមានស្រទាប់រលោងពីរពណ៌ ឬស្រទាប់រលោងគូលែនទេ ក្រៅអំពីកោដ្ឋ។ ភាជន៍ដទៃទៀតមានស្រទាប់ "រលោង" ក្រាសណាស់, ស្អិតស្មើ, ស្រអាប់, មិនច្នុះចាំងឡើយ ឯពណ៌មានពីត្នោតក្រមៅខ្លាំង ដល់ពណ៌កៅស៊ូក្រាលថ្នល់។ ក្នុងករណីយ៍ចុងក្រោយនេះ ស្រទាប់រលោងមានភាពស្ដើង មើលទៅមានអារម្មណ៍ថាគេដុតជ្រុលភ្លើងទាល់តែ "ខ្លោច"។ ក្បាច់ទ្រនង់លំអ លែងមានទៀតហើយ ក្បាច់ផ្ដិតដោយរុញកូនកង់ពុម្ព ឬក្បាច់ចូតរាងរលកក៏ដូចគ្នាដែរ (មើលរូបលេខ៥៦១ និង៦០)។ បើទោះជាគេខំធ្វើក្បាច់ផ្ដិតឬចូតនេះ ក៏ពុំអាចលេចចេញពីក្រោមស្រទាប់រលោងដ៏ស្រអាប់ឈឹងនេះដែរ។ វត្ថុដែលឃើញច្រើនជាងគេ គឺក្រឡដាក់វត្ថុរាវ ដែលមានកបែករីកសាយទៅលើ, ឡិទស្រា និងក្រឡដាក់ធញ្ញជាតិ (មើលរូបលេខ៤៤, ៦២ និង៦៤)[៥៣]។ ដែលអាចចាត់ទុកថាជាការបង្កើតថ្មីក្នុងក្រុមនោះ មានតែក្បាច់តូចៗដែលគេបិទពីលើតួខ្លួនភាជន៍ ជាជួរជុំវិញ ដូចជាផ្កា, ផ្កាយ, ត្រីកោណត្រឡប់, ពងត្រី (មើលរូបលេខ៦២)។ គេលែងឃើញទៀតហើយនូវក្រុមទាំងមូលដែលមានខ្វចដាក់គ្រឿងក្រអូប, ដបតូចៗ និងភាជន៍តូចធ្វើជារូបសត្វ។ ភាជន៍ដែលនៅឃើញទៀត គឺមានតែកូនភាជន៍មូលសំប៉ែត, កូនភាជន៍មូលប៉ោង (មើលរូបលេខ២៧, ៥៦១ និង៦០) ព្រមទាំងអកកំបោររូបដំរីប៉ុណ្ណោះ។ ឯដំរីនោះសោត ក៏ធ្វើដោយគ្មានទឹកដៃសោះ។ ខ្លួនធំគម្រាំង, ជើងខ្លីហួសហេតុ, ក្បាលស្ទើរតែខ្ទិលសូនឲ្យបានសព្វគ្រប់។ បើពោលពីស្រទាប់រលោងវិញ គឺច្រើនតែដុតឡើងខ្មៅ ហើយផ្នែកខាងក្រោមពោះនិងជើងមានជ្រលក់ទឹកថ្នាំឡើងពណ៌សល្អក់ (មើលរូបលេខ៦៥, ៦៦ និង៦៧)[៥៤]។

---

[៥៣] នៅលើចម្លាក់មួយនៃថែវខាងក្នុងប្រាសាទបាយ័ន្ត –ចុងស.វ.ទី១៣– មនុស្សប្រុសម្នាក់ នៅលើសំពៅមួយ កំពុងបឹតភេសជ្ជៈតាមបំពង់ពក អំពីក្រឡមួយដែលមានរូបរាងដូចវត្ថុលេខ១៥៤ (មើលរូបនៅ *Southeast*, p. 23)។

[៥៤] ឧទាហរណ៍៖ *Legend*, no. 57។ វត្ថុលេខ ៨៩, ៩១ និង១១៩នៃពិព័រណ៍នោះ ប្រហែលជាផលិតនៅដើមជំនាន់នេះដែរ។ បំណែកដែលបានមកពីកំណាយនៅកម្រាលបាតប្រាសាទបាយ័ន្ត មានចុះផ្សាយនៅក្នុង J. Dumarçay និង B.P. Groslier: *Le Bayon*, Mémoires Archéologiques III-2, Paris: EFEO, 1973, pp. 19-21, pl. xx។

យើងជឿថាសិល្បៈកុលាលភាជន៍ដែលចុះស្រុតខ្លាំងនេះនៅត្រដរខ្យល់រហូតដល់ពាក់កណ្ដាលស.វ.ទី១៣។ រីឯកាលប្បវត្តិវិញ ក៏ពុំអាចរៀបចំតាមលំដាប់តទៅទៀតបានទេ ត្បិតនៅអង្គរ លែងមានសំណង់អំពីថ្មដូចមុន ហើយប្រភពទិន្នន័យរបស់យើងសង្កុញមកនៅត្រឹមតែភាជន៍ពេញរូបរាងខ្លះ ដែលប្រទះឃើញដោយចៃដន្យ តែដែលកំណត់កាលបរិច្ឆេទមិនបាន។ អាស្រ័យហេតុនេះ ខ្ញុំស្មានដោយមិនជាក់ច្បាស់ទេ ថាក្រុមលើកក្រោយបង្អស់ ផលិតឡើងនៅចុងស.វ.ទី១៣។ ក្នុងក្រុមនោះ មានកុលាលភាជន៍ប្រកបដោយស្រទាប់រលោងក្រាសខ្លាំង, ហូរចុះមកក្រោម ហើយចេញស្នាមក្រយៅរីស័យថ្មកែវ។ ពណ៌មានពីខ្មៅដល់បៃតងចាស់ ឯក្រយៅនោះពណ៌លឿងស្លាទ់ផែរ។ ដីឥដ្ឋដែលប្រើនោះពណ៌ខ្មៅ ហើយគេពង្រឹងជាមួយកំទិចអំបែងច្រើនលើសលុប ដែលបុកកិនយកពីភាជន៍ដុតខូច។

ក្រុមទាំងមូលខាងក្រោយនេះ អាចចែកចេញជាបួនក្រុមតូចៗ[៥៥]៖ ភាជន៍ដាក់ទឹកដែលករីកឡើង, ឱ្ទិនស្រា, ក្រឡដាក់ធញ្ញជាតិ។ នៅលើវត្ថុទាំងអស់នេះគ្មានក្បាច់លំអអ្វីឡើយ ក្រៅអំពីទ្រនង់មួយខ្សែ នៅពាត់ជុំវិញគល់ក។ វត្ថុក្រោយបំផុតគឺអកកំបោរ រូបដីរ៍ (មើលរូបលេខ៦៩)។ ដីរ៍នោះធ្វើក្ដង់ខ្លាំងណាស់ រហូតដល់យើងអាចគិតថាជាជ្រូកព្រៃផង[៥៦]។ ណាមួយទៀត យើងមិនច្បាស់ថាវត្ថុទាំងនេះជាផលិតផលអង្គរឡើយ ព្រោះភាគច្រើនបានមកពីភាគឦសានប្រទេសសៀម។ ប្រហែលមានតែក្បឿងប្រកបដោយស្រទាប់រលោងប៉ុណ្ណោះដែលគេនៅតែបន្តផលិតមួយរយៈពេលទៀត មើលទៅអាចរហូតដល់ស.វ.ទី១៦[៥៧]។

## ឡនៅតាមខេត្ត

មកទល់ពេលនេះ មានបញ្ហាពិសេសមួយដែលខ្ញុំពុំទាន់បានលើកឡើងនៅឡើយ គឺឡដែលនៅតាម "ខេត្ត" ហើយដែលគេរកឃើញថ្មីៗនេះជាអាទិ៍នៅខេត្តសុរិន្ទ្រ និងបុរីរាម ដែលជាទឹកដីខ្មែរពីជំនាន់មុន (សព្វថ្ងៃជាភាគឦសាន នៃប្រទេសថៃឡង់ដ៍)។ គួរគប្បីអានសំណេររបស់អ្នកស្រី Roxanna M. Brown ដែលបានសិក្សាអំពីបញ្ហានេះច្រើន ឬនៅទីនេះ ខ្ញុំនឹងពោលតែអំពីលក្ខណៈពិសេសនៃកុលាលភាជន៍តំបន់នោះ ដោយប្រៀបធៀបជាមួយកុលាលភាជន៍នៅអង្គរ។

ឡដែលយើងស្គាល់សព្វថ្ងៃ ហាក់ដូចជាមានដំណើរការនៅស.វ.ទី១១ ហើយប្រហែលជាប់តមកដើមស.វ.ទី១២ផង។ ក្រោយពីពេលដែលព្រះបាទចិត្រសេនា (ឬមហេន្ទ្រវរ្ម័ន) វាតទឹកដីនៅខាងជើង មកទល់គ.ស.៦០០មក តំបន់ស្ថិតនៅខាងជើងភ្នំដងរែក ពុំមានខ្មែរត្រួតត្រាទៀតទេ។ មកដល់រវាងឆ្នាំ៩០០ ទើបព្រះបាទយសោវរ្ម័នមកសាងប្រាសាទខ្លះៗ។ ទាល់តែដល់រាជ្យព្រះបាទរាជេន្ទ្រវរ្ម័ន –នៅពាក់កណ្ដាលទី២ នៃស.វ.ទី១០– ទើបខ្មែរកាន់កាប់រៀបចំទឹកដីនោះពេញលេញ ហើយទាល់តែដល់រាជ្យព្រះបាទសូរ្យវរ្ម័នទី១ រហូតទៅចុងស.វ.ទី១១ ទើបទឹកដីខ្មែររីកធំជាអតិបរមា។ ពេលចុងក្រោយនេះ រាជ្យអំណាចប្ដូរមកនៅភិម័យមួយរយៈ ក្រោមរាជ្យព្រះបាទជ័យវរ្ម័នទី៦ ជាពិសេសក្រោមរាជ្យព្រះបាទធរណីន្ទ្រវរ្ម័នទី១ (គ. ស. ១១០៧_១១១៣)។ ទោះបីយ៉ាងណា ក៏នៅអង្គរពេលនោះពុំឃើញមានសង់ប្រាសាទអ្វីដែលមានទំហំស្មើប្រាសាទភិម័យឡើយ។

កុលាលភាជន៍នៅទីនេះ ពុំខុសអ្វីខ្លាំងពីនៅអង្គរទេ[៥៨] ប៉ុន្តែគេសង្កេតឃើញថា ស្រទាប់រលោងពណ៌ត្នោតមិនសូវក្រាស ហើយស្អាបទៅមិនសូវរអិលល្អដូចនៅអង្គរសោះ ច្រើនតែស្រអាប់ ឬមួយមានទិដ្ឋភាព "ខ្លាច" ទៀតផង។ រីឯស្រទាប់រលោងប្រភេទ "គូលែន" ច្រើនតែពណ៌ស, ស្រអាប់, មានប្រហោងតូចៗជាច្រើន មិនសូវទាក់ភ្នែកទេ។ យើងមានវត្ថុច្រើនសម្រាប់សិក្សា ដែលជាកុលាលភាជន៍ដុតខូច បានមកពីគំនរនៅក្បែរឡដែលគេបោះបង់ចោល។ វត្ថុទាំងនេះច្បាស់ជាខ្មែរប្រាកដ យ៉ាងហោចណាស់ក៏មកពីឡបុរាណខ្មែរដែលនៅតាម "ខេត្ត" ដែរ។ បើប្រៀបធៀប

[៥៥] *Ceramics*, pl. M, no. 3 and pl. 23, no. 80; *Legend*, no. 93។

[៥៦] មានឧទាហរណ៍មួយទៀតនៅក្នុង *Ceramics*, pl. M, no. 4។

[៥៧] គួរកត់សម្គាល់ថាកុលាលភាជន៍សូគាំលោក ឃើញមាននៅអង្គរតែជំនាន់ពាក់កណ្ដាលទី២នៃស.វ.ទី១៣ ប៉ុណ្ណោះ ឯចំនួនក៏មិនលើសលប់ដែរ។ ខ្ញុំធ្លាប់ជីកបានសេឡាដុនសូគាំលោកចំនួនប្រមាណ១៥០ ព្រមទាំងកុលាលភាជន៍សុខោទ័យប្រមាណ៥០។ ក្នុងជំនាន់ប្រហែលគ្នានេះដែរ យើងមានរបស់របរ Yuan ពណ៌ខៀវនិងស ព្រមទាំងផលិតផលវៀតណាមពណ៌ខៀវនិងស ដោយមានបាតពណ៌ត្នោតផង។

[៥៨] B.P. Groslier, *Prospection des sites khmers du Siam...*, *op.cit.*។

ប្រាសាទខ្មែរនៅទីនេះ ជាមួយប្រាសាទនៅអង្គរ ទើបយើងយល់ថាជាការធម្មតាទេ ដែលជាទូទៅកុលាលភាជន៍នៅឯណោះមានគុណភាពទាបជាងនៅអង្គរ។ ក្រៅតែពីប្រាសាទភិម័យ និងប្រាសាទភ្នំរុង ប្រាសាទទាំងអស់នៅតំបន់ស្ទឹងសេមូលតែងតែអន់ជាងនៅអង្គរ ក្នុងទស្សនៈស្ថាបត្យកម្ម, ក្បូរក្បាច់លំអ, ចម្លាក់ឬអាចពោលដូចពីលើមកថាមានលក្ខណៈ "ខេត្ត"។ តាមពិតទៅ យើងប្រទះឃើញកុលាលភាជន៍ដែលមានគុណភាពកម្រិតស្មើអង្គរនៅតំបន់នេះដែរ ប៉ុន្តែបើបញ្ច្រាសមកវិញ កុលាលភាជន៍ដែលមានកម្រិតគុណភាពដូចតំបន់នេះ ជាទូទៅពុំមានឃើញនៅអង្គរឡើយ។ ឃើញច្បាស់ថាមិនអាចប្រជែងនឹងរាជធានីបានដូច្នោះមែន។

នៅអង្គរ ក្រៅអំពីចានក្បានប្រើប្រាស់សម្រាប់អាហារ របស់របរអំពីកុលាលភាជន៍មិនសម្បូណ៌ទេ។ គេឃើញមានវត្ថុខ្លះដែរ ដូចជាស័ង្ខដែលត្រូវមានជាចាំបាច់ក្នុងពិធីផ្សេងៗ។ ខ្យងស័ង្ខធម្មជាតិពិតប្រាកដប្រហែលជាពិបាករក ដូច្នេះហើយបានជាគេផលិតជាកុលាលភាជន៍ ដែលអាចចែកចេញជាពីរក្រុម។ ក្នុងក្រុមទីមួយ ស័ង្ខច្រើនតែមានស្រទាប់លោង ប្រើសម្រាប់ច្រួចទឹកក្នុងពិធី។ គេសិតអំពីសម្រិតដែរ។ បើប្រៀបជាមួយស័ង្ខសាច់ចានស័ង្ខសម្រិតដែលយើងប្រទះឃើញសន្ទឹកសន្ទាប់ មានសោភណភាពល្អជាងឆ្ងាយ។ ក្នុងក្រុមទីពីរ នៅគូថស័ង្ខតែងមានចោះប្រហោង។ តាមស្នាមមើល ប្រហែលគេចោះសម្រាប់ដាក់អណ្ដាតដើម្បីផ្លុំនៅក្នុងពិធី។ ស័ង្ខនៅក្រុមនេះច្រើនតែគ្មានស្រទាប់លោងទេ។ នេះប្រហែលជាដីដុតរឹងឥតស្រទាប់លោង ធ្វើឱ្យសម្លេងល្អជាងក៏មិនដឹង។ គួរបញ្ជាក់ថា យើងបានប្រទះឃើញពុម្ពតែមួយគត់ ធ្វើពីដីដុតធម្មតា សម្រាប់ផលិតព្រះបដិមាតូចៗ។ ធម្មតាពុម្ពរបៀបនេះធ្វើអំពីសម្រិត។ រីឯរូបព្រះ (ទេពផ្សេងៗ) ស្ទើរតែទាំងអស់ –ដែលតែងតែជាដីឥដ្ឋដុត តែមិនមានស្រទាប់លោង– ផលិតនៅចុងស.វ.ទី១២ និងសម័យក្រោយមក។ មានរបស់ម្យ៉ាងនោះចម្លែកណាស់ រាងជាផ្លែឈើស្រួចចុងម្ខាង, ប្រហោងនៅចុងនោះ, ហើយមានរង្វះតូចមួយនៅចុងម្ខាងទៀត[៥៩]។ វត្ថុនេះប្រហែលគេប្រើសម្រាប់ប្រោះព្រំទឹក ដោយគេយកម្រាមដៃមួយខ្ទប់រង្វះនោះ ដើម្បីឱ្យទឹកស្រក់តក់ៗ។ មានតែមួយទេដែលឃើញនៅអង្គរ ហើយដែលយើងកំណត់បានថា ធ្វើនៅស.វ.ទី១១។ ប៉ុន្តែមានក្រុមទាំងមូលមួយក្នុងប្រភេទនេះ ដែលឃើញនៅតំបន់ភ្លៀសានប្រទេសសៀម។ ក្នុងនោះជួនកាលគេធ្វើរូបក្រី ឬសត្វស្លាប (មើលរូបលេខ៧៣ ដែលអាចផលិតជំនាន់ក្រោយមកទៀតផងក៏សឹងថាបាន)។

ឡនៅតំបន់បណ្ដោយស្ទឹងសេមូល ផលិតវត្ថុរូបរាងប្លែកច្រើន ឯចំនួនក៏ច្រើនទៀត។ យើងសង្កេតឃើញមានលិង្គភ្ជាប់នឹងបល្ល័ង្ក, ចង្កៀងប្រេង[៦០], កណ្ដឹង (មើលរូបលេខ៣៤ខ) ព្រមទាំងក្បាល់តូចល្អិតដែលប្រហែលជាប្រើសម្រាប់កិនគ្រឿងក្រអូប ឬថ្នាំ[៦១]។ វត្ថុរបៀបនេះមាននៅអង្គរដែរ ប៉ុន្តែនៅទីនេះមានទំហំសមល្មម[៦២]។ រូបរាងវត្ថុខ្លះគេនិយមប្រើច្រើនជាងនៅអង្គរ។ មានជាអាទិ៍គឺរបស់ដាក់ថ្វាយព្រះ ដែលជាទូទៅគឺកូនខ្ទះកូនតន្លាប់ព្រមទាំងចានក្បានតូចៗដែលមានរូបសត្វ។ នៅអង្គរ វត្ថុប្រភេទនេះច្បាស់ជាគេនិយមធ្វើអំពីលោហធាតុ មានប្រាក់ជាដើម។

បើពិចារណាលើវត្ថុទាំងអស់នេះទៅ ឃើញថាប្រជាជនសាមញ្ញគ្មានមធ្យោបាយទិញកុលាលភាជន៍ចិន ឬវត្ថុអំពីលោហធាតុឡើយ។ ម៉្លោះហើយ វត្ថុកុលាលភាជន៍ប្រភេទនេះ ដែលមានតម្លៃថោកជាង អាចយកមកធ្វើជារបស់ "ជំនួស" បាន។ រីឯផលិតផលក៏កើនទៅតាមតម្រូវការនេះ។ និយាយឱ្យខ្លីមក កុលាលភាជន៍ជាគ្រឿងប្រាក់នៃអ្នកក្រ។ នេះជាសម្មតិកម្មក៏ពិតមែន តែមានមូលដ្ឋានរឹងមាំ។ ទៅអនាគត បើប្រទះឃើញឡតាមខេត្តនេះច្រើនទៀត ហើយក្នុងការសិក្សាមានធ្វើស្ថិតិរបស់របរផង យើងនឹងដាក់ប្រាកដក្នុងចិត្ត។

វត្ថុរូបសត្វ ចោទឡើងនូវបញ្ហាពិសេសមួយ។ នៅអង្គរ យើងបានប្រទះតែរូបសេះមួយគត់ ដែលមានស្រទាប់លោងពណ៌បៃតងប្រភេទគួលែន។ នៅព្រះរាជវាំង យើងប្រទះក្រុមមួយមានត្រីសំប៉ែតតូចៗ ដែលមានស្រទាប់លោងដូចគ្នា មានប្រហោងមួយចោះនៅស្រកីសម្រាប់ចងព្យួរមើលទៅគួរឱ្យចាប់ចិត្ត។ តើនេះជាតុក្កតា ឬមួយជាគ្រឿងការពារខ្លួន? ចំណែកកុលាលភាជន៍រូបសត្វដែលប្រើប្រាស់ជាចានក្បាន តែងឃើញធ្វើជារូបសត្វស្លាបប្រភេទមៀម, កូនមាន់, ឬដំរី។ ជួនកាលមានទន្សាយ, គីង្គក់ឬអណ្ដើក។ សត្វទាំងប៉ុន្មានពុំដែលមានអ្វីជិះពីលើទេ ហើយសុទ្ធសឹងប្រើជាចានក្បាន ពោលគឺដាក់គ្រឿងអ្វីផ្សេងៗ។ មានតែសេះនិងត្រីខាងលើនេះទេ ដែលជាវត្ថុតាន់ មិនមែនសម្រាប់ផ្ទុកអ្វីមួយ។ ក្រៅអំពីគោដ្ឋនៅស្រះស្រង់ដែលបានរៀបរាប់ពីមុនមកនោះ នៅអង្គរឥតដែលមានឃើញចានក្បានអ្វីដែលធ្វើជារូបមនុស្សឡើយ។

---

[៥៩] *Legend*, nos. 100 to 103។

[៦០] តាមពាក្យថា "ចង្កៀង" ខ្ញុំសំដៅចានតូចម្យ៉ាងដែលមានមាត់ចង្អូរខ្ញីចេញទៅក្រៅចំនួនមួយឬបី។ ចង្អូរខ្ញី ដែលកើតឡើងដោយគេចាប់ច្បិចគែមចាននោះ មើលទៅច្បាស់ជាសម្រាប់ទ្រប្រឆេះឱ្យចេញក្រៅចាន។ ផ្នែកដែលមិនឆេះ នៅត្រាំខ្លាញ់ក្នុងចាន។ នៅភូមិភាគភ្លៀសានប្រទេសថៃឡង់ដ៍ គេប្រទះឃើញវត្ថុប្រភេទនេះ ដែលផលិតនៅស.វ.ទី១១ ប្រកបដោយស្រទាប់លោងពណ៌បៃតងខ្ចី។

[៦១] *Legend*, no. 104។

[៦២] *Ceramics*, pl. 24, no. 84។

រីឯនៅស្រុកសៀមវិញ យើងសង្កេតឃើញថាមិនត្រឹមតែសម្បុណិចានក្បានរូបសត្វប្រកបដោយរូបរាងប្លែកៗទេ គឺថែមទាំងសម្បុណិកុលាលភាជន៍តាន់ ធ្វើជារូបសត្វដែលពុំប្រើប្រាស់ជាគ្រឿងផ្ទុកទៀតផង។ ក្រៅអំពីសត្វស្លាបនិងដំរី[៦៣] គេឃើញមានសេះ *(មើលរូបលេខ៧១)*, ជ្រូកព្រៃ[៦៤], ត្រី[៦៥] *(មើលរូបលេខ៧០ និង៧៣)*, ទន្សាយ *(មើលរូបលេខ៧២)*[៦៦], ប្រើស[៦៧], ឆ្មា[៦៨] និងពង្រូល[៦៩]។ បញ្ហាដែលចោទឡើងគឺ យើងពុំស្គាល់តួនាទីនៃរបស់ទាំងអស់នោះសោះ។ តើគេប្រើជាគ្រឿងតង្វាយក្នុងកិច្ចបូជាផ្ទាល់ខ្លួន, ជាល្បែងតុក្កតា, ជាតង្វាយទៅសព ឬជាវត្ថុសម្រាប់បម្រើមន្តអាគម?

ក្នុងបញ្ហាឥទ្ធិពលខ្មែរ យើងដឹងថាមានទំនាក់ទំនងខ្ជាប់ខ្ជួនរវាងតំបន់បណ្តោយស្ទឹងសេមូល និងអាណាចក្រថៃផ្សេងៗនៃប្រទេសសៀមតាំងពីដើមប្រវត្តិសាស្ត្រនៃអាណាចក្រអស់ទាំងនោះមក។ យោងតាមនេះ យើងអាចគិតថាប្រពៃណីកុលាលភាជន៍ខ្មែរដែលតាំងទីរឹងមាំនៅតំបន់ខាងជើងស្ទឹងសេមូល ប្រហែលបានដើរតួនាទីសំខាន់ ក្នុងការផ្តួចផ្តើមឲ្យមានកុលាលភាជន៍ថៃ ដែលរីកចម្រើនខ្លាំងក្រោយមកនៅ"សួគ៌ាលោក"។ ឥទ្ធិពលសេមូល ប្រហែលខ្លាំងក្លាដូចឥទ្ធិពលចិនលើកុលាលភាជន៍សួគ៌ាលោកដែរ។

ចានក្បានព្រមទាំងវត្ថុរូបសត្វ ដែលទើបនឹងពោលមកនេះជួយយើងច្រើនដែរ ក្នុងការបន្ថយភាពច្របូកច្របល់ដែលយើងមានក្នុងវិស័យកុលាលភាជន៍។ ខ្លះមានទំហំធំដូចជាវត្ថុលេខ១៣៤ក, ៧០ និង៧៣, នៃពិព័រណ៍នេះ។ ខ្លះទៀតរូបរាងមិនចំជាខ្មែរទេ *("មិនមែនខ្មែរ" នៅទីនេះសំដៅថាមិនដែលឃើញមាននៅអង្គរ)*។ ឧទាហរណ៍រូបទន្សាយ *(មើលរូបលេខ៧២)* ដែលត្រចៀកទាំងពីរជាប់គ្នា ហើយនៅចំពីមុខមិនសូវដូចក្នុងធម្មជាតិ *(ចូរប្រៀបធៀបជាមួយទន្សាយលេខ១៣៣ ដែលធ្វើដូចមែនទែន ប្រកបដោយលក្ខណៈខ្មែរពិត)*។ ពួកខ្លះទៀត ដូចបានពោលមករួចហើយ មិនមែនជាចានក្បាន ពោលគឺវត្ថុផ្ទុកទេ ប៉ុន្តែជារូបតាន់។ ឯសេចក្តីសង្កេតឬអធិប្បាយលើនោះ អាចយកកំណត់ក្រោមទំព័រលេខ៦៣ ទៅលេខ៦៩ មកអនុវត្តន៍បាន។

បើមើលតែមួយភ្លែត គេអាចឲ្យកាលបរិច្ឆេទថានៅផ្នែកទី២ នៃស.វ.ទី១១ និងដើមស.វ.ទី១២។ លុះសង្កេតយូរបន្តិច ទើបឃើញថាវត្ថុទាំងនេះ មិនមែនមានពណ៌ពីរខុសដាច់គ្នា ដូចផលិតផលអង្គរទេ ប៉ុន្តែគឺជាលំនាំពណ៌ត្នោតតែមួយ ដែលភាពខ្ចីនិងដាំធ្វើឲ្យមានទម្រង់ពីរលាយគ្នាជារលកៗ។ បើយកកុលាលភាជន៍ដែលគេស្គាល់ច្បាស់នៅសួគ៌ាលោកមកប្រៀប ឃើញថាមានភាពដូចគ្នាច្រើន[៧០]។ សមត្ថិកម្មរបស់ខ្ញុំមានដូចតទៅ៖ វត្ថុទាំងអស់នេះ ផលិតឡើងនៅឡមួយក្រុម –ឬមួយជំនាន់– ដែលតពូជពង្សពីប្រពៃណីឡខ្មែរនៅតាមតំបន់បណ្តោយស្ទឹងសេមូល។ ក្រុមឡនេះប្រហែលរីកចម្រើនឡើងនៅស.វ.ទី១៣_១៤ ហើយប្រហែលបានជះឥទ្ធិពល ឬបានជួយរៀបចំដំណើរឲ្យអនាគតសិល្បៈកុលាលភាជន៍នៅសួគ៌ាលោក។ ក្រុមឡដែលមានដោយសមត្ថិកម្មនេះ ខ្ញុំស្នើឲ្យឈ្មោះថា "ឡស្លានចម្លង"។ ជាការពិតហើយ ទាល់តែធ្វើការស្រាវជ្រាវជ្រៅជ្រះតទៅទៀត ទើបការស្មាននេះអាចយកជាការបាន។

ទោះបីយ៉ាងណា ក៏រូបសត្វដែលរៀបរាប់ខាងលើ ពុំមែនជាខ្មែរដែរ ពោលគឺពុំមែនផលិតសម្រាប់មនុស្សដែលរស់នៅក្នុងក្របខណ្ឌអារ្យធម៌អង្គរ។ យើងនៅតែពុំទាន់ដឹងច្បាស់អំពីតួនាទីនៃវត្ថុទាំងនោះនៅឡើយ។ យើងតែងអះអាងថា បដិមាតូចៗដាច់ព្រះកេសដ៏ល្បីល្បាញដែលរកឃើញនៅសួគ៌ាលោក គេប្រើសម្រាប់មន្តអាគមអូមអាមផ្សេងៗ។ ក៏ប៉ុន្តែគ្មានភស្តុតាងអ្វីមួយ ដែលឲ្យទម្ងន់លើសមត្ថិកម្មនេះនៅឡើយទេ។ ម្យ៉ាងទៀត

---

[៦៣] ដំរីយ៉ាងល្អ ដែលមានបង្ហាញរូបនៅ *Legend,* no. 51, ខ្ញុំយល់ថាមិនមែនជាផលិតផលខ្មែរទេ។ វត្ថុនោះបង្ហាញអំពីការទាក់ដំរី។ គេទាក់កូនដំរីព្រៃនឹងព្រ័ត បានហើយគេចងវាភ្ជាប់នឹងខ្លួនមេដំរី ដែលសាំងស្រាប់។ មេនោះវាយកូនដំរីព្រៃទាល់តែខ្លាច ស្តាប់បង្គាប់ខ្លួន។ រូបដែលពោលនេះ បង្ហាញអំពីចំណុចនេះឯង។ ប៉ុន្តែនៅស្រុកខ្មែរ យើងពុំដែលប្រទះឃើញរូបសត្វអ្វីមួយ ដែលមានសត្វតូចជាងខ្លួនកៀកគ្នា *(ឬក៏មានមនុស្សជិះពីលើ)* ឡើយ។ ចូរប្រៀបធៀបជាមួយរូបជាច្រើនដែលបានមកពីសួគ៌ាលោក ហើយដែលមានលំនាំលក្ខណៈដូចគ្នាដែរ៖ *Ceramics,* pl. 35, no. 121 *(គេបានចាត់ត្រឹមត្រូវថាជារបស់សួគ៌ាលោក)*។

[៦៤] *Legend,* no. 53។

[៦៥] *Legend,* nos. 101, 103។

[៦៦] *Legend,* nos. 41, 45, 55, និង *Southeast,* p. 38, no. 11។

[៦៧] *Legend,* no. 52, និង *Southeast,* p. 36, no. 12។

[៦៨] *Legend,* nos. 46, 47, 48, 94, និង *Trade,* p. 217, no. 236។

[៦៩] *Legend,* no. 56។

[៧០] ឧទាហរណ៍ *Ceramics,* pl. 33, no. 116; pl. 35, no. 121; pl. R, no. 1; *Legend,* nos. 177. 179 to 184; *Trade,* p. 237, no. 264; p. 287, no. 250; *Export,* p. 103, no. 193, ។ល។ ក្រៅពីនេះ សូមអាន Aalderink. *Ceramic Wares of Siam,* (Aalderink, Amsterdam, 1978), *passim.*។

បើតាមខ្ញុំដឹង កូនបដិមាទាំងនេះ កាលគេបានមក យើងពុំដឹងថាយកចេញពីកន្លែងណា ព្រមទាំងស្រទាប់ដីណាពិតប្រាកដឡើយ។ តាមពិតទៅ បើយើងគិតថាជាវត្ថុតង្វាយសម្រាប់ពិធីសព ក៏អាចស្មានបាន។ ប្រសិនបើដូច្នោះមែន យើងអាចស្មានតទៅទៀតថា បដិមាតូចៗដាច់ព្រះកេសទាំងនេះ សម្បូណ៌ដោយសារទទួលការនិយមប្រើពីសាសន៍ថៃ ដែលសម័យនោះកំពុងមានអំណាចឡើងខ្លាំងក្លា នៅតំបន់នេះតែម្ដង។ ហើយប្រសិនបើយើងងាកទៅរកប្រភពដើមផ្សេងៗ នៃជាតិសាសន៍ថៃ ប្រហែលជាក្នុងថ្ងៃណាមួយយើងនឹងមានភស្តុតាងថា ពួកគេបាននាំមកពីប្រទេសចិន នូវកុលាលភាជន៍ *ming chi*...។

## រកស៊ីដូរញូសប្តិ... ឬដូរញូក្ដីស្រម័យ

ឡូវដែលនៅតាមខេត្តផ្សេងៗនោះ មានសារៈសំខាន់ម្យ៉ាងទៀតចំពោះឈ្មួញឬម្ចាស់សមុច្ច័យ។ កុលាលភាជន៍អង្គរស្ទើរតែទាំងអស់តម្កល់នៅសារមន្ទីរជាតិភ្នំពេញ និងជាពិសេសនៅអភិរក្សអង្គរ ព្រោះសុទ្ធសឹងរកឃើញដោយបុរាណវិទូព្រមទាំងអភិរក្សផ្សេងៗ។ ក្នុងរយៈពេលដែលគេបំពេញការងាររបស់គេ។ ចំពោះសមុច្ច័យនៃអភិរក្សអង្គរ រហូតមកដល់ឆ្នាំ ១៩៧០ កុលាលភាជន៍សុទ្ធសឹងបានមកពីកំណាយ ហើយមិនមែនយកមកសម្រាប់ទុកលក់ទេ។ មានសមុច្ច័យសំខាន់មួយដែរ តម្កល់នៅសារមន្ទីរជាតិបាងកកនិងនៅសារមន្ទីរខេត្តខ្លះៗទៀតនៃប្រទេសសៀម។ មួយចំនួនទៀតពុំសូវមានសារៈសំខាន់ប៉ុន្មានឡើយ ហើយដែលសារមន្ទីរខ្លះបានមក ក្នុងក្របខណ្ឌនៃការផ្លាស់ប្ដូរសមុច្ច័យ ដូចជានៅ Musée Guimet (Paris), Musium Seni Asia (University of Malaya), National Museum of Tokyo, Musée du Cinquantenaire (Brussels) ជាដើម។ របស់របរខ្លះ ឯកជនផ្សេងៗទិញបាននៅភ្នំពេញ, សៀមរាប ឬបាត់ដំបង ដោយឆ្លៀតឱកាសដែលគេទើបនឹងប្រទះយកបានដោយចៃដន្យ។ ប៉ុន្តែជាទូទៅ របស់ទាំងអស់ គេតែងតែយកមកស្នើលក់ឱ្យអភិរក្សអង្គរជាមុនសិន។ ស្ថាប័ននេះជ្រើសរើសវត្ថុសំខាន់ ហើយទិញដោយឱ្យតម្លៃខ្ពស់។ ទើបតែក្រោយមក ចំនួនទេសចរកើនឡើងច្រើន ហើយអ្នកលក់ក៏កាន់តែសម្លឹងមើលទឹកប្រាក់ខ្លាំងជាងមុន។ ដូនជាព្រឹត្តិការណ៍ឆ្នាំ ១៩៧០ កើតឡើងផងការគ្រប់គ្រងលែងមានភាពតឹងតែង ធ្វើឱ្យរបស់ខ្លះចេញទៅក្រៅ នៅតាមហាងលក់បុរាណវត្ថុផ្សេងៗ។

រីឯលទ្ធផល គឺកុលាលភាជន៍ខ្មែរស្ទើរតែទាំងអស់ដែលនៅតាមសមុច្ច័យនានា សុទ្ធសឹងមកពីខេត្តខ្មែរ ដែលសព្វថ្ងៃស្ថិតនៅដីសៀម។ ពិព័រណ៍នេះជាតឹកតាងស្រាប់ ដូច្នេះការយល់ស្មាននេះពុំខុសឡើយ។ ខ្ញុំទើបតែបានបង្ហាញថា ទោះបីជាផលិតនៅតាមខេត្តក៏ដោយ របស់របរទាំងអស់នេះជាកុលាលភាជន៍ខ្មែរ។ ផលិតផលដែលមានលក្ខណៈអង្គរពិតប្រាកដ គេរកឃើញមាននៅតំបន់បណ្ដោយស្ទឹងសេមូល។ ប៉ុន្តែយ៉ាងណាក៏ឈ្មួញឬឯកជនជាម្ចាស់សមុច្ច័យ មើលឃើញតែទិដ្ឋភាពមួយនៃសិល្បៈនេះប៉ុណ្ណោះ ហើយមិនមែនជាទិដ្ឋភាពដែលសំខាន់ផង។ ក្នុងន័យនេះ យើងអាចឧបមាថា ដើម្បីក្រេបជញ្ជក់សោភណភាព ឬវិជ្ជាអំពីកុលាលភាជន៍ចិន –រាប់តាំងពីសន្តតិវង្ស Han ដល់ Song– យើងមានតែកុលាលភាជន៍ដែលផលិតនៅវៀតណាមប៉ុណ្ណោះដើម្បីយកមកសិក្សា។

ផលពុំប្រសើរផ្សេងទៀតក៏មានដែរ។ ក្នុងការធ្វើកំណាយនានា ខ្ញុំធ្លាប់ប្រទះជារឿយៗនូវគម្រប ឬធ្នុកដែលស្ថិតនៅដាច់តែឯង ត្បិតដោយសារទំហំតូចហើយណែន វត្ថុទាំងអស់នេះធន់នឹងការបាក់បែកបាន។ មកទល់ពេលនេះ ខ្ញុំពុំទាន់យល់ច្បាស់អំពីការប្រើប្រាស់គម្របខ្លះឡើយ។ ប៉ុន្តែអ្នកដូរញូវត្ថុបុរាណ មិនសូវខ្វល់ខ្វាយគិតរឿងអស់ទាំងនេះទេ។ ឱ្យតែតួខ្លួន និងគម្របណាផ្គុំទៅត្រូវគ្នាល្មមៗ ហើយពណ៌ប្រហាក់ប្រហែលគ្នា គេបង្ហាញថាជាគូគ្នាត្រឹមត្រូវ ដើម្បីលក់បានថ្លៃ។ លទ្ធផលនៃការផ្គុំផ្គុំនោះ ជួនកាលចម្លែកមែនទែន...។

លើសពីនោះទៅទៀត ឈ្មួញដ៏មានទេពកោសល្យខ្លះយករបស់បុរាណ ប្រើការមិនកើតដោយសារដុតខូច ហើយដែលគេរកឃើញនៅភាគ "ឦសាន" មកច្នៃផ្សំតបន្ថែមនិងរបស់ផ្សេងៗ (ពួកគេតែងបន្លំធ្វើវត្ថុពីសម្រិតរបៀបនេះរួចទៅហើយ)។ ហេតុនេះគេបង្កើតវត្ថុចម្លែកមិនប្រក្រតីក្រងេងក្រងោងវិស័យដូចបិសាច។ ឧទាហរណ៍ យកផ្នែកគូថនៃក្រឡមួយ មកដាក់ឱ្យក្រឡមួយទៀត ជួនកាលថែមទាំងកែគូថនោះឱ្យទៅជាកឬជាធ្នុកវិញផងក៏មាន។ ឧទាហរណ៍ដែលសម្បូណ៌ជាងនោះទៅទៀត គឺថូរាងដើងទៀន, ដប, ក្រឡតូចៗ ដែលជារបស់ខ្មែរបុរាណពិត ប៉ុន្តែដែលគេបន្លំបន្ថែមក្បាលសត្វមួយ (ឬក្បាលច្រើន) នៅម្ខាងក្អែង ព្រមទាំងកន្ទុយសត្វនោះនៅម្ខាងទៀត។ ខ្ញុំហ៊ានអះអាងថា វត្ថុប្រភេទនេះទាំងប៉ុន្មានដែលខ្ញុំធ្លាប់បានកាន់ពិនិត្យក្នុងដៃ ព្រមទាំងវត្ថុប្រភេទដូចគ្នាភាគច្រើនដែលខ្ញុំបានឃើញតាមរូបថត (ក្នុងករណីយ៍ក្រោយនេះ ខ្ញុំមិនពោលដាច់ណាត់ទាំង

ស្រុងទេ) *សុទ្ធសឹងជារបស់ក្លែងក្លាយ*[៣១]។ គ្មានបំណែកណាមួយដែលរកឃើញនៅអង្គរ អាចធ្វើឲ្យយើងយល់ថាមានរបស់រូបរាងបែបនេះឡើយ។ គេមិនត្រូវច្រឡូកច្រឡំទាល់តែសោះ ជាមួយកុលាលភាជន៍ដែលមានរូបសត្វ ហើយដែលគេស្គាល់ថាជារបស់ខ្មែរបុរាណពិត។ របស់បុរាណពិតនេះ តែងតែមានកំពស់កំពទំហំសមគ្នា, មិនច្ពង, ហើយមិនដែលមានផ្នែកភ្ជាប់បន្ថែម ធ្វើឲ្យច្ពងទើសភ្នែករបៀបនោះឡើយ។ ដូច្នោះការប្រុងប្រយ័ត្នត្រូវតែមានជានិច្ច។

មានករណីយ៍មួយឬពីរ ដែលវត្ថុនោះជារបស់បុរាណពិត។ ប៉ុន្តែក្នុងករណីយ៍នោះ គេពុំអាចថាជារបស់ "ខ្មែរ" បានទេ។ ខ្ញុំយល់ថាផលិតឡើងដោយពពួកឡ "ស្លានចម្លង" ដែលបានពោលពីលើមក គឺចេញពីមណ្ឌលផលិតដែលនៅក្នុងវង្ស៍អារ្យធម៌នៃរដ្ឋ "ថៃ" នានា។

ក្នុងការផ្តើមសិក្សាដ៏ខ្លីនេះ ខ្ញុំនាំចោទដោយចេតនានូវបញ្ហាជាច្រើន គឺច្រើនជាងដំណោះស្រាយ។ តើយើងអាចទាញសេចក្តីសន្និដ្ឋានបណ្តោះអាសន្នយ៉ាងណាខ្លះ?

ក្នុងវិស័យបច្ចេកទេសនិងសិល្បៈ កុលាលភាជន៍មានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ គ្មានបញ្ចេញភាពស្រស់ស្អាតអ្វីឡើយ។ ម្យ៉ាងដោយសារថា សូម្បីតែនៅក្នុងការប្រើប្រាស់រាល់ថ្ងៃជាធម្មតា ភាជន៍ដែលធ្វើពីរុក្ខជាតិ (ដូចជាកញ្ច្រែង, ឃ្លោកដាក់ទឹក...) គឺគេនិយមជាទូទៅ។ ម្យ៉ាងទៀតបើគេប្រើវត្ថុមានតម្លៃជាងនោះបន្តិច ឬវត្ថុប្រណិត គេនិយមវត្ថុសិតពីលោហធាតុជាង ឬមួយក៏គេប្រើចានក្បានទាំចូលពីចិនតែម្តង ត្បិតមានសោភណភាពជាងកុលាលភាជន៍ខ្មែរឆ្ងាយ។ តាមពិតទៅ ក្នុងពពួកកុលាលភាជន៍ដុតក្លី គេនិយមតែវត្ថុបីប្រភេទប៉ុណ្ណោះ៖ ក្រឡឬពាងធំតូចសម្រាប់ផ្ទុកអាហារ, វត្ថុសម្រាប់ប្រើក្នុងពិធីនៅតាមប្រាសាទ (ក្នុងពួកនេះក៏គេចូលចិត្តប្រើលោហធាតុដែរ), របស់របរតូចៗប្រើប្រាស់សម្រាប់ពិធីក្នុងផ្ទះ ឬមួយតុក្កតា។ ពពួកចុងក្រោយនេះអាចពោលប្រដូចថាជា "គ្រឿងប្រាក់នៃអ្នកក្រ"។

បច្ចេកទេសប្រើកង់វិលព្រមទាំងរូបរាងកុលាលភាជន៍សម្រាប់ប្រើក្នុងពិធី ចូលមកកម្ពុជាតាមរយៈហ្វូណាន់។ តាំងពីដើមអារ្យធម៌ខ្មែរមក –ពោលគឺពីចុងស.វ.ទី៦– កុលាលភាជន៍ដែលមានលាបពណ៌ចាប់កំណើតឡើង ហើយប្រភេទនេះនៅមានបន្តរហូតក្នុងរូបរាងមួយចំនួនតូច។ ភាជន៍ដីដុតដែលមានមកតាំងពីសម័យបុរេប្រវត្តិក៏នៅតែផលិត ហើយគេនិយមប្រើរហូតដែរ។ លុះមកដល់អាណាចក្រអង្គរ ទើបបច្ចេកទេសមានការប្រែប្រួលខ្លាំង ដោយសារគេចាប់ផលិតភាជន៍ដែលមានស្រទាប់រលោង។ គ្មានអ្វីគួរសង្ស័យទេ នេះគឺជាឥទ្ធិពលចិន។ គឺចាប់អំពីនោះមកហើយ ដែលសិល្បៈកុលាលភាជន៍ខ្មែរ មានទិសដៅរបស់ខ្លួនពិតប្រាកដឡើង។

ខ្ញុំមានឱកាសពោលច្រើនដងដែរ អំពីរូបរាងនៃរបស់របរចិនដែលឲ្យគំនិតមកស្មូនខ្មែរ។ នរណាស្គាល់កុលាលភាជន៍ចិនច្បាស់ គ្រាន់តែមើលភ្លាមក៏យល់ដែរ។ ឥទ្ធិពលចិននេះ ឃើញកាន់តែច្បាស់ណាស់ទៅទៀត បើយើងប្រៀបធៀបកុលាលភាជន៍នៅស.វ.ទី៩ព្រមទាំងសតវត្សក្រោយមកទៀត ជាមួយភាជន៍ដីដុតនឹងភាជន៍លាបពណ៌នៅសម្បូណ៌ព្រៃគុក។ យើងដឹងច្បាស់ថា យ៉ាងណាក៏គេមិនអាចធ្វើត្រាប់កុលាលភាជន៍ចិនឲ្យដូចឡើយ។ បច្ចេកទេសទូទៅ, ការជ្រើសរើសដីឥដ្ឋ, ការលាយទឹកថ្នាំសម្រាប់ស្រទាប់រលោង, ការសង់ឡ, របៀបដុតភ្លើង... ទាំងអស់នេះទាល់តែបង្ហាញឲ្យឃើញជាក់ស្តែងទើបទៅរួច[៣២]។ រហូតមកទល់ពាក់កណ្តាលស.វ.ទី១១ យើងអាចឃើញមេរៀនដែលទទួលពីចិននៅលើផលិតផលខ្មែរ។ យើងស្ទើរតែអាចចាត់ទុកកុលាលភាជន៍ដុតក្លីនៃអង្គរថាជាសាខាក្រៅប្រទេសមួយនៃកុលាលភាជន៍ចិន។ នេះមិនខុសអ្វីពីកុលាលភាជន៍នៅវៀតណាមនិងកូរ៉េ ហើយក្រោយមកទៀតនៅ សួគាំលោក (ប្រទេសសៀម) ឡើយ។

ចំណុចនេះមានសារៈសំខាន់សមល្មមនឹងយើងធ្វើការវែកញែកបន្តិច។ អ្នកស្រាវជ្រាវទាំងអម្បាលមាណតែងតែពោលបញ្ជាក់អំពីឥទ្ធិពលនៃឥណ្ឌាមកលើកម្ពុជា។ ប្រាសាទនិងសិលាចារិកទាំងឡាយជាភស្តុតាងច្បាស់ ដូច្នេះគ្មានអ្វីនឹងឲ្យយល់ផ្ទុយពីនេះទេ។ រហូតមកដល់ស.វ.ទី១៤ ព្រាហ្មណ៍ក្លីង្គណាម្នាក់ក៏ដោយ ដែលមកស្រុកខ្មែរ អាចតាំងទីរស់នៅយ៉ាងស្រួល ដូចជានៅស្រុកខ្លួនឯងដែរ។ មានការតែមួយមុខប៉ុណ្ណោះដែលត្រូវធ្វើ គឺរៀនភាសាខ្មែរ។ ក្រៅពីនោះ ក្នុងវិស័យសាសនា, ទំនៀមក្បួន... ព្រាហ្មណ៍នោះស្ថិតនៅក្នុងវង្ស៍វប្បធម៌ខ្លួនទាំងស្រុង ហើយអាចអានដោយខ្លួនឯង នូវសិលាចារិកសំស្ក្រឹតដែលមាននៅផ្ទាំងថ្មអង្គរផង។ ប៉ុន្តែគួរសង្កេតចំណុចចម្លែកមួយ៖ នៅចន្លោះស.វ.ទី៨ និងស.វ.ទី១៥ គ្មានវត្ថុអ្វីមកពីឥណ្ឌាសូម្បីតែមួយនៅលើទឹកដីនៃរាជធានីខ្មែរឡើយ។

---

[៣១] ឧទាហរណ៍ *Ceramics*, pl. M, no. 2។ "កន្ទុយ" សត្វនោះមានតួនាទីជាចង្ក្រង ចំណែកក្បាលវិញមិនសមគ្នានឹងខ្លួនទាល់តែសោះ...។ បើរូបនៅ *Export*, p. 114, no. 216 វិញ គឺប្រហែលជាលទ្ធផលនៃការផ្គុំខុសទំនង។

[៣២] លើចំណុចនេះ ខ្ញុំយល់ស្របទាំងស្រុងនឹងលោក W. Willetts ដែលបានសរសេរអំពីឥទ្ធិពលចិនលើកុលាលភាជន៍សួគាំលោក៖ *Celadons*, pp. 36-37។

ផ្ទុយទៅវិញ គេបានយកចេញពីស្រទាប់ដីផ្សេងៗ នូវបំណែកកុលាលភាជន៍ចិនរាប់សែន។ ដូច្នេះ បើវិស័យនេះមិនរាប់ថាជាសិល្បៈ ក៏អាចនិយាយថាជាសាខាដ៏សំខាន់មួយនៃបច្ចេកទេសខ្មែរ –ពោលគឺកុលាលភាជន៍ប្រកបដោយស្រទាប់រលោង– នាំចូលមកពីចិនដែរ។ ហើយមិនមែនមានតែករណីយ៍មួយនេះទេ។ ខ្ញុំបានពោលពីលើរួចមកហើយអំពីគ្រឿងប្រភេទផ្កាប់ផ្ងារ ដែលលេចចេញឡើងក្នុងពេលជាមួយគ្នា។ ចំពោះជនជាតិខ្មែរ ជាស្ថាបនិកដ៏ពូកែ ដែលទុកស្នាដៃពាសពេញទឹកដី ការចម្លងបច្ចេកទេសនេះ មិនមែនជាចំណុចតូចតាចឡើយ។ ឯសូត្រ ព្រមទាំងវាយនភណ្ឌមួយភាគក៏នាំមកពីចិនដែរ។ សិលាចារិកមាននិយាយអំពី "មុងមកពីស្រុកចិន" ដែលគេរក្សាជាសម្បត្តិទ្រព្យនៃប្រាសាទ។ លំអក្បាច់ចិនខ្លះ ត្រូវបានខ្មែរនិយមខ្លាំង រហូតដល់មានឆ្លាក់ត្រាប់តាមនៅលើមេទ្វារនៃប្រាសាទអង្គរវត្តនិងប្រាសាទបាយ័ន្តផង ថ្វីត្បិតតែចាប់តាំងពីស.វ.ទី៩មក ក្នុងវិស្វកម្មនិងស្ថាបត្យកម្ម ខ្មែរលែងទទួលឥទ្ធិពលពីក្រៅទៀតហើយក៏ដោយ។ ក្នុងសិល្បៈសម្រិតក៏ពុំខុសគ្នាដែរ បច្ចេកទេស មើលទៅឃើញថានាំចូលមកពីខាងជើង តាំងតែពីសម័យបុរេប្រវត្តិម្ល៉េះ។ បើនិយាយជាទូទៅ បច្ចេកទេសមួយចំនួនធំដែលអនុវត្តន៍នៅអង្គរ គឺមានប្រភពឬឥទ្ធិពលមកពីចិន។ យកតែឧទាហរណ៍មួយមកបង្ហាញក៏អាចឃើញច្បាស់ដែរ៖ នៅស.វ.ទី១២ ឧបករណ៍សង្គ្រាមសំខាន់ខ្លាំងមួយនៃព្រះបាទជ័យវ៌្មនទី៧ នាំចូលមកពីចិន គឺ "ស្នាយន្ត"[៧៣]។

បញ្ហាទាំងអស់នេះ ប្រមូលផ្ដុំមកបានជាវិស័យធំមួយដែលត្រូវសិក្សាទៅអនាគត។ ឧទាហរណ៍៖ តើពាណិជ្ជកម្មទំហំធំបែបនេះធ្វើឡើងរបៀបយ៉ាងដូចម្ដេច ហើយខ្មែរយកអ្វីទៅទូទាត់ឥវ៉ាន់នាំចូលមក? ប្រាសាទបាយ័ន្តមានផ្ទាំងចម្លាក់ខ្លះដែលគួរពិនិត្យ។ នៅថែវរួតក្រៅ យើងមានទម្លាប់ហៅចម្លាក់មួយនោះថា "សំពៅចិន" ព្រមទាំងចម្លាក់មួយផ្ទាំងធំតែឯងថា "ផ្ទះបុរសចិន"។ ការដែលគេឆ្លាក់រូប "បរទេស" នៅលើជញ្ជាំងដែលចម្លាក់ទូទៅនិទានតែពីព្រះរាជានេះ គួរឲ្យចាប់អារម្មណ៍ពន់ពេក[៧៤]។ យោងតាមនេះយើងអាចសន្មតថា សាសន៍ចិនជំនាន់នោះ ខ្មែរទទួលស្គាល់ ឬឲ្យសារៈសំខាន់ហើយ បានជាអនុញ្ញាតិឲ្យចេញមុខយ៉ាងនេះ។

ឥឡូវ ចូរយើងពិនិត្យមើល "ផ្ទះបុរសចិន" នោះបន្តិច (មើលរូបយ)។ ថាន (ជួរ) ពីរខាងលើបង្ហាញពីផ្នែកក្រោយនៃផ្ទះ (តាមទស្សនៈនៃគំនូរឬចម្លាក់ខ្មែរ)។ គេឃើញស្រីមេផ្ទះ ព្រមទាំងខ្ញុំកំដរដែលសុទ្ធតែជាខ្មែរ។ ខ្ញុំស្រីៗ កំពុងដណ្ដាំស្លសម្រាប់មេផ្ទះនោះ ដោយប្រើចង្ក្រាននិងឆ្នាំងខ្មែរ។ ថានខាងក្រោម បង្ហាញផ្នែកខាងមុខនៃផ្ទះ។ នៅទីនេះខ្ញុំកំដរប្រុសសុទ្ធតែជាចិន (មើលដឹងដោយមានកំបោយសក់ព្រមទាំងអាវចិន)។ ខ្លះចំអិនអាហារដោយប្រើកុលាលភាជន៍ខ្មែរដូចរូបខាងលើដែរ។ ខ្លះទៀតបឺតស្រាតាមកូនបំពង់ពក ពីក្នុងឱទិនតូចមួយ។ ស្រានោះប្រហែលជាខ្លាំងហើយ បានជាអ្នកបម្រើម្នាក់នោះស្រវឹង ហើយលោតឡកមុខមិត្តភក្ដិរបស់ខ្លួន។

នៅរួតថែវដដែលនេះ មានចម្លាក់មួយកន្លែងបង្ហាញពីពួកចិនកំពុងស៊ីផឹកសប្បាយក្អាកក្អាយនៅលើសំប៉ាន់មួយ ដោយបឺតស្រាតាមបំពង់ពក។ ចម្លាក់រូបស៊ីផឹករបៀបនេះ មានមួយកន្លែងនៅប្រាសាទបន្ទាយឆ្មារដែរ ដែលសាងឡើងជំនាន់ជាមួយគ្នានេះ។ បើជាងចម្លាក់ខ្មែរ –ដែលតែងតែវាងវៃក្នុងការសង្កេតលក្ខណៈនិងចរិតមនុស្ស– ចូលចិត្តឆ្លាក់រឿងរបៀបនេះ គឺច្បាស់ជាខ្មែរជំនាន់នោះយល់ (ខុសឬត្រូវ) ថាចិនជាអ្នកចូលចិត្តសប្បាយហួសប្រមាណ...។

នៅថានទី២រាប់ពីក្រោមឡើង គេឃើញចិនម្ចាស់ផ្ទះពីរនាក់។ ម្នាក់នៅកណ្ដាលផ្ទាំងកំពុងនិយាយជាមួយឈ្នួលបម្រើដែលសុទ្ធតែជាចិនទាំងអស់ ហើយដែលកាន់មាន់រស់ ហាក់ដូចជាទើបនឹងមកពីផ្សារ។ ម្ចាស់ផ្ទះម្នាក់ទៀតអង្គុយនៅលើកូនគ្រែទាបមួយ ដែលមានលក្ខណៈចិន។ នៅស្រុកខ្មែរ មានតែព្រះរាជាទេ ទើបអាចគង់លើអសនៈខ្ពស់ជាងគេ ពោលគឺលើគ្រែទាបមួយ។ នៅមុខម្ចាស់ផ្ទះនោះ មានកូនតុតូចទាបមួយ ដែលជាសង្ហារិមចិនដូចមុនដែរ។ នៅពីលើកូនតុ មានកុលាលភាជន៍មួយមានគម្រប ដែលប្រាកដជាវត្ថុមានតម្លៃ។ នៅចំពីមុខគាត់ បុរសម្នាក់កាន់ក្រឡ *mei ping* រីឯពីរនាក់ទៀតកាន់ពែង។ នៅលើផ្ទឹមផ្ទះ គេព្យួរច័ត្រចិន (ច័ត្រទាំងនោះច្បាស់ជាធ្វើពីក្រដាសជ្រលក់នឹងប្រេង) ព្រមទាំងថូមានរាងឃ្លោក។ មើលទៅគឺសុទ្ធតែជារបស់ដែលចិននាំចូលមកខ្មែរ។ មិនមែនជាការចៃដន្យឡើយ ដែលរបស់ជាទីចាប់អារម្មណ៍នៃសិល្បៈករ គឺជាកុលាលភាជន៍។ បើបកស្រាយថា កន្លែងនេះជាផ្ទះអ្នកជំនួញចិនម្នាក់ដែលនាំកុលាលភាជន៍ពីស្រុកចិនចូលមកលក់នៅអង្គរ រវាងឆ្នាំ១២០០ ប្រហែលជាពុំខុសទេ។

ទោះបីមានវត្ថុដ៏ប្រណិតពីចិនជាគម្រូក្ដី ស្មូនខ្មែរមិនស្ទុះលោតទៅរកកំពូល។ របស់របរដែលផលិត ជួនកាលមានសោភណភាពគួរឲ្យចាប់ភ្នែកដែរ បើនិយាយពីរវាងពាក់កណ្ដាលស.វ.ទី១១ផង គឺស្ទើរតែមានភាពឥតខ្ចោះ។ ប៉ុន្តែយ៉ាងណា ក៏ជាទូទៅគុណភាពនៅថ្ងាយពីកុលាលភាជន៍ចិន

---

[៧៣] P. Mus, "Les Balistes du Bayon", *Bulletin de l'Ecole Française d'Extrême-Orient,* Hanoi, 1929, t. XXIX, pp. 135-145។

[៧៤] B.P. Groslier, *Le Bayon..., op. cit.,* pp. 167-168។

ហើយមិនទាន់ស្មើសេឡាដនទៅសូគាំលោកផង។ លំអក្បាច់មិនសូវខ្លាំងក្លាទេ អាចថាខ្សត់ខ្សោយក៏សឹងបាន។ ស្ទួនច្រើនតែសង្វៀបក្បាច់លំអទាំងប៉ុន្មានមកនៅត្រឹមតែជើងកោសនិងខ្សែច្នួតជួរៗប៉ុណ្ណោះ។ ឧទាហរណ៍៖ ហេតុម្តេចបានជាមិនដែលឃើញមានលំអដោយលាបពណ៌ ឬដោយសូនឬគូររូបអ្វីមួយភ្ជាប់និងថូផ្សេងៗ[៧៥]? លុះប្រៀបវិស័យនេះទៅនឹងសិល្បៈសម្រិតវិញ ទើបឃើញច្បាស់ថាខ្មែរពុំឱ្យតម្លៃលើដីឥដ្ឋឡើយ។ មានតែនៅស.វ.ទី១២ ប៉ុណ្ណោះ ដែលឃើញមានលេងយ៉ាងប៉ិនប្រសប់នូវក្បាច់ចេញពកសើៗលើផ្ទៃកុលាលភាជន៍ ក្រោមស្រទាប់រលោងស្រអាប់តិចៗ។ ឯសោភណភាពធំជាងគេបង្អស់ គឺស្ថិតនៅរូបរាង ដែលបញ្ចេញភាពបរិសុទ្ធ មិនឈ្លើយ។

ក្នុងប្រវត្តិសិល្បៈកុលាលភាជន៍ទាំងមូលនេះ ខ្មែរបានបង្កើតតែរូបរាងរបស់របរប៉ុណ្ណោះ គ្មានបង្កើតអ្វីថ្មីខាងវិស័យបច្ចេកទេសឡើយ។ មានតែនៅតាមខេត្តភូមិភាគ 'ព្លៀសាន' (ប្រទេសសៀមបច្ចុប្បន្ន) ទើបស្ទួនខ្មែរបង្កើតធ្វើចេញជាកុលាលភាជន៍ នូវវត្ថុដែលធម្មតាសិតជាសម្រិត។ នេះជាមាគាំសិល្បៈមួយគួរឱ្យកត់សម្គាល់។ ចំពោះកុលាលភាជន៍ដែលមានរូបសត្វ មិនឃើញមានប្រើមធ្យោបាយអ្វីច្រើនទេ តែរបស់អស់ទាំងនេះមានទឹកដមគួរឱ្យទាក់ចិត្ត។ ចំណុចនេះគ្មានអ្វីប្លែកឡើយ ព្រោះគេធ្លាប់ស្គាល់ថាខ្មែរមានទេពកោសល្យខ្លាំងណាស់ក្នុងការឆ្លាក់រូបសត្វ។

កាលបើយកការចាប់ចិត្ត និងការទាស់ ដែលបានពោលទាំងអម្បាលមាណមកថ្លឹងថ្លែងទៅ ឃើញថាថ្វីត្បិតតែកុលាលភាជន៍ខ្មែរជាសិល្បៈបន្ទាប់បន្សំ ក៏គង់សំខាន់ល្មមសមនឹងឱ្យចាប់អារម្មណ៍យកចិត្តទុកដាក់ដែរ។

៧៥ *Legend*, no. 91, បង្ហាញអំពីក្រឡមួយ ដែលមានច្នួតរូបត្រីយ៉ាងល្អមួយ លេចចេញពីក្រោមស្រទាប់រលោងនៅលើក្អេង។ ប៉ុន្តែដោយសង្កេតលើរាងវា, លើស្រទាប់រលោង ព្រមទាំងលើក្បាច់លំអ ខ្ញុំមិនជឿថាជាវត្ថុខ្មែរទេ។

កំណត់អ្នកប្រែ៖ ច្បាប់ខ្មែរនេះ ប្រែពីអត្ថបទលោក Bernard-Philippe Groslier ឈ្មោះ Introduction to the Ceramic Wares of Angkor ដែលចុះនៅក្នុងសៀវភៅរួមមួយឈ្មោះ Khmer Ceramics. 9th-14th Century ហើយដែលផ្សព្វផ្សាយនៅឆ្នាំ ១៩៨១ ដោយសមាគម Southeast Asian Ceramic Society ក្រោមការទទួលខុសត្រូវនៃអ្នកស្រី Diana Stock។ ការផ្សព្វផ្សាយនោះធ្វើឡើងក្នុងឱកាសពិព័រណ៍មួយនៅសិង្ហបុរីស្ដីពីកុលាលភាជន៍ខ្មែរ ដែលប្រមូលផ្ដុំវត្ថុចំនួនជាងមួយរយ។ ផ្នែកទីពីរនៃសៀវភៅរួម គឺជាកាតាឡុកពិព័រណ៍ដែលបង្ហាញវត្ថុទាំងអស់នេះតាមរូបថតពណ៌ មានលេខរៀងពី ១ ដល់ ៩៧។ នៅទីនេះ ខ្ញុំចោះយកតែរូបណាដែលអ្នកនិពន្ធបានធ្វើការបញ្ជូនឲ្យមើល។ ខ្ញុំមិនប្រែសេចក្ដីបរិយាយលើវត្ថុនីមួយៗទេ ត្បិតពុំមែនជារបស់លោក Groslier។ ប៉ុន្តែខ្ញុំចុះអំពីទំហំវត្ថុដែរ បើពុំដូច្នោះ អ្នកអានមិនអាចស្មានបានថារបស់នេះឬរបស់នោះ ធំឬតូចយ៉ាងដូចម្ដេចឡើយ។ ក្រៅពីនេះ មានរូបថតសខ្មៅរបស់លោក Groslier ផ្ទាល់ចំនួនប្រាំ ដែលមានអត្ថាធិប្បាយច្រើន។

តាំងអំពីលោក Groslier សរសេរអត្ថបទនេះមក ការសិក្សាអំពីកុលាលភាជន៍ខ្មែរ រីកចម្រើនទៅមុខជាលំដាប់ ជាពិសេសគេបានប្រទះឃើញឡកុលាលភាជន៍បុរាណមួយចំនួននៅតំបន់អង្គរ ជាហេតុធ្វើឲ្យយើងមានទិន្នន័យច្រើនជាងជំនាន់នោះ។ យ៉ាងណាក៏ដោយ វិភាគទូទៅនៃលោក Groslier មានសារៈសំខាន់ពន់ប្រមាណ ព្រោះលោកពុំត្រឹមតែយកចិត្តទុកដាក់លើកុលាលភាជន៍ជា "វត្ថុ" ប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈវត្ថុទាំងនេះ លោកបានលាតត្រដាងអំពីទិដ្ឋភាពមួយនៃអារ្យធម៌ខ្មែរបុរាណ។

ទស្សនាវដ្ដី Péninsule *(លេខ ៣១, ប៉ារីស៍ ១៩៩៥, ទ. ៥_៥៩)* បានចុះអត្ថបទដដែលនេះដែរជាភាសាបារាំង គឺសំណេរដែលលោក Groslier មិនបានផ្សាយ ហើយប្រហែលជាមិនទាន់បានកែកុនបញ្ចប់នៅឡើយ។ អ្នករៀបរៀងទស្សនាវដ្ដីបានយកមករៀបចំជាជំពូកផ្សេងៗ ព្រមទាំងមានអត្ថាធិប្បាយក្រៅបន្ថែមច្រើនផង។ សំណេរបារាំងនោះផ្ដល់នូវជំនួយច្រើនដល់ខ្ញុំដែរ ប៉ុន្តែអត្ថបទគោលគឺខ្ញុំយកអង់គ្លេស ដោយសារជាអត្ថបទដែលអ្នកនិពន្ធខ្លួនឯងបានដឹងឮ យល់ព្រមឲ្យផ្សព្វផ្សាយជាសាធារណៈ។

ខ្ញុំគ្មានសមត្ថភាពនឹងធ្វើការបកប្រែឲ្យបានចំច្បាស់ៗទេ។ កត្តាមួយដែលសំខាន់ គឺយើងពុំទាន់មានពាក្យបច្ចេកទេសខ្មែរគ្រប់គ្រាន់ក្នុងវិស័យកុលាលភាជន៍នៅឡើយ។ ខ្មែរបុរាណច្បាស់ជាមាន ប៉ុន្តែដោយសារសិល្បៈនេះសាបសូន្យទៅ ពាក្យអស់នោះយើង *(ឬខ្ញុំ)* លែងស្គាល់។

ដូច្នេះច្បាប់ខ្មែរ គ្រាន់តែជាការ "ប្រែសម្រួល" តែប៉ុណ្ណោះ។

អាំង ជូលាន



ខ

លំអិតអំពីភាជន៍ដាក់អាហារក្នុងរូប "ក១" និង "ក២"។ ភាជន៍នោះរាង មូលដូចបំពង់ (ឥតមានគម្របទេ) ហើយគេបំពេញអាហារទាល់តែ ហៀរទៅលើ។ គេអាចគិតថានេះជាកុលាលភាជន៍ដែលមានគ្រប ឬក៏ ជាភាជន៍សិតពីលោហធាតុផង។ ប៉ុន្តែខ្ញុំជឿថានេះជាវត្ថុដែលត្បាញអំពី ពោក់ហើយលាបជ័រុក្ខជាតិ ដែលគេប្រើប្រាស់ជាទូទៅក្នុងកម្ពុជាសម័យ បុរាណ។ សន្និដ្ឋាននេះក្រោយពីបានពិនិត្យរូបរាងវត្ថុ ជាពិសេសគន្លាក់ រង្វង់នៅលើនិងនៅក្រោម។ សូមកុំភ្លេចថានេះជាការទទួលទានអាហារ នៅកណ្តាលធម្មជាតិ។ ឯភាជន៍ប្រភេទនេះ គឺងាយស្រួលប្រើប្រាស់ក្នុង ការបោះជម្រុំដូច្នេះឯង។



គ

លំអិតមួយផ្នែកនៃរូប "ក១"។ អ្នកបម្រើម្នាក់កាន់កំសៀវមួយ។ ពិនិត្យ ចំពួយនោះទៅ ឃើញថាកំសៀវនេះធ្វើអំពីលោហធាតុ។ របៀបដែល មនុស្សនោះកាន់កំសៀវហាក់ដូចជាចម្លែកបន្តិច។ ដៃពីរដែលខ្វែងគ្នា នៅដើមទ្រូង ជាសញ្ញានៃការលំអោនគោរពចំពោះព្រះមហាក្សត្រ និង អ្នកមុខអ្នកការនានា។ ដូច្នោះហើយ បានជារបៀបកាន់មានភាពចម្លែក។



ឃ

ប្រាសាទបាយ័ន្ត, *រវាងគ.ស.១២០០*, នៅថែវខាងក្រៅ, ជ្រុងអាគ្នេយ៍។ នេះគឺរូបដែលគេនិយមហៅថា "ផ្ទះបុរសចិន"។ ថានពីរជួរខាងលើ គឺជាផ្នែកខាងក្រោយនៃផ្ទះ ដែលបង្ហាញអំពីគ្រួសាចិននោះ ព្រមដោយខ្មែរជាអ្នកបម្រើ។ ចូរពិនិត្យមើលការដណ្ដាំស្ល ដោយក្រុមមនុស្សស្រី។ ថានក្រោមគឺជាផ្នែកខាងមុខនៃផ្ទះ ដែលបង្ហាញអំពីការដណ្ដាំស្លដោយប្រុសៗចិនអ្នកបម្រើ *(គេមើលស្គាល់ដោយសម្លៀកបំពាក់ និងកំប៉ោយសក់)*។ គេកំពុងត្រងសម្រក់ឈាមកូនប្រើសទៅក្នុងភាជន៍មួយ។ បុរសម្នាក់កូរម្ហូបទឹក ដោយប្រើវែកមួយវែង ក្រង៉ុកខាងចុង។ ម្នាក់ទៀតបឹតស្រាអំពីក្រឡ តាមកូនបំពង់មួយ។ ថានលើបន្ទាប់មក បង្ហាញអំពីពួកចិនម្ចាស់ផ្ទះ។ ម្នាក់នៅខាងឆ្វេងអង្គុយនៅលើកៅអីទាប *(សង្ហារឹមចិន)* ព្រមទាំងកាន់កូនពែង *(តែ?)*។ នៅមុខគាត់ មានកូនតុចិនមួយទាប។ លើនោះមានភាជន៍តូចមានគម្របមួយ ដែលមើលទៅច្បាស់ជាវត្ថុមានតម្លៃ។ នៅមុខកូនតុនោះ បុរសម្នាក់កំពុងទទួលទានភេសជ្ជៈ ដោយប្រើពែងមួយ។ អ្នកបម្រើម្នាក់កាន់ក្រឡ mei ping។ គេចង់ជាប់ផ្ដឹមផ្ទះ នូវភាជន៍មូលទ្រវែងដែលមានស្រាចិន ដើម្បីទាក់ទាញអារម្មណ៍អ្នកទិញ។



រូបលេខ១១
កំពស់ ១៦,៥ស.ម. វិជ្ឈមាត្រ ១០ស.ម.



រូបលេខ១២



រូបលេខ១៣
កំពស់ ១៣ស.ម.



រូបលេខ១៤
បណ្ដាយ ២២ស.ម.
ទទឹងចុងម្ខាងតូច ១១,៥ស.ម.
ទទឹងចុងម្ខាងធំ ១៤ស.ម.



រូបលេខ១៥
កំពស់ ៨ស.ម.



រូបលេខ១៦
កំពស់ ១២ស.ម. វិជ្ឈមាត្រ ១៦ស.ម.



រូបលេខ១៧
កំពស់ ១៣ស.ម. វិជ្ឈមាត្រ ២០ស.ម.



រូបលេខ៨
កំពស់ ៨ស.ម.



រូបលេខ៩
កំពស់ ១០ស.ម. គិតទាំងគម្រប



រូបលេខ១០
កំពស់ ២៦,៥ស.ម.



រូបលេខ១១
រូបក មានកំពស់ ២៤ស.ម.
រូបខ មានកំពស់ ២២,៥ស.ម.



រូបលេខ១២
កំពស់ ៩ ស.ម. វិជ្ឈមាត្រ ១៨ស.ម.



រូបលេខ១៣. កំពស់ ៩ស.ម.



រូបលេខ១៤. កំពស់ ២១ស.ម.



រូបលេខ១៥. កំពស់ ១៦,៥ស.ម. ឥតគិតគម្រប



រូបលេខ១១៦. កំពស់ ៨,៥ស.ម.



រូបលេខ១១៧. កំពស់ ២៦,៥ស.ម.



រូបលេខ១១៨. កំពស់ ៥៣ស.ម.



រូបលេខ១១៩. រូបក មានកំពស់ ៩ស.ម.
រូបខ មានកំពស់ ១១,៥ស.ម.



រូបលេខ១២០. កំពស់ ១០,៥ស.ម.



រូបលេខ១២១. កំពស់ ៧,៥ស.ម.



រូបលេខ១២២. កំពស់ ១៩,៥ស.ម.



រូបលេខ១២៣. កំពស់ ២០ស.ម.



រូបលេខ១២៤. កំពស់ ៦,៥ស.ម.



រូបលេខ២២៥. រូបក មានកំពស់ ៨ស.ម.
រូបខ មានកំពស់ ៧,៥ស.ម.



រូបលេខ២២៦. កំពស់ ២៧,៥ស.ម.



រូបលេខ២២៧. កំពស់៧,៥ស.ម.



រូបលេខ២២៨. បណ្ដោយប្រវែង ១៨ស.ម.



រូបលេខ២២៩. កំពស់ ១៨,៥ស.ម.



រូបលេខ២៣០. កំពស់ ១៦ស.ម.



រូបលេខ២៣១. កំពស់ ៣៦,២ស.ម.



រូបលេខ២៣២. រូបក មានកំពស់ ៧ស.ម.
រូបខ មានកំពស់ ៥ស.ម.



រូបលេខ២៣៣. កំពស់ ៩,៥ស.ម.



រូបលេខ២៣៤



រូបលេខ២៣៥. កំពស់ ២៥ស.ម.



រូបលេខ២៣៦. កំពស់ ២៩,៥ស.ម.



រូបលេខ២៣៧. កំពស់ ៩,៧ស.ម.



រូបលេខ២៣៨. កំពស់ ៨,៥ស.ម.



រូបលេខ២៤០. រូបក មានកំពស់ ៧,៥ស.ម. គិតទាំងគម្រប
រូបខ មានកំពស់ ៨ស.ម. គិតទាំងគម្រប
រូបគ មានកំពស់ ១១,៥ស.ម. គិតទាំងគម្រប
រូបឃ មានកំពស់ ១០ស.ម. គិតទាំងគម្រប



រូបលេខ២៣៩
កំពស់ ១៥ស.ម. គិតទាំងកំពៅយកាន់



រូបលេខ២៤១. កំពស់១២,៥ស.ម. វិជ្ឈមាត្រ ២៤ស.ម.



រូបលេខ២៤២. កំពស់ ១៣,៥ស.ម. វិជ្ឈមាត្រ ២២ស.ម.



រូបលេខ១៤៣. កំពស់ ៣២,៧ស.ម.



រូបលេខ១៤៤. កំពស់ ៣៤ស.ម.



រូបលេខ១៤៥. កំពស់ ២២ស.ម.



រូបលេខ១៤៦. កំពស់ ៦,៥ស.ម.
វិជ្ឈមាត្រ ១០ស.ម.



រូបលេខ១៤៧. កំពស់ ២២ស.ម.



រូបលេខ១៤៨. កំពស់ ១០ស.ម.



រូបលេខ១៤៩. កំពស់ ៧ស.ម.



រូបលេខ១៥០. រូបក មានកំពស់ ២,៥ស.ម.
រូបខ មានកំពស់ ៣ស.ម.
រូបគ មានកំពស់ ៣,៥ស.ម.
រូបឃ មានកំពស់ ៣ស.ម.



រូបលេខ៥១. រូបក មានកំពស់ ៨,២ស.ម.
រូបខ មានកំពស់ ៣,១ស.ម.
រូបគ មានកំពស់ ៧ស.ម.



រូបលេខ៥២. កំពស់ ៥១ស.ម.



រូបលេខ៥៣. រូបក មានកំពស់ ៨ស.ម.
រូបខ មានកំពស់ ៧ស.ម.



រូបលេខ៥៤. កំពស់ ៦,៥ស.ម.



រូបលេខ៥៥. កំពស់ ៩,៥ស.ម.



រូបលេខ៥៦. រូបក មានកំពស់ ៨,២ស.ម.
រូបខ មានកំពស់ ៧ស.ម.



រូបលេខ៥៧. កំពស់ ៥១ស.ម.



រូបលេខ៥៨. កំពស់ ១១ស.ម.



រូបលេខ១៥៩. កំពស់ ៦ស.ម.



រូបលេខ១៦០. កំពស់ ៦ស.ម.



រូបលេខ១៦៣. កំពស់ ៥៩ស.ម.



រូបលេខ១៦១. កំពស់ ៨,៥ស.ម. វិជ្ឈមាត្រ ១៧,៥ស.ម.



រូបលេខ១៦២. កំពស់ ៣២ស.ម.



រូបលេខ១៦៦. កំពស់ ១៣,៥ស.ម.



រូបលេខ១៦៤. កំពស់ ៥៦,៥ស.ម.



រូបលេខ១៦៥. កំពស់ ១៤,៥ស.ម.



រូបលេខ១៦៧. កំពស់ ១២,៧ស.ម.
គិតទាំងគម្រប



រូបលេខ២៦៨. កំពស់ ៩ស.ម.



រូបលេខ២៦៩. កំពស់ ១២ស.ម. បណ្ដោយប្រវែង ១៨ស.ម.



រូបលេខ២៧០. ប្រវែងបណ្ដោយខ្លួន ១៨ស.ម. ប្រវែងមូលជុំខ្លួន ២៤ស.ម.



រូបលេខ២៧១. កំពស់ ៩ស.ម.



រូបលេខ២៧២. កំពស់ ១១ស.ម.



រូបលេខ២៧៣. ប្រវែងបណ្ដោយខ្លួន ១៨ស.ម. ប្រវែងមូលជុំខ្លួន ២៥,២ស.ម.